**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ប្រសិទ្ធភាពនៃការអប់រំ
# នៅសាលាបឋមសិក្សាវត្តបូព៌

កម្មសិក្សាពីថ្ងៃទី១៦ ខែមីនា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ ២០២០

ឈ្មោះស្ថាប័ន៖ **សាលាបឋមសិក្សាវត្តបូព៌**

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ជុំ ពេជ្រនីតា**

**អ៊ិន វឌ្ឍនា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **វ៉ាន់ ស៊ីនដេត**

បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៤

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេររបាយការណ៍ ២០២០

# អារម្ភកថា

សេដ្ឋកិច្ចអភិវឌ្ឍន៍ គឺជាជំនាញមួយដែលមានសារសំខាន់យ៉ាងខ្លាំង ព្រោះគោលបំណងចំបងនៃមុខជំនាញនេះ គឺដើម្បីរិះរកនូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់ប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិមួយឲ្យបន្តមានភាពប្រសើរឡើងជានិច្ច។ បន្ទាប់ពីបានសិក្សាមុខជំនាញមួយនេះមក យើងខ្ញុំទទួលបាននូវចំណេះដឹងជាច្រើនជុំវិញកត្តាដែលចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឲ្យទទួលបាននូវការរីកចំរើនលើគ្រប់វិស័យ។ ក្នុងនោះដែរយើងខ្ញុំបានសង្កេតឃើញថាកត្តាធនធានមនុស្សជាកត្តាសំខាន់មួយ និងជាចលករដែលពុំអាចខ្វះបានសម្រាប់ការអភិវឌ្ឍសង្គមជាតិ។ ឆ្លៀតក្នុងឱកាសនេះយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយដែលស្តីពី " ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ " ធ្វើជាប្រធានបទនៃកម្មសិក្សាសម្រាប់ធ្វើបទបង្ហាញនៅពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រ។

ចំពោះខ្លឹមសារនៃនិក្ខេបបទមានគោលបំណងឆ្លុះបញ្ចាំងឲ្យឃើញពីសារសំខាន់នៃវិស័យអប់រំ ដែលវិស័យអប់រំនេះទៀតសោត គឺទាមទារឲ្យមានការយកចិត្តទុកដាក់តាំងពីថ្នាក់មូលដ្ឋានមកម្ល៉េះ ពោលគឺតាំងពីថ្នាក់មត្តេយ្យ ក៏ដូចជាថ្នាក់បឋមសិក្សា ព្រោះកុមារប្រៀបបានទៅនឹងទំពាំងដែលទើបតែដុះពន្លក ប្រសិនបើយើងមើលថែទាំទំពាំងបានល្អ នោះយើងនឹងទទួលបាននូវប្រភេទឬស្សីដែលមានគុណភាពសមាមាត្រទៅនឹងការថែទាំរបស់យើងដូចគ្នា។ ដូចគ្នានេះដែរបើយើងប្រៀបធៀបទៅនឹងមនុស្សវិញ បើកាលណាកុមារទទួលបាននូវការយកចិត្តទុកដាក់ និងបង្ហាត់បង្រៀនផ្នែកចំណេះដឹងទូទៅនៅថ្នាក់មូលដ្ឋានឲ្យបានដិតដល់នោះពួកគេនឹងក្លាយទៅជាធនធានមនុស្សដែលពោរពេញដោយចំណេះវិជ្ជា។ ទន្ទឹមនឹងនេះសិស្សានុសិស្សទាំងអស់ក៏ទាមទារឲ្យមានការហ្វឹកហាត់ផ្នែកស្មារតី កាយសម្បទារ សីលធម៌ គុណធម៌ និងចរិយាធម៌ ព្រោះកត្តាទាំងអស់នេះនឹងកាន់តែជំរុញឲ្យពួកគាត់ក្លាយទៅជាបុគ្គលដែលមានសក្តានុពលនៅក្នុងសង្គម និងជាធនធានមួយដែលល្អប្រពៃសម្រាប់ជាទីពំនាក់របស់ គ្រួសារ សហគមន៍ ជាពិសេសគឺសង្គមជាតិនឹងកាន់តែមានការរីកចំរើនទៅមុខប្រកបដោយស្ថេរភាព និងនិរន្តរភាព។

ជាចុងក្រោយ យើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយអចេតនា ហើយក្រុមយើងខ្ញុំទទួលស្វាគមន៍ជានិច្ចនូវរាល់មតិរិះគន់ដើម្បីស្ថាបនា ពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ លោក លោកស្រី អ្នកនាង កញ្ញា សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ ដើម្បីជាបទពិសោធន៍ និងបង្កើននូវភាពទូលំទូលាយក្នុងការស្រាវជ្រាវនាពេលក្រោយៗទៀត។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ជុំ ពេជ្រនីតា និង អ៊ិន វឌ្ឍនា ជានិស្សិតជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ក្រុម $D_4C_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមសំដែងការដឹងគុណចំពោះ

លោកឪពុក **ជុំ សុផាន** និង អ្នកម្តាយ **សុខ សារឹម** ព្រមទាំងលោកឪពុក **អ៊ិន ចាន់ថុល** និង អ្នកម្តាយ **យឹម ណារ៉េត** ដែលបានផ្តល់កំណើតដល់កូន ចិញ្ចឹមបីបាច់ថែរក្សាកូនប្រកបដោយព្រហ្មវិហារធម៌តាំងពីតូចរហូតដល់ធំដឹងក្តី យកចិត្តទុកដាក់ មើលថែរក្សា ដើរតួនាទីជាទីប្រឹក្សាដ៏ល្អ និងតែងតែផ្តល់កម្លាំងចិត្តជំរុញកូនៗឲ្យឆ្លងកាត់ឧបសគ្គនានាប្រកបដោយជោគជ័យ ជាពិសេសគឺការផ្តល់ឱកាសឲ្យកូនៗបានសិក្សារៀនសូត្រក្រេបជញ្ជក់យកចំណេះដឹងតាំងពីថ្នាក់ដំបូងរហូតដល់បានបញ្ចប់បរិញ្ញាបត្រនេះ។

**ក្រសួងអប់រំ យុវជន និងកីឡា** ព្រមទាំង**គណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានផ្តល់ជាអាហារូបករណ៍សម្រាប់រយៈពេលសិក្សា៤ឆ្នាំពេញដល់យើងខ្ញុំ។ ការផ្តល់អាហារូបករណ៍នេះជាឱកាសមួយដ៏មានតម្លៃក្រៃលែងសម្រាប់យើងខ្ញុំបានមកសិក្សា និងទទួលយកចំណេះដឹងនៅទីនេះ។ យើងខ្ញុំក៏សូមអរគុណចំពោះ លោក លោកស្រីសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ ព្រមទាំងបុគ្គលិកគ្រប់លំដាប់ថ្នាក់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវចំណេះដឹង និងបទពិសោធន៍ផ្សេងៗសម្រាប់និស្សិតគ្រប់រូបដើម្បីវិវត្តខ្លួនក្លាយជាធនធានមនុស្សដែលជួយអាចដល់គ្រួសារ សហគមន៍ និងសង្គមជាតិ។

លោកសាស្ត្រាចារ្យបណ្ឌិត **ច៉ាន់ ស៊ីនដេត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំក្រុមស្រាវជ្រាវរបស់យើងខ្ញុំ ដោយការយកចិត្តទុកដាក់បំផុតតាំងពីការចាប់ផ្តើមរហូតដល់ពេលបញ្ចប់រួចរាល់ និងទទួលបានជោគជ័យជាស្ថាពរ។

**សាលាបឋមសិក្សាវត្តបូព៌** ដែលបានអនុញ្ញាតឲ្យយើងខ្ញុំចុះកម្មសិក្សា និងផ្តល់នូវរាល់ឯកសារក៏ដូចជាមតិយោបល់ សម្រាប់យើងខ្ញុំបានចងក្រងជាសៀវភៅនេះឡើង។

ជាមួយគ្នានេះដែរ ក្រុមគ្រួសារសាច់ញាតិ និងមិត្តទាំងអស់ដែលបានជួយ ផ្តល់ជាយោបល់ល្អៗចែករំលែកចំណេះដឹង និងជំរុញទឹកចិត្តគ្រប់ពេលវេលា។

យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវនេះនឹងអាចផ្តល់ជាអត្ថប្រយោជន៍ដល់មិត្តអ្នកអានគ្រប់រូប ពិសេសគឺបង្កភាពងាយស្រួលដល់អ្នកសិក្សាស្រាវជ្រាវក្រោយៗទៀត ដែលមានបំណងសិក្សាពីជុំវិញបញ្ហាដូចគ្នានេះ។

ជាចុងក្រោយយើងខ្ញុំសូមគោរពជូនពរដល់អ្នកទាំងអស់មានសុខភាពល្អ មានសុវត្ថិភាព និងទទួលបាននូវភាពជោគជ័យលើគ្រប់ភារកិច្ចទាំងអស់។

# មាតិកា

**ទំព័រ**


បញ្ជីអក្សរកាត់ ........ v

បញ្ជីតារាង ........ vi

បញ្ជីក្រាហ្វិច ........ vii

បញ្ជីរូបភាព ........ viii

បញ្ជីឧបសម្ព័ន្ធ ........ ix


## សេចក្ដីផ្ដើម


១. លំនាំបញ្ហា ........ ២

២. គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ ៣

៣. ចំណោទបញ្ហា ........ ៣

៤. សារសំខាន់នៃការស្រាវជ្រាវ ........ ៣

៥. ទំហំ និងដែលកំណត់នៃការស្រាវជ្រាវ ........ ៤

៦. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៥


## ជំពូកទី១

## រំលឹកទ្រឹស្ដីពាក់ព័ន្ធនឹងការអប់រំ


១.១. និយមន័យអប់រំ ........ ៧

១.២. ទ្រឹស្ដីពាក់ព័ន្ធនឹងការអប់រំ ........ ៧

១.២.១. ទ្រឹស្ដីពួកនេអូក្លាសិក (Neoclassical Theory) ........ ៧

១.២.២. ទ្រឹស្ដីអ្នកម៉ាក្រូអ៊ែតមុនហ្វ៊ែរ (Edmund Phelps) ........ ៧

១.៣. ករណីសិក្សាប្រទេសដែលមានប្រព័ន្ធអប់រំល្អ ........ ៨

១.៣.១ ការអប់រំនៅប្រទេសជប៉ុន ........ ៨

១.៣.១.១ គោលបំណង និងគោលការណ៍នៃការអប់រំ ........ ៨

១.៣.១.២ មូលដ្ឋានគ្រឹះទាក់ទងនឹងការផ្ដល់ការអប់រំ ........ ៩

១.៣.១.៣ រដ្ឋបាលអប់រំ ........ ១១

១.៣.២ ការអប់រំនៅប្រទេសថៃ ........................................ ១២
១.៣.២.១ ប្រពន្ធ័អប់រំនៅប្រទេសថៃ ........................................ ១២
១.៣.២.២ យុទ្ធសាស្ត្រ និងគោលនយោបាយអប់រំថ្នាក់ជាតិរបស់ប្រទេសថៃ............ ១៣
១.៣.២.៣ កត្តាដែលប្រទេសថៃយកចិត្តទុកដាក់ ........................................ ១៤
១.៣.២.៤ ចំពោះគ្រូបង្រៀន និងថ្នាក់ដឹកនាំនៅប្រទេសថៃ ........................................ ១៤
១.៣.២.៥ សមិទ្ធផលដែលប្រទេសថៃទទួលបាន ........................................ ១៥
១.៣.១ ការអប់រំនៅប្រទេសសិង្ហបុរី ........................................ ១៥
១.៣.៣.១ កត្តាដែលប្រទេសសិង្ហបុរីមានភាពជឿនលឿន និងប្រសិទ្ធិភាពវិស័យអប់រំ ..១៥
១.៣.៣.២ លទ្ធផលការអប់រំដែលប្រទេសសិង្ហបុរីពឹង ........................................ ១៥
១.៣.៣.៣ ចំពោះគ្រូបង្រៀននៅប្រទេសសិង្ហបុរី ........................................ ១៦
១.៣.៣.៤ គោលនយោបាយរបស់រដ្ឋាភិបាលសិង្ហបុរីលើវិស័យអប់រំ ........................................ ១៦

## ជំពូកទី២

## ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

២.១ ប្រភេទនៃការអប់រំ ........................................ ១៨
២.២ ការវិវត្តន៍ប្រព័ន្ធអប់រំកម្ពុជា ........................................ ១៩
២.២.១ មុនសម័យអាណានិគមបារាំង ........................................ ១៩
២.២.២ សម័យអាណានិគមបារាំង (១៨៦៣ ដល់ ១៩៥៣) ........................................ ២១
២.២.៣ ប្រព័ន្ធអប់រំនៅចន្លោះឆ្នាំ (១៩៥៣ ដល់ ១៩៦០) ........................................ ២១
២.២.៤ សម័យសាធារណរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥) ........................................ ២៣
២.២.៥ សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩) ........................................ ២៣
២.២.៦ សម័យសាធារណរដ្ឋប្រជាមានិត្យកម្ពុជា (១៩៧៩ ដល់ ១៩៨៩) ........................................ ២៤
២.២.៧ សម័យព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣ ដល់ បច្ចុប្បន្ន) ........................................ ២៤
២.៣ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ ........................................ ២៦
២.៤ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ........................................ ៣១
២.៥ គោលនយោបាយនៃការអប់រំនៅប្រទេសកម្ពុជា ........................................ ៣៦
២.៦ ការចូលរួមរបស់វិស័យអប់រំក្នុងការអភិវឌ្ឍជាតិ ........................................ ៣៧

# ជំពូកទី៣

# ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌

៣.១ ប្រវត្តិ និងទីតាំងរបស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤០

៣.២ និមិត្តសញ្ញាសាលា ..... ៤០

៣.៣ ចំនួនអាគារ បន្ទប់ ថ្នាក់ គ្រូ និង សិស្ស ..... ៤២

៣.៤ កត្តារួមចំណែកធ្វើឲ្យការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌មានប្រសិទ្ធភាព ..... ៤៣

៣.៤.១ គោលនយោបាយរបស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤៣

៣.៤.១.១ ចក្ខុវិស័យរបស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤៤

៣.៤.១.២ បេសកកម្មរបស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤៥

៣.៤.១.៣ យុទ្ធសាស្ត្រអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤៥

៣.៤.១.៤ យុទ្ធវិធីការអប់រំ(សមាសភាគអប់រំ៥)របស់សាលាបឋមសិក្សាវត្តបូព៌ ..... ៤៦

៣.៤.២ ការអនុវត្តការងារជាក់ស្តែង ..... ៤៧

៣.៤.២.១ ការគ្រប់គ្រងធនធានមនុស្ស ..... ៤៧

៣.៤.២.២ ការអភិវឌ្ឍធនធានមនុស្ស ..... ៥១

៣.៤.២.៣ ការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាលា ..... ៥១

៣.៤.២.៤ ការរៀបចំបរិស្ថានក្នុងបរិវេណសាលា ..... ៥៤

៣.៤.២.៥ សកម្មភាពនៃការបង្រៀន និងរៀន ..... ៥៥

៣.៤.៣ ការទំនាក់ទំនងជាមួយសមាគមជាតិ និងអន្តរជាតិ ..... ៥៧

៣.៥ ស្នាដៃដែលសម្រេចបាន ..... ៥៧

៣.៥.១ ស្នាដៃរបស់នាយកសាលា ..... ៥៧

៣.៥.២ ស្នាដៃអង្គភាព ..... ៥៨

៣.៦ លទ្ធផលសិក្សារបស់សិស្សពីឆ្នាំ២០១៥ ដល់ ២០១៩ ..... ៥៨

៣.៧ លទ្ធផលស្រាវជ្រាវ ..... ៦១

៣.៧.១ ចំណុចខ្លាំង ..... ៦២

៣.៧.២ ចំណុចខ្វះចន្លោះ ..... ៦៣

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ....................................................................................................................៦៥
២. ការផ្តល់អនុសាសន៍ ..................................................................................................................៦៧

## ឯកសារយោង

## ឧបសម្ព័ន្ធ

# បញ្ជីអក្សរកាត់

| | |
|---|---|
| STEM | Science, technology, engineering, and mathematics |
| WIL | Work-Integrated Learning |
| CEFR | Common European Framework of Reference |
| 4 Hs | Head, Heart, Hand and Health |
| ភ វ ស | ភូមិ វត្ត/វិហារ សាលា |
| ICT | Information and Communications Technology |

# បញ្ជីតារាង

តារាង ១៖ សូចនាករ និងចំនុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំយុវជន និងកីឡា ......................៣៥
តារាង ២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាបឋមសិក្សាវត្តបូព៌...............................................................៤៨
តារាង ៣៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៥ ~ ២០១៦ ....................................................... ៥៩
តារាង ៤៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៦ ~ ២០១៧ ....................................................... ៥៩
តារាង ៥៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៧ ~ ២០១៨........................................................ ៦០
តារាង ៦៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៨ ~ ២០១៩ ........................................................ ៦១
តារាង ៧៖ អត្រាឡើងថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩....៦២
តារាង ៨៖ អត្រាត្រួតថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩......៦៣
តារាង ៩៖ អត្រាត្រួតថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩...... ៦៤

# បញ្ជីក្រាហ្វិច

ក្រាហ្វិច ១៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៥ ~ ២០១៦ ....................................................៥៩
ក្រាហ្វិច ២៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៦ ~ ២០១៧....................................................៦០
ក្រាហ្វិច ៣៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៧ ~ ២០១៨....................................................៦០
ក្រាហ្វិច ៤៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៨ ~ ២០១៩......................................................៦១

# បញ្ជីរូបភាព


រូបភាព ១ ៖ គំនូសបំប្រួញយុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤ ............................................ ២៧

រូបភាព ២៖ និមិត្តសញ្ញាសាលាបឋមសិក្សាវត្តបូព៌ ...................................................................... ៤០

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាកុមារប្រចាំសាលា
ឧបសម្ព័ន្ធទី២៖ សកម្មភាពក្រុមប្រឹក្សាបំពេញភារកិច្ច
ឧបសម្ព័ន្ធទី៣៖ ឯកសណ្ឋានរបស់គ្រូបង្រៀន
ឧបសម្ព័ន្ធទី៤៖ ឯកសណ្ឋានរបស់សិស្ស
ឧបសម្ព័ន្ធទី៥៖ សកម្មភាពស្ទេនមេដៃដើម្បីស្រង់វត្តមានរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី៦៖ ការធ្វើសមាធិពេលគោរពទង់ជាតិ
ឧបសម្ព័ន្ធទី៧៖ អាហារដ្ឋានក្នុងសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី៨៖ សកម្មភាពនៃការសិក្សាក្នុងសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី៩៖ សកម្មភាពនៃការរៀន និងបង្រៀនក្នុងសម័យកូវីដ១៩របស់សាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី១០៖ អាណាព្យាបាលរបស់សិស្សចូលរួមក្នុងសកម្មភាពសាលា
ឧបសម្ព័ន្ធទី១១៖ សកម្មភាពដែលព្រះសង្ឃអប់រំដល់សិស្សានុសិស្ស
ឧបសម្ព័ន្ធទី១២៖ សកម្មភាពដែលភ្ញៀវជាតិ និងអន្តរជាតិមកធ្វើទស្សនកិច្ចនៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី១៣៖ ប័ណ្ណសរសើរ និងពានរង្វាន់ផ្សេងដែលសាលាបឋមសិក្សាវត្តបូព៌ទទួលបាន
ឧបសម្ព័ន្ធទី១៤៖ កម្រងសំណួរ
ឧបសម្ព័ន្ធទី១៥៖ ចំនួនមហាជនគិតទៅតាមភេទ
ឧបសម្ព័ន្ធទី១៦៖ ចំនួនមហាជនគិតទៅតាមមុខងារ
ឧបសម្ព័ន្ធទី១៧៖ ការយល់ឃើញចំពោះកម្រិតនៃការសហការគ្នារវាងគ្រូ និងមាតាបិតាឬអាណាព្យាបាលសិស្សក្នុងការតាមដានការសិក្សារបស់សិស្ស
ឧបសម្ព័ន្ធទី១៨៖ ការរៀបចំសណ្តាប់ធ្នាប់ក្នុងទីធ្លាសាលាបឋមសិក្សាវត្តបូព៌ (សំដៅលើការរៀបចំផ្នែកបរិស្ថានស្អាត ការរៀបចំសាលាឲ្យមានសោភ័ណភាព មានពាក្យស្លោក និងសុភាសិតសម្រាប់អប់រំដល់ជនានុជនទាំងឡាយ មានសួនកំសាន្តសម្រាប់កុមារ...)
ឧបសម្ព័ន្ធទី១៩៖ សភាពលក្ខណៈបង្គន់អនាម័យនៅក្នុងសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២០៖ ទឹកស្អាតសម្រាប់ប្រើប្រាស់នៅក្នុងសាលា
ឧបសម្ព័ន្ធទី២១៖ បុគ្គលិកលក្ខណៈរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២២៖ កម្រិតនៃការយកចិត្តទុកដាក់ក្នុងការបង្រៀនរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២៣៖ បុគ្គលិកលក្ខណៈរបស់សិស្សនៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២៤៖ កម្រិតនៃការយកចិត្តទុកដាក់ក្នុងការសិក្សារបស់សិស្សនៅសាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២៥៖ ការយល់ឃើញចំពោះកំណែទម្រង់ថ្មីរបស់សាលាបឋមសិក្សាវត្តបូព៌
ឧបសម្ព័ន្ធទី២៦៖ បញ្ជីរាយនាមបុគ្គលិកតាមក្របខ័ណ្ឌអប់រំ ឆ្នាំសិក្សា ២០១៩ ២០២០
ឧបសម្ព័ន្ធទី២៧៖ លទ្ធផលនៃការសិក្សារបស់សិស្សចន្លោះឆ្នាំ ២០១៥ ដល់ ២០១៩
ឧបសម្ព័ន្ធទី២៨៖ សំណើសុំអនុញ្ញាតចុះកម្មសិក្សា

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានវ័យចំណាស់ជាងគេនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ ប្រទេសមួយនេះក៏ធ្លាប់ទទួលបាននូវភាពរុងរឿង និងរីកចំរើនស្ទើរគ្រប់វិស័យដែលគួរជាទីកោតស្ញប់ស្ញែងរបស់បរទេស ប៉ុន្តែគួរឲ្យសោកស្តាយដែលប្រទេសយើងទទួលរងនូវឥទ្ធិពលសង្គ្រាមរ៉ាំរ៉ៃអស់ជាច្រើនទសវត្សថែមទាំងបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធជាតិអស់យ៉ាងច្រើន ព្រមទាំងការបាត់បង់ធនធានមនុស្សក្នុងសម័យសង្គ្រាមនោះផងដែរ។ ទោះបីជាប្រទេសជាតិទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងណាក៏ដោយ ក៏ថ្នាក់ដឹកនាំ និងប្រជាពលរដ្ឋគ្រប់រូបនាសម័យបច្ចុប្បន្ននេះបានរួបរួមគ្នាជាធ្លុងមួយក្នុងការកសាងប្រទេសជាតិឡើងវិញរហូតក្លាយជាប្រទេសកំពុងអភិវឌ្ឍន៍។ ទន្ទឹមនឹងការឈានមកដល់ចំណុចនេះបាន គឺទាមទារឲ្យមានការចូលរួមពីគ្រប់វិស័យទាំងអស់ ពិសេសគឺវិស័យអប់រំធនធានមនុស្សគ្រប់កម្រិតថ្នាក់ ដែលជាចលករដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សង្គមជាតិឲ្យសមស្របទៅតាមការវិវត្តន៍នៃពិភពលោកនាពេលបច្ចុប្បន្ន និងអនាគតកាល។ ជាការពិតណាស់នៅពេលដែលប្រទេសជាតិមួយបានយកចិត្តទុកដាក់ក្នុងការអប់រំ និងបណ្តុះបណ្តាលប្រជាពលរដ្ឋរបស់ខ្លួនជាចំបង គួបផ្សំនឹងការខិតខំប្រឹងប្រែងរៀនសូត្រ និងក្រេបជញ្ជក់ចំណេះដឹងរបស់ប្រជាពលរដ្ឋផងនោះ ជាលទ្ធផលប្រជាពលរដ្ឋរបស់ប្រទេសនោះនឹងទទួលបានចំណេះដឹង និងជំនាញពិតប្រាកដជាក់ជាមិនខាន។ ប៉ុន្តែការអប់រំត្រឹមតែចំណេះដឹង និងចំណេះធ្វើពុំទាន់គ្រប់គ្រាន់នៅឡើយទេ ពោលគឺ ទាមទារឲ្យមានការអប់រំជាចាំបាច់លើផ្នែកសីលធម៌ សុខភាពផ្លូវកាយ ក៏ដូចជាសុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋផងដែរ ព្រោះកត្តាទាំងនេះពិតជាមានសារសំខាន់យ៉ាងខ្លាំងក្នុងការជួយគាំទ្រការរីកលូតលាស់ និងភាពជោគជ័យរបស់មនុស្សជាតិ។ កាលណាប្រជាជនយើងប្រកបទៅដោយចំណេះដឹង ជំនាញ មានសីលធម៌ល្អ និងសុខភាពប្រពៃ នោះសង្គមជាតិនឹងពោរពេញទៅដោយធនធានមនុស្សពិតប្រាកដសម្រាប់បន្តកសាង និងអភិវឌ្ឍន៍សង្គមជាតិឲ្យមានការរីកចំរើនជានិរន្តរភាព។

ការអប់រំពិតជាមានសារសំខាន់ខ្លាំងណាស់សម្រាប់មនុស្សទូទៅ ពិសេសគឺជួយពន្លឿនដល់ការអភិវឌ្ឍប្រទេសជាតិ។ អាស្រ័យហេតុនេះហើយទើបប្រទេសគ្រប់ទម្រង់ទាំងអស់នៅលើពិភពលោកមិនថាជាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ក្តីតែងតែខិតខំកែសម្រួលប្រព័ន្ធសិក្សាធិការរបស់ខ្លួនឲ្យកាន់តែមានភាពប្រសើរជាងមុន។ តួយ៉ាងនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងផ្ទាល់ ឃើញថារដ្ឋាភិបាល និងក្រសួងអប់រំព្រមទាំងស្ថាប័នដែលពាក់ព័ន្ធទាំងអស់បានព្យាយាមសិក្សាពីបញ្ហាប្រឈម ធ្វើការតាមដានរាល់ប្រតិបត្តិការ និងស្វែងរកដំណោះស្រាយថ្មីៗជារៀងរាល់អាណត្តិសម្រាប់ដាក់ចេញជាផែនការយុទ្ធសាស្ត្រ ដើម្បីលើកស្ទួយវិស័យអប់រំនៅកម្ពុជា។

# ១. លំនាំបញ្ហា

កត្តាអប់រំជាកត្តាស្នូលមួយដែលចាំបាច់ណាស់សម្រាប់វឌ្ឍនភាពរបស់ប្រទេសនីមួយៗនៅលើសកលលោកយើងនេះ ហើយការអប់រំនេះទៀតសោតត្រូវមានការយកចិត្តទុកលើកុមារជាពិសេស តាមរយៈការបង្ហាត់បង្រៀន ហាត់ពត់លត់ដំ គឺធ្វើយ៉ាងណាឲ្យពួកគាត់មានគ្រឹះរឹងមាំតាំងពីកុមារភាព។ កុមារគ្រប់រូបមានសិទ្ធិទទួលបាននូវការអប់រំស្មើរៗគ្នាដោយពុំមានការរើសអើងជាតិសាសន៍ ពណ៌សម្បុរ ឬភេទឡើយ។

ការផ្តោតការអប់រំលើកុមារជាកាតព្វកិច្ចរបស់យើងគ្រប់គ្នាដែលជាអ្នកជំនាន់មុន ព្រោះវាសនារបស់ប្រទេសជាតិទាំងមូលត្រូវស្ថិតលើទំនួលខុសត្រូវរបស់ពួកគេទាំងស្រុងនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ជាក់ស្តែងសង្គមជាតិមួយអាចរីកចំរើនទៅមុខបានគឺត្រូវពឹងផ្អែកលើប្រជាពលរដ្ឋរបស់ខ្លួននេះហើយ ប្រសិនបើប្រជាពលរដ្ឋរបស់ខ្លួនពុំមានចំណេះដឹង និងសមត្ថភាពគ្រប់គ្រាន់ទេ នោះប្រាកដជាពុំអាចធ្វើការប្រកួតប្រជែងជាមួយបរទេសបានឡើយ។ ផ្ទុយមកវិញប្រសិនបើប្រជាពលរដ្ឋរបស់ប្រទេសនោះពោរពេញដោយចំណេះដឹង ជំនាញ និងមានក្រមសីលធម៌ល្អប្រពៃ នោះយើងនឹងមានលទ្ធភាពក្នុងការបង្កើនផលិតភាពផលិតផលដែលមានគុណភាពខ្ពស់ ដោយចំណាយពេលតិចជាងមុន និងចំណេញជាងមុន ហើយប្រាកដណាស់យើងនឹងមានលទ្ធភាពឈានជើងចូលប្រកួតប្រជែងក្នុងការដណ្តើមយកទីផ្សារអន្តរជាតិជាហេតុនាំឲ្យមានកំណើនសេដ្ឋកិច្ច ដែលជាសរសៃឈាមដ៏សំខាន់របស់ប្រទេសជាតិ និងឈានទៅដល់ការអភិវឌ្ឍលើគ្រប់វិស័យឲ្យដូចប្រទេសជឿនលឿនសព្វថ្ងៃនេះដែរ។ មួយវិញទៀតនៅពេលដែលប្រទេសរបស់យើងសម្បូរធនធានមនុស្សនោះនឹងទាក់ទាញដល់វិនិយោគិនឲ្យមកធ្វើការវិនិយោគនៅក្នុងប្រទេសឲ្យកាន់តែច្រើន នឹងផ្តល់នូវឱកាសការងារកាន់តែច្រើនដូចគ្នាសម្រាប់ប្រជាពលរដ្ឋយើង ដែលនឹងលើកស្ទួយជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិផងដែរ។ យ៉ាងណាមិញជាបឋមយើងត្រូវផ្តល់ឲ្យកុមារនូវការអប់រំមួយដែលត្រឹមត្រូវច្បាស់លាស់ និងត្រូវតែមានគុណភាពទើបអាចសម្រេចកិច្ចការដូចដែលបានរៀបរាប់ខាងលើនេះ។

សព្វថ្ងៃរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយវិស័យអប់រំនៅកម្ពុជាឲ្យមានភាពរីកលូតលាស់ និងប្រសើរជាងមុន។ ក្រៅពីនេះក៏មានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងគណៈគ្រប់គ្រងសាលាគ្រប់លំដាប់ថ្នាក់ក៏បានខិតខំខ្នែងបំពេញកាតព្វកិច្ច និងគោរពទៅតាមគោលការណ៍របស់រដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងទិសដៅជំរុញវិស័យអប់រំឲ្យមានភាពរីកចំរើន។ តួយ៉ាងសាលាបឋមសិក្សាវត្តបូព៌ជាសាលាមួយក្នុងចំណោមសាលាជាច្រើនទៀតដែលបានចូលរួមចំណែកក្នុងការពង្រឹង និងពង្រីកនូវគុណភាពអប់រំរបស់សិស្សានុសិស្ស។ អាស្រ័យហេតុនេះហើយទើបក្រុមយើងខ្ញុំបានសម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវទៅលើសកម្មភាពនៃការអប់រំរបស់សាលាបឋមសិក្សា

វត្តបូព៌ ក្នុងគោលបំណងសិក្សាស្វែងយល់ពីការដឹកនាំ និងការអប់រំនៅក្នុងសាលានេះ ពិសេសគឺមានចេតនាផ្សព្វផ្សាយឲ្យកាន់តែមានភាពទូលំទូលាយចំពោះសកម្មភាពដែលនាំឲ្យការអប់រំនៅទីនេះទទួលបានលទ្ធផលល្អប្រសើរ។

## ២. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ មានគោលបំណងដូចតទៅ៖

- សិក្សាស្វែងយល់អំពីការគ្រប់គ្រងលើសាលាបឋមសិក្សាវត្តបូព៌
- សិក្សាស្វែងយល់ពីសកម្មភាពអប់រំនៅក្នុងសាលាបឋមសិក្សាវត្តបូព៌
- ប្រើជាសេចក្តីថ្លែងការណ៍ពីភាពជោគជ័យនៃការអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌ដល់គណៈគ្រប់គ្រងសាលាដទៃទៀត អ្នកសិក្សាស្រាវជ្រាវគ្រប់រូប និងមហាជនទូទៅឲ្យបានជ្រាបច្បាស់ និងយកធ្វើជាគំរូក្នុងការកែលំអរការអប់រំនៅក្នុងសហគមន៍ ឬតំបន់របស់ខ្លួន ពិសេសគឺលើកស្ទួយវិស័យអប់រំឲ្យកាន់តែមានភាពប្រសើរឡើងជារៀងរហូត និងដើម្បីបន្តគាំទ្រដល់វឌ្ឍនភាពរបស់សង្គមជាតិ។

## ៣. ចំណោទបញ្ហា

ការផ្តល់នូវសេវាអប់រំដល់កុមារ មិនមែនជាការងាយស្រួលនោះទេ ហើយកាន់តែពិបាកទៅទៀតគឺនៅពេលដែលយើងចង់ផ្តល់នូវការអប់រំមួយដ៏មានគុណភាពដល់ពួកគេ។ ការអប់រំដែលមានគុណភាព គឺសំដៅលើការអប់រំទាំងផ្នែកចំណេះដឹង វិន័យ និងសីលធម៌។ ការអប់រំកុមារប្រកបដោយគុណភាពនេះទៀតសោតគឺចាំបាច់ណាស់ត្រូវមានការចូលរួមពីគ្រប់ផ្នែកដែលពាក់ព័ន្ធ ដូចជាមាតាបិតាសិស្ស គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សាសនា និងសហគមន៍។ ប្រសិនបើមានផ្នែកណាមួយដែលមិនមានការគាំទ្រនោះដំណើរការនៃការអប់រំក៏ពុំអាចទទួលបានជោគជ័យដែរ។ អាស្រ័យហេតុនេះហើយទើបក្រុមយើងខ្ញុំចង់សិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ និងចង់ទទួលបានបទពិសោធន៍អំពី៖

- តើមានកត្តាអ្វីខ្លះដែលជំរុញឲ្យការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ទទួលបាននូវប្រសិទ្ធភាព?

## ៤. សារសំខាន់នៃការស្រាវជ្រាវ

ការអប់រំពិតជាកត្តាមួយសំខាន់ណាស់សម្រាប់គ្រប់ជាតិសាសន៍នៅលើសកលលោកយើងនេះ បើពុំមានការអប់រំមួយដែលត្រឹមត្រូវ និងមានគុណភាពទេ នោះកត្តាផ្សេងៗទៀតនៅក្នុងសង្គម និងសេដ្ឋកិច្ចក៏ពុំអាចដំណើរការទៅមុខបានល្អដែរ។ អាស្រ័យហេតុនេះហើយទើបក្រុមយើងខ្ញុំបានធ្វើការខិតខំស្រាវជ្រាវលើ

ប្រធានបទមួយដែលលើកឡើងអំពី ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ ដោយមានការសង្ឃឹមយ៉ាងមុតមាំថាការសិក្សាស្រាវជ្រាវមួយនេះនឹងបានផ្តល់ជាប្រយោជន៍ដល់៖

- ខ្លួនឯងផ្ទាល់ ដែលទទួលបានបទពិសោធន៍ក្នុងការធ្វើទំនាក់ទំនងជាផ្លូវការនៅក្នុងសង្គម ដូចជាការធ្វើទំនាក់ទំនងជាមួយលោកចៅសង្កាត់សាលាកំរើក លោកគ្រូអ្នកគ្រូ សិស្សនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ និងការជួបសម្ភាសន៍ផ្ទាល់ជាមួយប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ។ លើសពីនេះទៅទៀតយើងខ្ញុំក៏បានទទួលនូវចំណេះដឹងថ្មីៗ និងការអនុវត្តជាក់ស្តែងបន្ទាប់ពីបានសិក្សាទៅលើផ្នែកទ្រឹស្តីនៅក្នុងសាលា ដូចជា ការអភិវឌ្ឍសាលា ការដឹកនាំគ្រប់គ្រង និងសកម្មភាពនៃការអប់រំមួយប្រកបដោយគុណភាពដែលអាចធ្វើឲ្យមហាជនទូទៅទាំងជាតិ និងអន្តរជាតិមានការចាប់អារម្មណ៍ជាខ្លាំងលើការអប់រំនៅក្នុងសាលានេះផងដែរ។
- អ្នកសិក្សាស្រាវជ្រាវគ្រប់រូបដែលមានបំណងចង់សិក្សាស្រាវជ្រាវ និងស្វែងយល់ពីបញ្ហាដូចគ្នានេះដោយអាចយកធ្វើជាមូលដ្ឋានគ្រឹះក្នុងការស្រាវជ្រាវ និងពង្រីកវិសាលភាពទៅលើការស្រាវជ្រាវរបស់ពួកគេ ពោលគឺការចេះប្រើប្រាស់នូវធនធានដែលមានស្រាប់ និងបង្កើតគំនិតច្នៃប្រឌិតថ្មី ឬការរកបាននូវដំណោះស្រាយថ្មី ដែលនាំទៅរកលទ្ធផលថ្មីមួយទៀតដែលមានប្រសិទ្ធភាពជាង។
- គណៈគ្រប់គ្រងសាលាគ្រប់រូប ក្នុងការសិក្សាអំពីបញ្ហាប្រឈមនានា និងដំណោះស្រាយរាល់បញ្ហាប្រឈមទាំងនោះ ដើម្បីយកធ្វើជាលំនាំ ក៏ដូចជាគំរូក្នុងការកែសម្រួលដំណើរការអប់រំក្នុងតំបន់របស់ខ្លួនឲ្យឈានទៅរកការអប់រំមួយប្រកបដោយប្រសិទ្ធភាព និងគុណភាព។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការសិក្សាអត្ថបទនេះ នឹងផ្តោតលើប្រសិទ្ធភាពនៃការអប់រំនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ ដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់មត្តេយ្យសិក្សា ដល់ថ្នាក់ទី៦។ ចំណែកដែនកំណត់នៃអត្ថបទនេះវិញ គឺផ្តោតសំខាន់លើការដឹកនាំគ្រប់គ្រង សកម្មភាពអប់រំប្រកបដោយគុណភាពនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ ដែលមានទីតាំងនៅក្នុងភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងបានប្រើប្រាស់ទិន្នន័យសាលាមួយចំនួនដែលនៅចន្លោះឆ្នាំ២០១៥ ដល់២០១៩។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការស្រាវជ្រាវលើ "ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌" យើងប្រើវិធីសាស្ត្រពិពណ៌នាប្រៀបធៀប ដើម្បីស្វែងរកចំណុចខ្លាំង និងចំណុចដែលខ្វះចន្លោះនៃសកម្មភាពអប់រំរបស់សាលា

បឋមសិក្សាវត្តបូព៌។ ដូចនេះដើម្បីប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹងការអប់រំ យើងបានធ្វើការចុះកម្មសិក្សានៅសាលាបឋមសិក្សាវត្តបូព៌ ចាប់ពីថ្ងៃទី១៩ ខែមេសា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។

ការប្រមូលទិន្នន័យចែកចេញជាពីរករណីគឺ៖

**៦.១ ទិន្នន័យដំបូង (Primary Data) :** នៅក្នុងទិន្នន័យដំបូង ឬបឋម គឺយើងប្រើប្រាស់ទិន្នន័យបែបគុណវិស័យ ដែលបានមកតាមរយៈការសម្ភាសន៍មហាជនដែលមានសំណាកគំរូ៩៧នាក់។

- ការអង្កេតលើស្ថានភាពអប់រំជាក់ស្តែង ព្រមទាំងសាកសួរព័ត៌មានមួយចំនួនពីលោកគ្រូ អ្នកគ្រូ សិស្ស មាតាបិតា ឬអាណាព្យាបាលសិស្ស និងប្រជាជនដែលរស់នៅក្នុងតំបន់ក្បែរសាលាចំពោះសកម្មភាពអប់រំនៅសាលាបឋមសិក្សាវត្តបូព៌។
- ទិន្នន័យបានមកពីការសាកសួរលោកនាយកសាលា ដើម្បីទទួលបាននូវព័ត៌មានទាក់ទងនឹងសកម្មភាពអប់រំនៅទីនេះ យកមកសរសេរជារបាយការណ៍។

**៦.២ ទិន្នន័យទី២ (Secondary Data) :** ជាទិន្នន័យដែលបានរៀបចំរួចជាស្រេច រួមមានទិន្នន័យផ្ទៃក្នុង និងទិន្នន័យខាងក្រៅ។

- ការស្វែងរកឯកសារ ឬការដកយកប្រភេទទ្រឹស្តីនានាដែលទាក់ទងនឹងប្រធានបទ ដែលមានប្រភពដូចជា លំនាំឯកសារ និងរបាយការណ៍កម្មសិក្សានៅបណ្ណាល័យ និងព័ត៌មានផ្សេងៗដែលបានមកពីអ៊ីនធឺណែត។
- ឯកសារសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ និងឯកសារដែលផ្តល់ដោយផ្ទាល់ពីសាលាបឋមសិក្សាវត្តបូព៌។

ទំនាក់ទំនងទិន្នន័យដែលប្រមូលបាន និងបញ្ហា:

រាល់ទិន្នន័យដែលយើងប្រមូលបាន ទាំងទិន្នន័យបឋម និងទិន្នន័យទី២ អាចឲ្យយើងស្វែងរកចំណុចខ្លាំង ចំណុចខ្វះចន្លោះ ព្រមទាំងទទួលបានព័ត៌មានដែលផ្តល់ត្រឡប់ពីមហាជនចំពោះសកម្មភាពអប់រំនៅសាលាបឋមសិក្សាវត្តបូព៌ជាក់ស្តែង។ ចំណុចទាំងអស់នេះហើយជាគោលដៅនៃការស្រាវជ្រាវរបស់យើង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវក្រោមប្រធានបទ "ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌" បានបែងចែកចេញជា៣ជំពូកធំៗគឺ៖

- នៅក្នុងជំពូកទី១ ៖

- មានការលើកយកនូវនិយមន័យនៃការអប់រំដែលយោងតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ បានឲ្យនិយមន័យការអប់រំថាជាការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈ ផ្តល់នូវចំណេះដឹង និងជំនាញពិតប្រាកដដើម្បីក្លាយជាធនធានមនុស្ស។ មានការរំលឹកទស្សនៈរបស់លោក Prof. H. Mahmud Yunus អំពីការផ្តល់ជាគម្រូល្អ និងសម្របសម្រួលដល់ការវិវត្តន៍គ្រប់ផ្នែករបស់កុមារ ដើម្បីជួយឲ្យពួកគេជោគជ័យនាពេលអនាគត។
- ទ្រឹស្តីជុំវិញការអប់រំមានដូចជា ទ្រឹស្តីកំណើន Solow ដែលបង្ហាញពីទំនាក់ទំនងរវាងការអប់រំ និងកម្លាំងពលកម្មដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ច។ ទ្រឹស្តីរបស់លោក Edmund Phelps ដែលបង្ហាញពីការអប់រំដែលជំរុញឲ្យមានភាពជោគជ័យលើផ្នែកបច្ចេកវិទ្យានាំឲ្យមានកំណើនសេដ្ឋកិច្ច។
- លើកបង្ហាញពីការអប់រំនៅក្នុងប្រទេសដែលមានការអប់រំល្អក្នុងតំបន់អាស៊ានដូចជា ប្រទេសជប៉ុន ប្រទេសថៃ និងប្រទេសសិង្ហបុរី។

- នៅក្នុងជំពូកទី២ បានលើកឡើងពីប្រវត្តិនៃការអប់រំក្នុងប្រទេសកម្ពុជាកាលពីមុនសម័យអាណានិគមបារាំង សម័យអាណានិគមបារាំង ប្រព័ន្ធអប់រំនៅចន្លោះឆ្នាំ (១៩៥០ ដល់ ១៩៦០) សម័យសាធារណរដ្ឋខ្មែរ សម័យកម្ពុជាប្រជាធិបតេយ្យ សម័យសាធារណរដ្ឋប្រជាមានិតក្យកម្ពុជា និងសម័យព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣ ដល់ បច្ចុប្បន្ន) ដើម្បីឆ្លុះបញ្ចាំងពីការវិវត្តន៍ប្រព័ន្ធអប់រំទៅតាមសម័យកាលនីមួយៗ។
- នៅក្នុងជំពូកទី៣ យើងធ្វើការលើកបង្ហាញពីការដឹកនាំគ្រប់គ្រង សកម្មភាពអប់រំនៅក្នុងសាលាបឋមសិក្សាវត្តបូព៌ និងបានលើកបង្ហាញពីចំណុចខ្លាំង ចំណុចខ្វះចន្លោះ ព្រមទាំងព័ត៌មានដែលផ្តល់ត្រឡប់ពីមហាជនចំពោះសកម្មភាពអប់រំនៅក្នុងសាលា និងបានផ្តល់ជាអនុសាសន៍មួយចំនួនសម្រាប់សាលាធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីឲ្យយល់ពីបញ្ហាស្នូល រួចដាក់ចេញនូវគោលការណ៍ដែលនឹងអាចមានលទ្ធភាពឆ្លើយតបទៅនឹងចំណុចខ្វះចន្លោះរបស់សាលា នឹងជំរុញឲ្យកាន់តែមានភាពប្រសើរឡើងថែមទៀតនូវភាពខ្លាំងរបស់សាលាក្នុងផ្នែកអនុសាសន៍ និងសេចក្តីសន្និដ្ឋាន។

# ជំពូកទី១
# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ

## ១.១ និយមន័យអប់រំ

យោងតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ នៃច្បាប់ស្តីពីការអប់រំបានឲ្យនិយមន័យការអប់រំ ថាជាកិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឲ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។[1]

ការអប់រំ សំដៅដល់កិច្ចខិតខំប្រឹងប្រែងក្នុងការលើកបង្ហាញសកម្មភាពល្អៗជាគំរូដល់កុមារ ព្រមទាំងការសម្របសម្រួលពួកគេចំពោះការវិវត្តន៍ផ្នែកចំណេះដឹង រាងកាយ និងឥរិយាបថ ដែលជាប្រយោជន៍ចំពោះការសម្រេចគោលដៅរបស់ពួកគេប្រកបដោយជោគជ័យ។[2]

## ១.២ ទ្រឹស្តីពាក់ព័ន្ធ

### ១.២.១ ទ្រឹស្តីពួកនេអូក្លាសិក (Neoclassical Theory)

តាមទ្រឹស្តីកំណើន Solow (1956) របស់ពួកនេអូក្លាសិកបានថែងថា ការអប់រំអាចបង្កើតធនធានមនុស្សរួមជាមួយកម្លាំងពលកម្មដែលបានបង្កើតឲ្យមានផលិតភាព និងនាំឲ្យមានកំណើន។ ក្នុងនោះដែរមានទ្រឹស្តីនេះបានបញ្ជាក់ថាសេដ្ឋកិច្ចវិទូអាចសម្រេចនូវកំណើនសេដ្ឋកិច្ចរយៈពេលវែងតាមរយៈការរីកចម្រើនពីប្រព័ន្ធសេដ្ឋកិច្ចក្រៅ។[3]

### ១.២.២ ទ្រឹស្តីអ្នកម៉ាក្សអ៊ែតមុនហ្វ៊ែរ (Edmund Phelps)

លោកអ៊ែតមុនហ្វ៊ែរ ជាសេដ្ឋកិច្ចវិទូរបស់សហរដ្ឋអាមេរិច ហើយលោកបានធ្លាប់ឈ្នះពានរង្វាន់ណូប៊ែលខាងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ គាត់បានឲ្យទ្រឹស្តីនៃការអប់រំ អាចជំរុញឲ្យមានកំណើន និងផ្ទេរចំណេះដឹងដើម្បីទទួលពត៌មាន ដែលនាំឲ្យជោគជ័យលើផ្នែកបច្ចេកវិទ្យាដែលបានបង្កើតឡើងដែលជួយកំណើនសេដ្ឋកិច្ច។[4]

---

[1] ច្បាប់ស្តីពីការអប់រំ មាត្រា៤ ជំពូកទី១ ទំព័រទី២ ឆ្នាំ២០០៧

[2] ទស្សនៈរបស់លោក Prof. H. Mahmud Yunus

[3] Antoneitta Campus (1987), "marginal economics", *The New Palgrave: A Dictionary of Economics*, v.3, p. 323.

[4] International Encyclopedia of Education-Education and Economic Growth (2010) vol.2 ទំព័រ ២៤៥

## ១.៣ ករណីសិក្សាប្រទេសដែលមានប្រព័ន្ធអប់រំល្អ

### ១.៣.១ ការអប់រំនៅប្រទេសជប៉ុន[5]

ប្រជាជនជប៉ុនមានបំណងចង់អភិវឌ្ឍបន្ថែមទៀតនូវរដ្ឋប្រជាធិបតេយ្យ និងវប្បធម៌ដែលបានកសាងតាមរយៈការខិតខំដោយមិនចេះនឿយហត់ ហើយក៏សង្ឃឹមថានឹងរួមចំណែកដល់សន្តិភាពពិភពលោក និងដើម្បីលើកកម្ពស់សុខុមាលភាពមនុស្សជាតិហើយការអភិវឌ្ឍក៏ត្រូវតែសមស្របជាមួយវប្បធម៌របស់ជនជាតិជប៉ុន។ ការអនុវត្តច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញនៃប្រទេសជប៉ុនដើម្បីបង្កើតមូលដ្ឋានគ្រឹះនៃការអប់រំ និងលើកកម្ពស់ការអប់រំដែលបើកផ្លូវឆ្ពោះទៅអនាគតរបស់ប្រទេស។

#### ១.៣.១.១ គោលបំណង និងគោលការណ៍នៃការអប់រំ

ដើម្បីសំរេចនូវគោលបំណងដែលបានរៀបរាប់ខាងលើនេះ ការអប់រំរបស់ប្រទេសជប៉ុនត្រូវបានផ្តល់ជូនដោយពុំមានការរើសអើង ៖

១. ឲ្យសិស្សទទួលបានចំណេះដឹង និងវប្បធម៌ទូលំទូលាយ ជំរុញឲ្យតម្លៃនៃការស្វែងរកការពិត ការបណ្តុះបណ្តាលនូវភាពវាងវៃ ការយល់ដឹងខាងសីលធម៌ និងការកសាងសុខភាពរបស់រាងកាយ។

២. ការអភិវឌ្ឍសមត្ថភាពរបស់បុគ្គល ការបណ្តុះគំនិតច្នៃប្រឌិត ជំរុញស្មារតីស្វ័យភាព ឯករាជ្យភាព ដោយគោរពតម្លៃបុគ្គល ព្រមទាំងផ្តោតសំខាន់លើទំនាក់ទំនងរវាងអាជីព និងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ ពិសេសគឺឲ្យតម្លៃចំពោះការខិតខំប្រឹងប្រែង។

៣. លើកកម្ពស់គុណតម្លៃនៃការគោរពយុត្តិធម៌ ការទទួលខុសត្រូវ សមភាពរវាងបុរស និងស្ត្រី ការគោរព និងធ្វើកិច្ចសហប្រតិបត្តិការទៅវិញទៅមក ក៏ដូចជាការចូលរួមយ៉ាងសកម្មក្នុងការកសាងសង្គម ការរួមចំណែកដល់ការអភិវឌ្ឍរបស់ខ្លួនក្នុងស្មារតីសាធារណៈ។

៤. ការលើកកម្ពស់គុណតម្លៃជីវិត ការយកចិត្តទុកដាក់ចំពោះធម្មជាតិ និងការចូលរួមចំណែកក្នុងការថែរក្សាបរិស្ថាន។

៥. លើកកម្ពស់គុណតម្លៃនៃការគោរពប្រពៃណី វប្បធម៌ សេចក្តីស្រឡាញ់ចំពោះប្រទេសកំណើត ក៏ដូចជាតម្លៃនៃការគោរពចំពោះប្រទេសដទៃទៀត ការចូលរួមចំណែកដល់សន្តិភាពពិភពលោក ព្រមទាំងការអភិវឌ្ឍសហគមន៍អន្តរជាតិ។

##### ក. គំនិតនៃការរៀនសូត្រពេញមួយជីវិត

សង្គមបានគាំទ្រចំពោះការរៀនសូត្រពេញមួយជីវិតរបស់ប្រជាជន និងគ្រប់ទីកន្លែងគឺពួកគេអាចអនុវត្តបាននូវលទ្ធផលនៃការរៀនសូត្រពេញមួយជីវិតរបស់ពួកគេ ដើម្បីធ្វើឱ្យខ្លួនគេស្រស់បំព្រង និងដឹកនាំ

[5] https://www.mext.go.jp/en/

ជីវិតដែលទៅរកគោលដៅដែលគេចង់បាន។

**ខ. ឱកាសស្មើគ្នាក្នុងការអប់រំ**

ប្រជាជនត្រូវតែទទួលបានឱកាសស្មើគ្នាក្នុងការទទួលបានការអប់រំសមស្របតាមសមត្ថភាពរបស់ពួកគេ ហើយមិនត្រូវទទួលរងនូវការរើសអើងនៅក្នុងការអប់រំទាក់ទងនឹងពូជសាសន៍ ជំនឿសាសនា ស្ថានភាពសង្គម ស្ថានភាពសេដ្ឋកិច្ច ឬដើមកំណើតនៃគ្រួសារឡើយ។

១. រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវផ្តល់ការគាំទ្រផ្នែកអប់រំចាំបាច់ដើម្បីធានាថាជនពិការទទួលបានការអប់រំគ្រប់គ្រាន់ស្របតាមកម្រិតពិការភាពរបស់ពួកគេ។

២. រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវចាត់វិធានការដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុដល់អ្នកដែលជួបប្រទះការលំបាកក្នុងការទទួលការអប់រំដោយសារហេតុផលសេដ្ឋកិច្ច។

**១.៣.១.២ មូលដ្ឋានគ្រឹះទាក់ទងនឹងការផ្តល់ការអប់រំ**

**ក. វិស័យអប់រំជាកាតព្វកិច្ច**

ប្រជាជនត្រូវមានកាតព្វកិច្ចឱ្យកុមារដែលស្ថិតនៅក្រោមការការពាររបស់ពួកគេទទួលបានការអប់រំទូទៅស្របតាមបទបញ្ញារបស់សាលា ។

១. ការអប់រំទូទៅដែលត្រូវបានផ្តល់ជាទំរង់នៃការអប់រំជាកាតព្វកិច្ច ដែលបណ្តុះមូលដ្ឋានគ្រឹះសម្រាប់ជីវិតឯករាជ្យនៅក្នុងសង្គមខណៈពេលកំពុងអភិវឌ្ឍសមត្ថភាពរបស់បុគ្គលម្នាក់ៗ និងមានគោលបំណងជំរុញគុណសម្បត្តិជាមូលដ្ឋាននៃជីវិតផង ដែលចាំបាច់សម្រាប់ប្រជាជនដែលបង្កើតប្រទេស និងសង្គម។

២. ដើម្បីធានានូវឱកាសសម្រាប់ការអប់រំជាកំហិត និងធានានូវស្តង់ដារគ្រប់គ្រាន់ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវទទួលខុសត្រូវក្នុងការអនុវត្តការអប់រំជាកាតព្វកិច្ចតាមរយៈការចែករំលែកតួនាទីសមស្រប និងកិច្ចសហប្រតិបត្តិការទៅវិញទៅមក។

៣. មិនមានការបង់ថ្លៃសិក្សាណាមួយសម្រាប់ការអប់រំជាកាតព្វកិច្ចនៅក្នុងសាលារៀនដែលបង្កើតឡើងដោយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានឡើយ។

**ខ. ការអប់រំនៅសាលា**

សាលារៀនមួយអាចបង្កើតបានលុះត្រាតែគោរពទៅតាមច្បាប់របស់រដ្ឋាភិបាល។

១. ដើម្បីសំរេចគោលបំណងនៃការអប់រំដែលបានលើកឡើងនៅក្នុងកថាខណ្ឌមុន គឺត្រូវផ្តល់ការអប់រំដែលមានលក្ខណៈជារចនាសម្ព័ន្ធ ដែលសមស្របទៅនឹងការអភិវឌ្ឍផ្លូវចិត្ត និងរាងកាយរបស់មនុស្សដែលទទួលការអប់រំនោះ។ ក្នុងន័យនេះការអប់រំត្រូវតែបានផ្តល់ជូនតាមរបៀបមួយដែលគោរពវិន័យជាចាំបាច់ ដើម្បី

គ្រប់គ្រង និងអភិវឌ្ឍសាលារៀន សម្រាប់ជាប្រយោជន៍ដល់មនុស្សដែលទទួលបានការអប់រំនោះ ព្រមទាំងពង្រឹងលើការលើកទឹកចិត្តពួកគេក្នុងការរៀនសូត្រសម្រាប់រយៈពេលយូរអង្វែង។

**គ. សាកលវិទ្យាល័យ**

សាកលវិទ្យាល័យដែលជាស្នូលនៃសកម្មភាពរបស់អ្នកអប់រំ គឺចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមតាមរយៈការបណ្តុះបណ្តាលចំណេះដឹង និងជំនាញឯកទេសស្រាវជ្រាវឲ្យបានស៊ីជម្រៅទៅរកការពិតដើម្បីបង្កើតចំណេះដឹងថ្មីៗ និងផ្តល់ផ្លែផ្កាយ៉ាងទូលំទូលាយដល់ការខិតខំទាំងនេះដល់សង្គម។"**ស្វ័យភាពសាកលវិទ្យាល័យ លក្ខណៈពិសេសដទៃទៀតនៃការអប់រំ និងការស្រាវជ្រាវនៅសាកលវិទ្យាល័យត្រូវតែគោរព**" ។

**ឃ. សាលាឯកជន**

ដោយពិចារណាលើលក្ខណៈជាសាធារណៈនៃសាលារៀនដែលបានបង្កើតឡើងជាលក្ខណៈឯកជនក៏មានតួនាទីសំខាន់ក្នុងការអប់រំផងដែរ។ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននឹងខិតខំជំរុញការអប់រំនៅតាមសាលារៀនឯកជនតាមរយៈការឧបត្ថម្ភធន និងមធ្យោបាយសមស្របដទៃទៀតខណៈពេលដែលពួកគេគោរពស្វ័យភាពសាលា។

**ង. គ្រូបង្រៀន**

គ្រូបង្រៀនត្រូវខិតខំបំពេញភារកិច្ច និងបន្តធ្វើការស្រាវជ្រាវដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួន។

១. ដោយពិចារណាលើគុណតម្លៃនៃគ្រូ និងភារកិច្ចរបស់គ្រូដែលបានលើកឡើងនៅក្នុងកថាខណ្ឌខាងលើនេះឋានៈរបស់គ្រូត្រូវតែបានគោរព ការធានាឱ្យបានត្រឹមត្រូវ និងសមរម្យ ត្រូវចាត់វិធានការដើម្បីលើកកម្ពស់ការអប់រំ និងការបណ្តុះបណ្តាល ។

**ច. ការអប់រំនៅក្នុងគ្រួសារ**

ឪពុកម្តាយ ឬអាណាព្យាបាលមានការទទួលខុសត្រូវជាចំបងចំពោះការអប់រំកូនៗរបស់ពួកគេដោយខិតខំបង្រៀនកូនៗនូវទម្លាប់ចាំបាច់សម្រាប់ជីវិត លើកទឹកចិត្ត ផ្តល់នូវឯករាជ្យភាព ចិញ្ចឹមបីបាច់ និងយកចិត្តទុកចំពោះការអភិវឌ្ឍរាងកាយ និងចិត្តគំនិត។

១. រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវខិតខំចាត់វិធានការចាំបាច់សម្រាប់គាំទ្រដល់ការអប់រំក្នុងគ្រួសារដូចជាផ្តល់នូវសេវាបណ្តុះបណ្តាលអាណាព្យាបាលគ្រប់រូបឲ្យយល់ដឹងពីការចិញ្ចឹមកូន និងទទួលបានព័ត៌មានទាក់ទងនឹងការសិក្សារបស់កូនៗ។

**ឆ. ការអប់រំកុមារតូច**

ដោយពិចារណាលើសារៈសំខាន់នៃការអប់រំកុមារតូចដែលជាមូលដ្ឋានសម្រាប់ការបង្កើតចរិត

លក្ខណៈរបស់មនុស្សម្នាក់ៗ រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានបានខិតខំលើកកម្ពស់ការអប់រំបែបនេះ ដោយផ្តល់នូវបរិយាកាសអំណោយផលដល់ការលូតលាស់ប្រកបដោយសុខភាពរបស់កុមារនិង មធ្យោបាយសមស្របផ្សេងទៀត។

**ជ. ការអប់រំសង្គម**

រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវជំរុញការអប់រំដែលកើតឡើងនៅក្នុងសហគមន៍ និងសង្គមដើម្បីឆ្លើយតបទៅនឹងការទាមទាររបស់បុគ្គល សហគមន៍ និងសង្គមទាំងមូល។

១. រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវខិតខំលើកកម្ពស់ការអប់រំសង្គមតាមរយៈការបង្កើតបណ្ណាល័យ សារមន្ទីរ សាលសហគមន៍ និងកន្លែងផ្សេងៗទៀតសម្រាប់ការអប់រំសង្គមដោយប្រើប្រាស់សម្ភារៈសិក្សា ផ្តល់ឱកាសរៀនសូត្រ ព័ត៌មានពាក់ព័ន្ធនឹងការអប់រំ និងមធ្យោបាយសមស្របផ្សេងទៀត។

**ឈ. ភាពជាដៃគូ និងការសហការណ៍រវាងសាលារៀន គ្រួសារ និងអ្នកនៅក្នុងមូលដ្ឋាន**

សាលារៀន ក្រុមគ្រួសារ អ្នករស់នៅក្នុងមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀតត្រូវរក្សាការយល់ដឹងអំពីតួនាទី និងទំនួលខុសត្រូវរៀងៗខ្លួនទាក់ទងនឹងការអប់រំ ក៏ដូចជាការព្យាយាមអភិវឌ្ឍភាពជាដៃគូ និងធ្វើការសហការណ៍យ៉ាងជិតស្និទ្ធជាមួយគ្នា។

**ញ. ការអប់រំនយោបាយ**

ប្រជាជនគ្រប់រូបត្រូវយល់ដឹងពីនយោបាយក្នុងប្រទេសរបស់ខ្លួន ពោលគឺសាលារៀនត្រូវមានការអប់រំផ្នែកនយោបាយ ដើម្បីជួយឲ្យពួកគេមានការសម្រេចចិត្តបានត្រឹមត្រូវចំពោះការគាំទ្រនយោបាយជាក់លាក់ណាមួយ និងសកម្មភាពនយោបាយដទៃទៀត។

**ដ. ការអប់រំអំពីសាសនា**

ការអត់ឱនខាងសាសនា ចំណេះដឹងទូទៅអំពីសាសនា និងជំហរសាសនានៅក្នុងជីវិតសង្គមត្រូវតែមានតម្លៃចំពោះការអប់រំ។

១. សាលារៀនដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវជៀសវាងពីការរើសអើងខាងសាសនា ដោយមានសាសនាជាក់លាក់ ប៉ុន្តែមិនមានការហាមឃាត់សកម្មភាពរបស់សាសនាដទៃទៀត។

### ១.៣.១.៣ រដ្ឋបាលអប់រំ

**ក. រដ្ឋបាលគ្រប់គ្រងការអប់រំ**

ការអប់រំមិនត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដែលមិនត្រឹមត្រូវឡើយ ហើយត្រូវផ្តល់ឱ្យស្របតាមច្បាប់

នៃការអប់រំ និងសកម្មភាពផ្សេងទៀតរបស់រដ្ឋាភិបាល។ រដ្ឋបាលអប់រំត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមរយៈការបែងចែកតួនាទី និងកិច្ចសហប្រតិបត្តិការដែលសមស្របរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

១. រដ្ឋាភិបាលថ្នាក់ជាតិត្រូវបង្កើត និងអនុវត្តវិធានការអប់រំឲ្យបានទូលំទូលាយ ដើម្បីផ្តល់ឱកាសស្មើគ្នាក្នុងការអប់រំ ពង្រឹង និងពង្រីកស្តង់ដារអប់រំនៅទូទាំងប្រទេស។

២. រដ្ឋាភិបាលមូលដ្ឋានត្រូវបង្កើត និងអនុវត្តវិធានការអប់រំដែលត្រូវនឹងស្ថានភាពក្នុងតំបន់ ដើម្បីលើកកម្ពស់ការអប់រំនៅក្នុងតំបន់របស់ពួកគេ។

៣. រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានត្រូវចាត់វិធានការណ៍ចាំបាច់ ដើម្បីធានាថាការអប់រំត្រូវបានផ្តល់ដោយរលូន និងជាបន្តបន្ទាប់។

### ខ. ផែនការមូលដ្ឋានសម្រាប់ការលើកកម្ពស់ការអប់រំ

ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយឲ្យបានទូលំទូលាយ និងមានលក្ខណៈជាប្រព័ន្ធដែលលើកកម្ពស់ការអប់រំ រដ្ឋាភិបាលត្រូវរៀបចំផែនការលម្អិតជាច្រើនទៀតដោយផ្អែកលើផែនការគោល រួចត្រូវអនុវត្តជាចាំបាច់ចំពោះគោលការណ៍ដែលបានដាក់ចេញ និងព្យាយាមដោះស្រាយរាល់បញ្ហាប្រឈមនានា។

១. រដ្ឋាភិបាលមូលដ្ឋានត្រូវពិគ្រោះលើផែនការដែលមានចែងក្នុងកថាខណ្ឌមុន និងខិតខំបង្កើតផែនការមូលដ្ឋានដែលត្រូវនឹងស្ថានភាពក្នុងតំបន់សម្រាប់គោលនយោបាយលើកកម្ពស់ការអប់រំ។

### គ. ការអនុម័តច្បាប់ និងបទប្បញ្ញត្តិ

ច្បាប់ និងបទប្បញ្ញត្តិចាំបាច់សម្រាប់អនុវត្តបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះត្រូវតែបានអនុម័តផ្អែកផែនការ និងសម្របសម្រួលគោលនយោបាយ សិក្សាពេញមួយជីវិត។

## ១.៣.២ ការអប់រំនៅប្រទេសថៃ[6]

### ១.៣.២.១ ប្រពន្ធ័អប់រំនៅប្រទេសថៃ

ក្រសួងអប់រំ គឺជាទីភ្នាក់ងារចំបងដែលទទួលខុសត្រូវក្នុងការលើកកម្ពស់ និងត្រួតពិនិត្យ។ ការផ្តល់នូវការអប់រំគ្រប់កម្រិត និងគ្រប់រូបភាពដែលមានទាំងចំណេះដឹងទូទៅ និងការអប់រំវិជ្ជាជីវៈ។ ការអប់រំជាផ្លូវការចែកចេញជាពីរកម្រិត គឺការអប់រំមូលដ្ឋាន និងឧត្តមសិក្សា។ រីឯការអប់រំជាមូលដ្ឋាននៅប្រទេសថៃសំដៅទៅលើការអប់រំបឋមសិក្សារយៈពេល ៦ ឆ្នាំ (G1-G6) រយៈពេល ៣ ឆ្នាំសម្រាប់អនុវិទ្យាល័យ (G7-G9) និងមធ្យមសិក្សាទុតិយភូមិរយៈពេល ៣ ឆ្នាំ (G10-G12) ។ ដូច្នេះប្រព័ន្ធអប់រំរបស់ថៃបានផ្តល់ការអប់រំមូលដ្ឋានឥតគិតថ្លៃរយៈពេល ១២ ឆ្នាំ។ ការអប់រំវិជ្ជាជីវៈត្រូវបានផ្តល់ជាបីថ្នាក់គឺ កម្រិតក្រោយអនុវិទ្យាល័យដែល

[6] http://www.en.moe.go.th/enMoe2017/

ទទួលបានវិញ្ញាបនប័ត្រវិជ្ជាជីវៈកម្រិតទាប កម្រិតមធ្យមសិក្សាទុតិយភូមិដែលនាំឱ្យទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈកម្រិតខ្ពស់ និងការអប់រំវិជ្ជាជីវៈកម្រិតឧត្តមនាំឱ្យទទួលបានបរិញ្ញាបត្រ។

### ១.៣.២.២ យុទ្ធសាស្ត្រ និងគោលនយោបាយអប់រំថ្នាក់ជាតិរបស់ប្រទេសថៃ

យុទ្ធសាស្ត្រជាតិរយៈពេល ២០ ឆ្នាំមាន ៦ ចំណុចផ្តោតសំខាន់លើវិស័យអប់រំ ដូចជាការពង្រឹងសមត្ថភាព ប្រកួតប្រជែង ការអភិវឌ្ឍធនធានមនុស្ស សង្គមមានសមភាព កំណើនបៃតង និងការធ្វើឱ្យមានតុល្យភាពឡើងវិញនូវការអភិវឌ្ឍវិស័យសាធារណៈ។ ក្រសួងអប់រំបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រព្រមទាំងបានអនុវត្តគម្រោងមានដូចខាងក្រោម៖

១. ការលើកកម្ពស់សន្តិភាព និងសន្តិសុខ: ដើម្បីលើកកម្ពស់សន្តិសុខ និងសន្តិភាពក្រសួងត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការលើកកម្ពស់សីលធម៌។ ក្រមសីលធម៌ និងអភិបាលកិច្ចនៅតាមសាលារៀនផ្តល់ការគាំទ្រពិសេសដល់ការផ្តល់ការអប់រំនៅក្នុងខេត្តចំនួន ៥ នៅភាគខាងត្បូងដែលធានានូវឱកាសអប់រំស្មើៗគ្នាសម្រាប់ពលរដ្ឋថៃ និងមិនមែនជាជនជាតិថៃ រួមទាំងកុមារ និងកុមារគ្មានទីលំនៅរបស់ជនចំណាកស្រុក និងជនជាតិភាគតិច។ ល។

២. ការលើកកម្ពស់សមត្ថភាពប្រកួតប្រជែងថ្នាក់ជាតិ: ក្រសួងបានផ្តួចផ្តើម និងអនុវត្តគម្រោងជាច្រើនដើម្បីលើកកម្ពស់ការប្រកួតប្រជែងរបស់ប្រទេសថៃ។ គំនិតផ្តួចផ្តើមទាំងនេះរួមមានការរៀបចំជំរុំក្នុងការប្រកួតប្រជែងសម្រាប់សិស្សភាសាអង់គ្លេស និងគ្រូភាសាអង់គ្លេសនៅតាមគ្រឹះស្ថានអប់រំមូលដ្ឋាន ការលើកកម្ពស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា (STEM) ការអប់រំនៅក្នុងស្ថាប័នអប់រំមូលដ្ឋាន ការលើកកម្ពស់ការអនុវត្តល្អបំផុត ឧត្តមភាពក្នុងការអប់រំវិជ្ជាជីវៈ និងស្ថាប័នបណ្តុះបណ្តាល ក៏ដូចជាការជំរុញការរៀនសូត្រដែលរួមបញ្ចូលការងារ (WIL= work-integrated learning) នៅក្នុងស្ថាប័នឧត្តមសិក្សា។ល។

៣. ការអភិវឌ្ឍធនធានមនុស្ស: ចំពោះការអភិវឌ្ឍធនធានមនុស្សជាការសង្កត់ធ្ងន់លើការចិញ្ចឹមបីបាច់ថែរក្សាបានល្អដោយផ្តល់នូវការអប់រំដល់អ្នកសិក្សា តាមរយៈការអនុវត្តដើម្បីជំរុញផ្នែកគិត សីលធម៌ និងអនាម័យដែលគេហៅថា (៤ Hs)៖ ក្បាល បេះដូង ដៃ និង សុខភាព (head, heart, hand and health) លើកកម្ពស់ជំនាញរៀនអក្ខរកម្មលេខ និងសមត្ថភាពវែកញែក លើកទឹកចិត្តគ្រូភាសាអង់គ្លេស ដើម្បីអភិវឌ្ឍជំនាញទំនាក់ទំនងភាសាអង់គ្លេសរបស់ពួកគេស្របតាមស្តង់ដាររបស់អឺរ៉ុប(CEFR=Common European Framework of Reference)។ល។

៤. ការផ្តល់ឱកាសសិក្សាស្មើៗគ្នាដើម្បីកាត់បន្ថយវិសមភាពក្នុងការអប់រំ: ឱកាសអប់រំស្មើៗគ្នាត្រូវបានផ្តល់ជូនសម្រាប់ទាំងអស់គ្នា រួមទាំងការផ្តល់ការអប់រំជាមូលដ្ឋានក្រៅផ្លូវការដល់ប្រជាជនក្រៅសាលា ការកែលំអរ

គុណភាពសាលារៀនដែលត្រូវការជំនួយបន្ទាន់ ការផ្តល់ការអប់រំពិសេសសម្រាប់កុមារ និងកុមារពិការជាពិសេសប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល។ល។

៥. ការលើកកម្ពស់គម្រោងដែលមិនប៉ះពាល់ដល់បរិស្ថានដើម្បីលើកកម្ពស់គុណភាពជីវិតៈ គម្រោងផ្សេងៗត្រូវបានអនុវត្ត ដើម្បីលើកកម្ពស់ការយល់ដឹង និងការទទួលស្គាល់បរិស្ថានរួមទាំងគម្រោងគ្រប់គ្រងសំរាមសាលារៀន។ គម្រោងទាំងនេះមានគោលបំណងលើកកម្ពស់ការចូលរួមរបស់សហគមន៍ជុំវិញ និងភ្នាក់ងារបណ្តាញ។ល។

៦. កែលំអរប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធអប់រំៈ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាល និងការគ្រប់គ្រងការអប់រំរបស់ប្រទេស។ ប្រព័ន្ធកំណែទម្រង់ត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធរដ្ឋបាល និងគ្រប់គ្រងរបស់ក្រសួងនៅថ្នាក់កណ្តាល និងក្នុងតំបន់។ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធត្រូវបានធ្វើវិសោធនកម្មដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររចនាសម្ព័ន្ធ ទំនួលខុសត្រូវ និងអនុញ្ញាតឱ្យមានស្ថាប័នអប់រំស្វ័យភាពកាន់តែច្រើនទៀត។ល។

### ១.៣.២.៣ កត្តាដែលប្រទេសថៃយកចិត្តទុកដាក់

ពង្រឹងគុណភាព និងស្តង់ដារការអប់រំគ្រប់កម្រិត និងគ្រប់ប្រភេទដើម្បីឆ្ពោះទៅរកកម្រិតអន្តរជាតិ។ ការពង្រឹងសមភាពនៃឱកាសសម្រាប់ការទទួលបានសេវាអប់រំសាធារណៈ អភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងការអប់រំស្របតាមគោលការណ៍អភិបាលកិច្ចល្អ។ ផ្តោតសំខាន់លើការអភិវឌ្ឍអ្នកសិក្សារួមជាមួយចំណេះដឹង សីលធម៌ គុណភាពជីវិត និងសុភមង្គលក្នុងសង្គម។

### ១.៣.២.៤ ចំពោះគ្រូបង្រៀន និងថ្នាក់ដឹកនាំនៅប្រទេសថៃ

គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលា គឺជាចំណុចសំខាន់នៃកំណែទម្រង់ការអប់រំរបស់ប្រទេសថៃឲ្យមានកម្លាំងចលករក្នុងការបង្រៀន។ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ ២០០០ ប្រទេសថៃមានដំណើរការផ្តល់អាជ្ញាប័ណ្ណជាផ្លូវការដែលតម្រូវឱ្យគ្រូមានគុណវុឌ្ឍិអប់រំត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាគ្រូបង្រៀននៃប្រទេសថៃ ហើយបានបញ្ចប់ការបណ្តុះបណ្តាលផ្នែកអប់រំរយៈពេលមួយឆ្នាំនៅសាលារៀន។ ទោះជាយ៉ាងណាក៏ដោយគ្រូជនជាតិថៃត្រូវបានរៀបចំឱ្យបានល្អគ្រប់គ្រាន់តាមរយៈគរុកោសល្យ ឬបន្តអភិវឌ្ឍជំនាញ ដើម្បីគាំទ្រដល់ការអប់រំរបស់ប្រទេស និងកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់។ ប្រទេសថៃបណ្តុះបណ្តាលវិជ្ជាជីវៈទូទាំងប្រទេសជាយុទ្ធសាស្ត្រអភិវឌ្ឍដើម្បីធានាថាគ្រូធ្វើឱ្យការប្រើប្រាស់វិធីសាស្ត្របង្រៀនប្រកបដោយប្រសិទ្ធភាពក្នុងវាយតម្លៃជាផ្លូវការ។ ដើម្បីកាត់បន្ថយវិសមភាពនៅទូទាំងប្រព័ន្ធអប់រំប្រទេសថៃចាំបាច់ត្រូវធ្វើកិច្ចការជាច្រើនដើម្បីរក្សា និងគាំទ្រដល់ការអប់រំនៅតាមសាលាជនបទដែលជួបការលំបាក។ ឆន្ទៈនេះទាមទារឱ្យ

មានការកែលម្អរដើម្បីធានាថាផែនការទីផ្សារការងារផ្អែកលើមូលដ្ឋានរឹងមាំ និងការផ្លាស់ប្តូរ ដើម្បីកាត់បន្ថយនីតិវិធីដាក់ពង្រាយ។ នៅតាមសាលាជនបទ និងទីក្រុង គឺគ្រូត្រូវមានពេលច្រើនក្នុងការបង្រៀនជាក់ស្តែងជាជាងបំពេញភារកិច្ចរដ្ឋបាល។ សំខាន់បំផុតពួកគាត់ត្រូវការគាំទ្រពីថ្នាក់ដឹកនាំសាលាដែលមានជំនាញវិជ្ជាជីវៈច្បាស់លាស់។

• គណៈគ្រប់គ្រងសាលាត្រូវត្រួតពិនិត្យ និងវាយតម្លៃចំពោះលទ្ធផលនៃការរៀន និងបង្រៀន រួចអភិវឌ្ឍរាល់ចំណុចខ្វះចន្លោះ។

• ផ្តល់ការអភិវឌ្ឍ និងការគាំទ្រជំនាញជាគោលដៅដូចជា សំភារៈសិក្សាសមស្របដល់គ្រូនិងអ្នកដឹកនាំសាលាណែនាំការអនុវត្តកម្មវិធីសិក្សា។

**១.៣.២.៥ សមិទ្ធផលដែលប្រទេសថៃទទួលបាន**

សេដ្ឋកិច្ចចុងក្រោយរបស់ប្រទេសថៃ គឺទទួលបានពីការពង្រឹងជំនាញ និងផលិតភាពនៃកម្លាំងពលកម្មរបស់ប្រទេស គឺជាចំណុចស្នូលក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងរបស់ខ្លួន។ យ៉ាងណាមិញនិស្សិតជាច្រើន ជាពិសេសនៅតាមជនបទមានជំនាញសម្រាប់ការងារនៅក្នុងសេដ្ឋកិច្ចថៃដែលកំពុងរីកចម្រើន។

**១.៣.៣ ការអប់រំនៅប្រទេសសិង្ហបុរី**[7]

**១.៣.៣.១ កត្តាដែលប្រទេសសិង្ហបុរីមានភាពជឿនលឿន និងប្រសិទ្ធភាពវិស័យអប់រំ**

សាកលភាវូបនីយកម្ម ការផ្លាស់ប្តូរប្រជាសាស្ត្រ និងការជឿនលឿនផ្នែកបច្ចេកវិទ្យា គឺជាកត្តាជំរុញដ៏សំខាន់នាពេលអនាគត។ សមត្ថភាពត្រូវបានតំណាងនៅក្នុងក្របខ័ណ្ឌគាំទ្រការអប់រំទូទៅដែលសាលារៀនផ្តល់ ដើម្បីរៀបចំសិស្សឱ្យកាន់តែប្រសើរសម្រាប់ពេលអនាគត។ មានការរំពឹងទុកថាសាលារៀន និងឪពុកម្តាយត្រូវធ្វើការរួមគ្នា ដើម្បីជួយសិស្សអភិវឌ្ឍសមត្ថភាពក្នុងសតវត្សរ៍ទី ២១ នេះ។

**១.៣.៣.២ លទ្ធផលការអប់រំដែលប្រទេសសិង្ហបុរីរំពឹង**

ការអប់រំគ្រប់កម្រិតថ្នាក់ចាប់តាំងពីថ្នាក់ក្រោមដល់កម្រិតខ្ពស់ស្របទៅតាមប្រពន្ធ័អប់រំដែលមានប្រសិទ្ធភាព ដើម្បីទទួលបាននូវ "**មូលធនមនុស្សដែលមានគុណភាព**"។ លទ្ធផលដែលចង់បានពីការអប់រំគឺការអប់រំប្រាថ្នាចង់អោយប្រជាជនសិង្ហបុរីទទួលបាននូវចំណេះដឹង និងជំនាញជាលទ្ធផលបន្ទាប់ពីបញ្ចប់ការអប់រំដោយបង្កើតគោលបំណងរួមសម្រាប់អ្នកអប់រំ ជំរុញគោលនយោបាយ និងកម្មវិធីសិក្សា អនុញ្ញាតឱ្យ

[7] https://www.moe.gov.sg/

កំណត់លើប្រព័ន្ធអប់រំដំណើរការល្អ។ មនសិការល្អក្នុងការយល់ដឹងខ្លួនឯងជាត្រីវិស័យខាងសីលធម៌ល្អ និងជំនាញចំណេះដឹងចាំបាច់ ដើម្បីប្រឈមនឹងឧបសគ្គនាពេលអនាគត ទទួលខុសត្រូវចំពោះគ្រួសារ សហគមន៍ និងប្រជាជាតិ រាងកាយដែលមានសុខភាពល្អ និងមានក្តីសង្ឃឹមសម្រាប់ជីវិត។ សរុបមកជាមនុស្សដែលមានជំនឿចិត្ត ចេះដឹងខុសត្រូវ គឺចេះសម្របខ្លួន ចេះអត់ធន់ ចេះស្គាល់ខ្លួនឯង ចេះវែកញែកវិនិច្ឆ័យ គិតដោយឯករាជ្យ ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។ ជាអ្នកសិក្សាដែលដឹកនាំខ្លួនឯងទទួលខុសត្រូវចំពោះការរៀនសូត្រផ្ទាល់ខ្លួន ចេះសាកសួរសំណួរដែលរឆ្លុះបញ្ចាំងពីតថភាព និងតស៊ូក្នុងការស្វែងរកការរៀនសូត្រ។ ចូលរួមសកម្មភាពដែលអាចធ្វើការប្រកបដោយប្រសិទ្ធភាពក្រុម ការផ្តួចផ្តើមធ្វើលំហាត់ប្រាណ ទទួលយកហានិភ័យដែលត្រូវបានគណនាមានលក្ខណៈច្នៃប្រឌិត និងខិតខំដើម្បីឧត្តមភាព។ ពលរដ្ឋមានដើមកំណើតនៅប្រទេសសិង្ហបុរីមានត្រូវមានស្មារតីពលរដ្ឋរឹងមាំត្រូវ និងមានតួនាទីយ៉ាងសកម្មក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវិតអ្នកដទៃនៅជុំវិញគាត់។

### ១.៣.៣.៣ ចំពោះគ្រូបង្រៀននៅប្រទេសសិង្ហបុរី

គ្រូមានសារៈសំខាន់ណាស់ចំពោះការអប់រំដោយ ខិតខំអស់ពីសមត្ថភាព ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់គ្រូ ដើម្បីនាំយកការអនុវត្តប្រកបដោយគុណភាពគំនិតច្នៃប្រឌិតថ្មីក្នុងថ្នាក់រៀន និងសាលារៀន។ ការកសាងសមត្ថភាពរបស់ពួកគេក្នុងនាមជាអ្នកជំនាញបង្រៀនដូច្នេះអាចណែនាំសិស្សរបស់ពួកគេកាន់តែច្រើននៅក្នុងដំណាក់កាលនៃរីកលូតលាស់របស់ពួកគេ។

### ១.៣.៣.៤ គោលនយោបាយរបស់រដ្ឋាភិបាលសិង្ហបុរីលើវិស័យអប់រំ

ប្រព័ន្ធអប់រំរឹងមាំសិង្ហបុរីមានគោលបំណងខ្ពស់ ហើយទទួលបានលទ្ធផលល្អណាស់ ត្រូវបានទទួលស្គាល់នៅជុំវិញពិភពលោកថាមានសាលាល្អៗ ដែលមានអ្នកដឹកនាំសាលា និងគ្រូមានសមត្ថភាព។ ប្រទេសសិង្ហបុរីកំពុងពង្រឹងចំណុចខ្លាំងទាំងនេះនៅពេលដែលរៀបចំប្រជាជនសិង្ហបុរីជំនាន់ក្រោយសម្រាប់អនាគត។ នេះគឺជាអនាគតដែលនាំមកនូវឱកាសយ៉ាងច្រើន ជាពិសេសនៅក្នុងទ្វីបអាស៊ី ប៉ុន្តែវាក៏នឹងនាំមកនូវការផ្លាស់ប្តូរជាច្រើនដែលមិនអាចនឹកស្មានដល់នាពេលបច្ចុប្បន្ននេះ។ ភារកិច្ចរបស់សាលា និងស្ថាប័នឧត្តមសិក្សារបស់សិង្ហបុរី គឺផ្តល់ឱកាសដល់យុវជនក្នុងការអភិវឌ្ឍជំនាញលក្ខណៈ និងគុណតម្លៃដែលអាចឱ្យពួកគេបន្តធ្វើបានល្អ និងឈានទៅមុខនៅប្រទេសសិង្ហបុរីនាពេលអនាគត។ ការផ្លាស់ប្តូរនៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះឆ្ពោះទៅរកប្រព័ន្ធអប់រំមួយដែលមានភាពបត់បែន និងចម្រុះ។ គោលបំណង គឺដើម្បីផ្តល់ឱ្យសិស្សនូវជម្រើសកាន់តែប្រសើរ ដើម្បីបំពេញតាមចំណាប់អារម្មណ៍ និងវិធីផ្សេងគ្នានៃការរៀនសូត្រ អាចជ្រើសរើសនិងរបៀបដែលពួកគេរៀន និងលើកទឹកចិត្តពួកគេឱ្យមានភាពជាម្ចាស់នៃការរៀនរបស់ពួកគេកាន់តែច្រើន។ កំពុងផ្តល់

ឱ្យសិស្ស នូវការអប់រំដែលមានមូលដ្ឋានទូលំទូលាយបន្ថែមទៀតដើម្បីធានាឱ្យមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ ឬជាទូទៅនៅក្នុង និងក្រៅថ្នាក់រៀន។ វិធីសាស្ត្រទាំងនេះនៅក្នុងការអប់រំនឹងអនុញ្ញាតឱ្យចិញ្ចឹមបីបាច់ក្មេងៗជាមួយនឹងជំនាញផ្សេងៗគ្នាដែលពួកគេត្រូវការសម្រាប់អនាគត និងព្យាយាមជួយកុមារគ្រប់រូបឱ្យរកឃើញទេពកោសល្យផ្ទាល់ខ្លួន ហើយរីកចម្រើន និងចេញពីសាលារៀនទាំងមានទំនុកចិត្តលើសមត្ថភាពខ្លួនលើកទឹកចិត្តពួកគេឱ្យធ្វើតាមចំណង់របស់ពួកគេ និងលើកកម្ពស់ភាពសម្បូរបែបនៃទេពកោសល្យក្នុងចំណោមពួកគេនៅក្នុងវិស័យអប់រំ កីឡា និងសិល្បៈ។ បណ្តុះបណ្តាលយុវជន អ្នកដែលមានឆន្ទៈគិតតាមវិធីដោះស្រាយបញ្ហាថ្មីៗនិងបង្កើតឱកាសថ្មីៗសម្រាប់អនាគត ហើយសំខាន់ដូចគ្នា ជួយយុវជនបញ្ចេញមតិដើម្បីអោយពួកគេមានភាពរឹងមាំនៃចរិតលក្ខណៈ និងភាពអត់ធ្មត់ដើម្បីទប់ទល់នឹងដំណើរថយក្រោយដែលចៀសមិនរួចដោយមិនមានការបាក់ទឹកចិត្តហើយដូច្នេះពួកគេមានឆន្ទៈខិតខំធ្វើការដើម្បីសំរេចក្តីសុបិន្តរបស់ពួកគេ។

# ជំពូកទី២

# ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជា

## ២.១. ប្រភេទនៃការអប់រំ

យោងតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៧ ការអប់រំនៅកម្ពុជាចែកចេញជាបី[8]ប្រភេទគឺ៖

- ការអប់រំក្នុងប្រព័ន្ធ : សំដៅដល់ដំណើរការសិក្សាដែលមានលក្ខណៈជាប្រព័ន្ធ និងហ្មត់ចត់ មានរចនាសម្ព័ន្ធរៀបរយ និងតាមលំដាប់ថ្នាក់។ ការអប់រំក្នុងប្រព័ន្ធផ្តល់ឲ្យដោយគ្រឹះស្ថានសិក្សា ដែលមានអាជ្ញាប័ណ្ណអប់រំត្រឹមត្រូវ ឬដែលមានការទទួលស្គាល់គុណភាពអប់រំស្របតាមលក្ខខណ្ឌផ្នែកច្បាប់ និងនីតិវិធីដែលមានចែងក្នុងច្បាប់នេះ។
- ការអប់រំក្រៅប្រព័ន្ធ : សំដៅដល់សកម្មភាពអប់រំ ដែលមានការរៀបចំមានលក្ខណៈជាប្រព័ន្ធ ដែលធ្វើឡើងនៅក្រៅក្របខ័ណ្ឌនៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ដើម្បីផ្តល់ការសិក្សាមួយចំនួនដែលបានជ្រើសរើស។ ការអប់រំក្រៅប្រព័ន្ធគ្រប់ដណ្តប់លើកម្មវិធីអប់រំជាច្រើន ដូចជាអក្ខរកម្ម បំណិនជីវិត បំណិនការងារ ការអប់រំមូលដ្ឋាន សម្រាប់អ្នកសិក្សាដែលមិនចូលសិក្សានៅគ្រឹះស្ថានសិក្សាក្នុងប្រព័ន្ធ ដែលមានលក្ខណៈជាការសិក្សាបន្ត និងការសិក្សាកម្រិតសមមូលសម្រាប់ការបញ្ចូលទៅក្នុងកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬ ជាការអប់រំអស់មួយជីវិត។ អ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធមានសិទ្ធិសុំ និងទទួលបាននូវការធ្វើតេស វាយតម្លៃកម្រិតសមមូលចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ។
- ការអប់រំមិនផ្លូវការ : សំដៅដល់ដំណើរការស្វ័យសិក្សា ឬ ការសិក្សាដោយខ្លួនឯង និងជាដំណើរការសិក្សាអស់មួយជីវិត តាមការចាប់អារម្មណ៍ សក្តានុពលត្រៀមខ្លួនជាស្រេច និងឱកាសដែលមានហើយដែលអ្នកសិក្សាទទួល និងបង្កើនផ្គុំចំណេះដឹង ជំនាញ ឥរិយាបថ និងគំនិតបានមកពីបទពិសោធន៍ប្រចាំថ្ងៃពីការងារ ការសំដែង និងពីជីវិតផ្ទាល់ និងជាការសិក្សាតាមរយៈមនុស្ស សង្គម មជ្ឈដ្ឋានជុំវិញប្រព័ន្ធសារព័ត៌មាន ព្រមទាំងប្រភពចំណេះដឹង ឬ ប្រភពព័ត៌មានផ្សេងទៀតនៅពេលណា និងនៅទីកន្លែងណាផ្សេងទៀតក៏ដោយក្រៅពីកម្មវិធីអប់រំក្នុងប្រព័ន្ធ និងកម្មវិធីអប់រំក្រៅប្រព័ន្ធ។ អ្នកសិក្សាមានសិទ្ធិសុំ និងទទួលការធ្វើតេសវាយតម្លៃកម្រិតសមមូល ចំពោះការអប់រំរបស់ខ្លួនពីអាជ្ញាធរអប់រំមានសមត្ថកិច្ចដូចមានចែងក្នុងច្បាប់នេះ។

[8] ច្បាប់ស្តីពីការអប់រំ មាត្រា១៥ ជំពូកទី៤ ទំព័រទី៥ ឆ្នាំ២០០៧

## ២.២ ការវិវត្តន៍ប្រព័ន្ធអប់រំកម្ពុជា

តាមរយៈប្រវត្តិនៃសម័យកាលអប់រំនីមួយៗ យើងសូមបង្ហាញជូនជាដំណាក់កាលដូចតទៅះ

### ២.២.១. មុនសម័យអាណានិគមបារាំង[9]

ប្រទេសកម្ពុជាមានប្រវត្តិនៃការសិក្សាតាំងពីយូរយារណាស់មកហើយ ដែលទម្រង់នៃការសិក្សានេះទៀតសោតក៏មានការប្រែប្រួលទៅតាមសម័យកាល និងការដឹកនាំប្រទេសរបស់ថ្នាក់ដឹកនាំនីមួយៗផងដែរ។ កាលពីសម័យដើមការសិក្សារបស់ប្រទេសខ្មែរ គឺត្រូវបានធ្វើឡើងនៅតាមទីវត្តអារាមតែប៉ុណ្ណោះ ដោយមានព្រះសង្ឃដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ហាត់បង្រៀន និងផ្តល់ចំណេះដឹងដល់កុមារ និងយុវវ័យនាសម័យនោះ។ អាស្រ័យហេតុនេះហើយទើបមានតែក្មេងប្រុសតែប៉ុណ្ណោះដែលមានសិទ្ធក្នុងការទទួលបាននូវការអប់រំ ចំណែកឯកូនស្រីត្រូវបានគេហាមឃាត់មិនអនុញ្ញាតឲ្យទទួលបានការអប់រំឡើយ។ ការសិក្សាដែលផ្តល់ឲ្យសិស្ស គឺមានត្រឹមតែចេះ និងចងចាំនូវព្រះធម៌ជាភាសាបាលី ចេះអាន សរសេរអក្សរ និងមានបង្ហាត់បង្រៀនការងារជំនាញមួយចំនួន ដែលទាក់ទងទៅនឹងជីវភាពរស់នៅតាមជនបទរបស់ប្រជាជនខ្មែរតែប៉ុណ្ណោះ ដូចជាការងារ ជាងឈើ ធ្វើតុ ទូ ជាដើម។ ការសិក្សាអប់រំនាសម័យបុរាណមានការរីកចំរើនគួរឲ្យកត់សម្គាល់ ពិសេសក៏បាននាំយកនូវភាពរុងរឿង និងកេរ្តិ៍ឈ្មោះល្បីល្បាញជូនប្រទេសជាតិជារឿយៗផងដែរ តាមរយៈស្នាដៃ ក៏ដូចជាទេពកោសល្យដូនតារបស់យើង។ ជាក់ស្តែងក្នុងរជ្ជកាលនៃព្រះបាទកៅណ្ឌិន្យ គ្រិស្តសតវត្សទី ៥ ព្រះមហាថេរៈព្រះនាម សង្ឃបាល បាននិមន្តទៅកាន់ប្រទេសចិន និងបានធ្វើការបកប្រែព្រះត្រៃបិដក និងគម្ពីរ វិសុទ្ធមគ្គ ទៅជាភាសាចិននៅការិយាល័យនគរភ្នំ (Founan QUANG) នាប្រទេសចិន ដែលធ្វើឲ្យព្រះចៅក្រុងចិនសព្វព្រះរាជហឫទ័យយ៉ាងខ្លាំង ហើយថែមទាំងបានចារឹកព្រះនាមរបស់ព្រះអង្គនេះទុកក្នុងគម្ពីរព្រះត្រៃបិដកចិនទៀតផង។

ចំណែកសម័យមហានគរវិញត្រូវបានអ្នកស្រាវជ្រាវជាច្រើនលើកបង្ហាញថាការសិក្សាអប់រំនៅសម័យនោះបានឈានឡើងដល់កម្រិតខ្ពស់បំផុត ព្រោះមានព្រះនាងឥន្ទ្រទេវីដែលជាអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី ៧ ដោយព្រះនាងជាអ្នកសិក្សាមួយរូប ដែលទ្រង់ចេះវិជ្ជាអក្សរសិល្ប៍ ចេះភាសាសំស្រ្កឹតច្បាស់លាស់ ចេះវិទ្យាសាស្ត្រផ្សេងៗ ហើយមានប្រាជ្ញាឈ្លាសវៃផងដែរ។ ហេតុដូច្នេះហើយទើបទ្រង់យកព្រះទ័យទុកដាក់យ៉ាងខ្លាំង និងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកស្ទួយវិស័យអប់រំឲ្យមានការរីកចំរើន។ លើសពីនេះទៅទៀតព្រះនាង ឥន្ទ្រទេវី ទ្រង់ជាសាកលវិទ្យាធិការនី នៅក្នុងវត្តជ័យស្រី (ព្រះខាន់)។ ចំណែកនៅក្នុងវត្ត

---

[9] ដកស្រង់ពីសៀវភៅ ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សានៅកម្ពុជា និពន្ធដោយបណ្ឌិតប្រវត្តិវិទ្យា ស៊ន សំណាង និងអតីតអធិការបឋមសិក្សា លោក យ៉ង់ ធី ទំព័រទី១ ដល់១០ ឆ្នាំ១៩៩៨

រាជវិហារ (តាព្រហ្ម) ព្រះមហាថេរៈ ថ្នាក់បណ្ឌិតមាន ១៨ អង្គ និងជាសាស្ត្រាចារ្យមាន ២៧៤០ អង្គ។ ទាំងនេះជាស្តម្ភ សម្រាប់ទ្រទ្រង់ការសិក្សានាសម័យនោះ។ ជាលទ្ធផលបានបង្ហាញថាពេលនោះប្រទេសខ្មែរសម្បូរទៅដោយអ្នកចេះដឹង អ្នកប្រាជ្ញជាច្រើននាក់ ទាំងផ្នែកព្រះពុទ្ធសាសនា និងសាសនាព្រាហ្មណ៍។

បើនិយាយពីការសិក្សាក្នុងគ្រឹស្តសតវត្សទី១៦ ទី១៧ ទី១៨ មានការធ្លាក់ចុះទន់ខ្សោយណាស់ ស្ទើរតែរលត់ទៅហើយ។ តែទោះជាយ៉ាងណាក៏ដោយការសិក្សា នេះគ្រាន់តែរៀវស្ងួចតូច តែមិនដល់ថ្នាក់ដាច់នោះឡើយ ពោលគឺការសិក្សាត្រូវបានធ្វើនៅតាមទីវត្តអារាមដដែល។

បើយើងងាកមកមើលការសិក្សាក្នុងសតវត្សទី ១៩ វិញ ក្នុងរាជ្យព្រះបាទហរិរក្សរាមា (ព្រះអង្គដួង) ឃើញថាការសិក្សាមានការរីកចំរើនឡើងវិញ ព្រោះមានការយកព្រះទ័យទុកដាក់ពីព្រះអង្គ។ ព្រះបាទអង្គដួងត្រូវបានគេស្គាល់ថាទ្រង់ជាអ្នកប្រាជ្ញ ទ្រង់ជាកវី ទ្រង់ជាបណ្ឌិត ទ្រង់ជាអ្នកនិពន្ធដ៏វិសេស ហើយទ្រង់ក៏ជាសាស្ត្រាឯកទៀតផង។ នាសម័យនោះសាស្ត្រាច្បាប់ សាស្ត្រាល្បែង សាស្ត្រាទេសន៍ មានការកើនឡើងច្រើន។ ក្នុងសម័យនោះព្រះបរមរាជវាំងឧដុង្គជាសាកលវិទ្យាល័យ ដែលមានព្រះបាទអង្គដួង ជាសាកលវិទ្យាធិការ។ ទ្រង់បង្រៀនវិជ្ជាអក្សរសាស្ត្រខ្មែរ វិជ្ជាកាព្យ វិជ្ជានិពន្ធ ទ្រង់បង្រៀនបាលី បង្រៀនធម៌ ទស្សនៈវិជ្ជាពុទ្ធសាសនា និងវិជ្ជាផ្សេងៗទៀតផ្ទាល់ព្រះអង្គ។ ក្រៅពីរាជកិច្ចគ្រប់គ្រងដឹកនាំប្រទេសដ៏ធ្ងន់ធ្ងរ ទ្រង់បានឆ្លៀតព្រះបរមរាជវរោកាសដ៏មានតម្លៃរបស់ព្រះអង្គទៅក្នុងការសិក្សា ទ្រង់បង្រៀនព្រះបរិយត្តិធម៌ដល់ភិក្ខុសាមណេរទៀតផង។ ព្រះរាជដំណាក់ឃ្លាំង ដែលនៅចំពីមុខព្រះទីនាំងទេវាវិនិច្ឆ័យឧដុង្គជាមន្ទីរសិក្សា។ ព្រះរាជបរិពារក៏បានទទួលការសិក្សា។ ក្រៅពីភារកិច្ចរបស់ខ្លួន ម្នាក់ៗសិក្សាបរិយត្តិធម៌រៀនបែបបទផ្សេងៗ តាមបំណងរៀងៗខ្លួន ដូចជាភិក្ខុសាមណេរនៅតាមវត្តអារាមដែរ។ ការសិក្សាប្រព្រឹត្តទៅតាមប្រពៃណីដើមដដែល ពោលគឺ មានតែកុមារាទេដែលទទួលបានការសិក្សា។ រីឯកុមារីវិញ ទោះបីពុំមានការហាមឃាត់ជាផ្លូវការតែមានទំនៀមចងទូទៅពេញប្រទេសថា មិនគួរនឹងឲ្យស្ត្រីសិក្សាទេរៀរលែងតែនៅក្នុងព្រះរាជសំណាក់។ កាលណាកុមារាមានអាយុ ៧ ទៅ១០ឆ្នាំ ឪពុកម្តាយតែងនាំកូនទៅផ្ញើរលោកគ្រូចៅអធិការ ដើម្បីស្នាក់នៅនិងហាត់រៀននៅក្នុងវត្ត។ បើនិយាយពី ការសិក្សាសម័យនោះ គេសំដៅទៅលើការរៀនអក្សរ រៀនអាន ស្មូត្រកំណាព្យ ស្មូត្រលេខនព្វន្ត ធម៌អាថ៌ និងរៀនវិជ្ជាជីវៈ។ ការសិក្សាមានតាមដំណាក់កាល ជាដំបូងពួកគេត្រូវរៀនអាន និងសរសេរឲ្យបានស្ទាត់ជំនាញសឹមលោកគ្រូនឹងបង្រៀនមើលសាស្ត្រាច្បាប់ សាស្ត្រាល្បែង និងសាស្ត្រាទេសន៍តាមលំដាប់ជាបន្តបន្ទាប់។ លើសពីនោះទៅទៀតក៏មានបង្រៀនជំនាញវិជ្ជាជីវៈ ខាងប្រុសៗគេរៀនអារ ចាំង ឈូស ដាប់ឈើ ធ្វើផ្ទះ តុ ទូ ទូក ក្តារ ឥដ្ឋ គ្រឿង ត្បាញកញ្ជើ ល្អី កញ្ច្រែង។ល។ ឯស្រីៗ

វិញ រៀនវេស្សន្ដរ អំបោះ ត្បាញ ធ្វើគោម ចង្កៀង ទៀន ធូប។ល។ ជារួមការសិក្សានៅសម័យនោះមានការរីកចំរើនណាស់ក្រោមការដឹកនាំរបស់ព្រះបាទអង្គដួង។

### ២.២.២ សម័យអាណានិគមបារាំង (១៨៦៣ ដល់ ១៩៥៣)

ប្រទេសបារាំងបានចាប់ផ្ដើមត្រួតត្រាមកលើប្រទេសកម្ពុជានៅឆ្នាំ១៨៦៣ ប៉ុន្តែរដ្ឋាភិបាលអាណានិគមពុំបានយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជានោះទេ ព្រោះពួកគេយល់ថាការលើកកម្ពស់ការអប់រំនៅកម្ពុជា អាចធ្វើឲ្យប្រជាជនខ្មែរមានឆន្ទៈក្នុងការរួបរួមកម្លាំងគ្នាដើម្បីរើបម្រាស់ចេញពីអាណានិគម ពិសេសគឺប៉ះពាល់ដល់អំណាចនៃការគ្រប់គ្រងរបស់ពួកគេមកលើប្រទេសខ្មែរ។ ក្រោយមកក្នុងអំឡុងទសវត្សទី៩០ ទើបបារាំងបានបង្កើតឲ្យមានប្រព័ន្ធអប់រំដែលផ្អែកលើមូលដ្ឋានគំរូបែបបារាំង ដែលដើរទន្ទឹមគ្នានឹងប្រព័ន្ធអប់រំបែបប្រពៃណីរបស់ខ្មែរផងដែរ។ ក្នុងលក្ខខណ្ឌនៃការអប់រំបែបទំនើបដែលបារាំងបានផ្ដល់មកកម្ពុជា គេសង្កេតឃើញថា ត្រូវបានផ្ដល់ឲ្យតែគ្រួសារណាដែលមានទ្រព្យសម្បត្តិច្រើន និងអាចបម្រើដល់អំណាចរបស់រដ្ឋាភិបាលអាណានិគមតែប៉ុណ្ណោះ ពោលគឺ អ្នកដែលមានជីវភាពធូរធារទើបអាចចូលរៀនតាមប្រព័ន្ធអប់រំទំនើបបារាំង ចំណែកសិស្សដែលរស់នៅតំបន់ជនបទនៅតែបន្តការសិក្សានៅតាមទីវត្តអារាមតាមបែបប្រពៃណីដដែល។ ទោះបីជាយ៉ាងណាក៏ដោយ ការបង្កើតប្រព័ន្ធអប់រំទំនើបបារាំងនេះក៏បានផ្ដល់ឱកាសជាលើកដំបូងសម្រាប់ក្មេងស្រីបានចូលរៀននៅសាលាជាផ្លូវការផងដែរ។ ទន្ទឹមនឹងនេះពេលមានវត្តមាននៃការអប់រំបែបទំនើប កាន់តែពង្រីកទូលំទូលាយទៅ សាលារៀនប្រពៃណីតាមវត្តអារាមនៅសល់តួនាទីគ្រាន់តែជាកន្លែងដែលអភិរក្សវប្បធម៌ខ្មែរប៉ុណ្ណោះ។ លើសពីនេះទៅទៀតបារាំងមានចេតនាអាក្រក់មួយ គឺចង់លុបបំបាត់ឲ្យបាននូវវប្បធម៌ខ្មែរដូចដែលបារាំងបានទទួលជោគជ័យលើប្រទេសវៀតណាមនោះ។ ប៉ុន្តែបញ្ញាវន្តខ្មែរនាសម័យនោះ ពិសេសគឺព្រះសង្ឃ បានប្រឆាំងនឹងបំណងរបស់រដ្ឋាភិបាលអាណានិគមក្នុងការចង់ផ្សព្វផ្សាយវប្បធម៌របស់ខ្លួនទាំងស្រុងមកលើប្រទេសខ្មែរ។[10]

### ២.២.៣ ប្រព័ន្ធអប់រំនៅចន្លោះឆ្នាំ (១៩៥៣ ដល់ ១៩៦០)

ក្នុងទសវត្សឆ្នាំ១៩៥៣ និង ១៩៦០ សន្ទុះទឹកចិត្តសប្បាយរីករាយរបស់ប្រជាពលរដ្ឋចំពោះការរៀនសូត្រមានធំធេងណាស់។ គ្រប់ស្រុក គ្រប់ឃុំ មានសមាគមទ្រទ្រង់សាលារៀន បង្កើតដោយព្រះសង្ឃ និងឪពុកម្ដាយសិស្ស។ គេនាំគ្នាធ្វើបុណ្យផ្កាប្រែបច្ច័យយកមកកសាងសាលារៀននៅក្នុងភូមិឃុំរបស់ខ្លួន។ ដូចនេះសាលារៀនទាំងបឋមសិក្សា និងទាំងមធ្យមសិក្សា ត្រូវបានសាងសង់ដុះដូចផ្សិតត្រូវទឹកភ្លៀង។ សាលាវត្តជាច្រើនត្រូវបានកែប្រែជាសាលាបឋមសិក្សារដ្ឋ។ ក្រសួងអប់រំមានកង្វល់ជាខ្លាំងក្នុងការផ្ដល់គ្រូ។ មួយឆ្នាំៗមាន

[10] Strategies and Policies for Basic Education in Cambodia: Historical PerspectivesSideth S. Dy, P. 91-93 (In 2004)

ការប្រលងប្រជែងជ្រើសរើសគ្រូបង្ហាត់ខ្មែរផង គ្រូបឋមសិក្សាផង។ នៅឆ្នាំ ១៩៥៨ វិទ្យាស្ថានជាតិគរុកោសល្យ (ព្រះរាជក្រមលេខ ៤៣៨ ន.ស ចុះថ្ងៃទី ១០-០៧-១៩៥៨)។

វិទ្យាស្ថាននេះ មានបីផ្នែក៖

- បណ្តុះបណ្តាលគ្រូបឋមសិក្សា
- បណ្តុះបណ្តាលសាស្ត្រាចារ្យមធ្យមសិក្សាបឋមភូមិ
- មជ្ឈមណ្ឌលស្រាវជ្រាវ និងតម្កល់ឯកសារ

នៅឆ្នាំបន្តបន្ទាប់មានបង្កើតផ្នែកពីរទៀតគឺ៖

- មជ្ឈមណ្ឌលបង្រៀនមេផ្ទះ
- ថ្នាក់រៀបចំប្រលងអធិការបឋមសិក្សា។

ដើម្បីឲ្យការសិក្សាមានដំណើរប្រកបដោយភាពជោគជ័យ ក្នុងការទទួលចំណេះដឹងគ្រប់មុខវិជ្ជា ក្រសួងអប់រំបានបង្កើតគណៈកម្មការមួយសម្រាប់បកប្រែពាក្យបច្ចេកទេសតាមមុខវិជ្ជានីមួយៗ ហើយបានចាប់អនុវត្តខេមរយានកម្ម ចាប់ពីថ្នាក់ទី ៦ ទំនើប ក្នុងឆ្នាំ ១៩៦៧។ រីឯការបង្រៀនភាសាបារាំងវិញ ក្រសួងអប់រំបានអញ្ជើញសាស្ត្រាចារ្យបារាំងមកបង្រៀននៅតាមអនុវិទ្យាល័យ វិទ្យាល័យ តាមកិច្ចព្រមព្រៀងរវាងកម្ពុជា-បារាំង ប៉ុន្តែមិនបានគ្រប់អនុវិទ្យាល័យ និងវិទ្យាល័យឡើយ។

អនុលោមតាមសន្ធិសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃទី ០៨ ១១ ១៩៤៩ រាជរដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលបារាំង បានចុះកិច្ចព្រមព្រៀងវប្បធម៌ នៅភ្នំពេញ នាថ្ងៃទី ១៥ មិថុនា ១៩៥០។ តាមកិច្ចព្រមព្រៀងនេះ បារាំងបានផ្ទេរសមត្ថកិច្ចគ្រប់គ្រងសាលាបឋមសិក្សា មធ្យមសិក្សា និងសិក្សាបច្ចេកទេស និងវិជ្ជាជីវៈឲ្យមករាជរដ្ឋាភិបាលខ្មែរ និងកំណត់ទីតាំងភាសាបារាំងក្នុងកម្មវិធីសិក្សាខ្មែរ។ នាឆ្នាំ១៩៥២ វិទ្យាល័យ និងអនុវិទ្យាល័យបានរីកដុះដាលយ៉ាងច្រើនដូចជា វិទ្យាល័យស៊ីសុវត្ថិ អនុវិទ្យាល័យនារី សាលាគរុវិជ្ជា អនុវិទ្យាល័យកំពង់ចាម អនុវិទ្យាល័យបាត់ដំបង ហើយក្រោយមកក៏មានការបង្កើតអនុវិទ្យាល័យបន្ថែមទៀតនៅតាមបណ្តាខេត្តផ្សេងៗដូចជា សៀមរាប កំពត ស្វាយរៀង និងតាកែវ។ មកដល់ទសវត្សឆ្នាំ ១៩៦០ ជាឆ្នាំកំពូលនៃការរីកចម្រើនឧត្តមសិក្សា ក្នុងនោះមាន សាកលវិទ្យាល័យ ៩ និងមហាវិទ្យាល័យ ៣៩។ ការបណ្តុះបណ្តាលសាស្ត្រាចារ្យទុតិយភូមិ នៅសាលាគរុកោសល្យជាន់ខ្ពស់ បានបោះជំហានសន្សឹមៗ ហើយរដ្ឋក៏បានបញ្ជូននិស្សិតពូកែៗទៅបន្តការសិក្សានៅប្រទេសបារាំងមួយចំនួន ដើម្បីយកសញ្ញាបត្រថ្នាក់បណ្ឌិត។ ជារួមការសិក្សានាសម័យនោះគឺមានការរីកចំរើនខ្លាំង។ តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍មូលធនមនុស្ស

ក្នុងទសវត្សទី៦០ ជាលទ្ធផលបានបង្ហាញថា ប្រទេសកម្ពុជា ជាប្រទេសដែលមានអត្រាអក្ខរកម្ម និងប្រព័ន្ធអប់រំខ្ពស់ជាងគេនៅអាស៊ីអាគ្នេយ៍នាសម័យនោះ។[11]

### ២.២.៤ សម័យសាធារណរដ្ឋខ្មែរ (១៩៧០ ដល់ ១៩៧៥)

របបសាធារណរដ្ឋខ្មែរ ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ បន្ទាប់ពីការធ្វើរដ្ឋប្រហារទម្លាក់ព្រះបាទ នរោត្តម សីហនុ ដែលធ្វើឡើងដោយ សេនាប្រមុខ លន់ នល់ និងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលមានការគាំទ្រពីសហរដ្ឋអាមេរិច។ ប្រទេសកម្ពុជានាពេលនោះមាននិន្នាការទៅរកលទ្ធិប្រជាធិបតេយ្យ។ អស្ថិរភាពជាតិ និងភាពរឹករវផ្នែកនយោបាយបានដឹកនាំឲ្យរបបសាធារណរដ្ឋខ្មែរធ្វើការកាត់បន្ថយកញ្ចប់ថវិកាសម្រាប់ទ្រទ្រង់ដល់វិស័យអប់រំ ពិសេសសាលារៀនជាច្រើននៅតំបន់ជនបទត្រូវបានបិទ។ ទន្ទឹមនឹងនេះមានគ្រូបង្រៀន និងសិស្សជាច្រើនបានចូលរួមក្នុងចលនាខ្មែរក្រហមកុំម្មុយនីស្ត ហើយបាតុកម្មក៏កើតមានជាញឹកញាប់នៅទីក្រុងភ្នំពេញ។ នៅដើមឆ្នាំ១៩៧២ សហរដ្ឋអាមេរិចបានទម្លាក់គ្រាប់បែកជាច្រើននៅតំបន់ភូមិភាគខាងកើត ក្នុងគោលបំណងកាត់បន្ថយការសាយភាយនៃលទ្ធិកុំម្មុយនីស្ត ដែលជាលទ្ធផលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធអស់យ៉ាងច្រើន រួមទាំងហេដ្ឋារចនាសម្ព័ន្ធអប់រំផងដែរ។[12]

### ២.២.៥ សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ ដល់ ១៩៧៩)

ក្នុងអំឡុងពេលនោះ ប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងស្ថានភាពងងឹតគឺ របបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ឬរបបប៉ុលពត ដែលឡើងកាន់អំណាចនាថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥។ ការដឹកនាំរបបនេះត្រូវដើរតាមបដិវត្តន៍កុម្មុយនីស្តម៉ៅ ដែលមានលក្ខណៈជារបបផ្តាច់ការខ្លាំងបំផុត។ របបនេះទៀតសោតបានបន្តបំផ្លិចបំផ្លាញប្រទេសជាតិយ៉ាងដំណំ ក្នុងនោះរួមមានប្រព័ន្ធអប់រំ វប្បធម៌សង្គម និងទ្រព្យសម្បត្តិបុគ្គលជាដើម។ ជាពិសេសគឺបានធ្វើឲ្យបាត់បង់ធនធានមនុស្ស ដែលជាកាតាលីករយ៉ាងសំខាន់សម្រាប់អភិវឌ្ឍសង្គមជាតិ ខណៈពេលគ្រូបង្រៀន សិស្ស អ្នកជំនាញ និងបញ្ញវ័ន្តជាច្រើនត្រូវបានសម្លាប់យ៉ាងរង្គៀល ឬត្រូវបានជម្លៀសខ្លួនទៅនៅបរទេស។ លើសពីនេះទៅទៀតរបបនេះបានបង្ខំប្រជាជនទាំងមូលចូលក្នុងជំរុំកងទ័ព ឬកសិដ្ឋានសមូហភាព។ ការអប់រំផ្លូវការត្រូវបានលុបបំបាត់ចោល ហើយប្រជាជនទាំងអស់ត្រូវបានបែងចែកឲ្យរស់នៅជាសហករណ៍ទៅតាមភេទ និងអាយុ។[13]

---

[11] ដកស្រង់ពីសៀវភៅ ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សានៅកម្ពុជា និពន្ធដោយបណ្ឌិតប្រវត្តិវិទ្យា ស៊ន សំណាង និងអតីតអធិការបឋមសិក្សា លោក យ៉ង់ ជី ទំព័រទី33 ដល់35 ឆ្នាំ១៩៩៨

[12] Strategies and Policies for Basic Education in Cambodia: Historical Perspectives Sideth S. Dy, P. 95 (In 2004)

[13] Strategies and Policies for Basic Education in Cambodia: Historical Perspectives Sideth S. Dy, P. 95 (In 2004)

### ២.២.៦ សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩ ដល់ ១៩៨៩)

បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ ប្រទេសកម្ពុជាក៏បានឆ្លងកាត់ទៅរបបមួយថ្មីទៀតគឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលទទួលបានការគាំទ្រពីកុំម្មុយនីស្តវៀតណាម និងបណ្តាប្រទេសប្លុកសង្គមនិយមផ្សេងទៀត។ រដ្ឋាភិបាលនៃរបបនេះបានខិតខំស្តារប្រទេសជាតិដែលរងនូវការបំផ្លិចបំផ្លាញយ៉ាងដំណំឡើងវិញ។ តាមរយៈឯកសារស្រាវជ្រាវរបស់លោក Sideth S. Dy បានបញ្ជាក់ថា នៅចន្លោះឆ្នាំ ១៩៧៩ ដល់១៩៨១ គោលនយោបាយរបស់រដ្ឋាភិបាល គឺផ្តោតសំខាន់ទៅលើការកសាងឡើងវិញនូវវិស័យអប់រំដោយមានការគាំទ្រពីសំណាក់អង្គការ UNICEF and International Red Cross ។ ជាលទ្ធផលគេសង្កេតឃើញថាមានការកសាងឡើងវិញនូវស្ថាប័នអប់រំចំនួន ៦០០០ស្ថាប័ន ហើយគ្រូបង្រៀនរាប់សែននាក់ត្រូវបានបណ្តុះបណ្តាលឡើងវិញសម្រាប់រយៈពេលខ្លី។ នាសម័យកាលនោះ គឺរដ្ឋាភិបាលយកចិត្តទុកដាក់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។ ក្មេងៗដែលគ្រប់អាយុត្រូវបានបញ្ជូនឲ្យទៅសិក្សានៅសាលារៀនវិញ ប៉ុន្តែថ្នាក់រៀននៅពេលនោះគឺពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ដោយសិស្សមួយចំនួនត្រូវរៀននៅក្រៅអគារ និងក្រោមដើមឈើជាដើម។ ម្យ៉ាងវិញទៀតរដ្ឋាភិបាលក៏បានអំពាវនាវដល់គ្រូបង្រៀន និងអ្នកចេះអក្សរទាំងអស់ ដើម្បីបង្រៀនដល់អ្នកមិនចេះអក្សរ ដោយមិនទាមទារនូវលក្ខខណ្ឌអ្វីច្រើននោះទេ។ មួយវិញទៀតក្នុងរបបនោះក៏មានការលើកឡើងនូវពាក្យស្លោកដូចជា ទៅបង្រៀន និងទៅរៀន គឺស្នេហាជាតិ។ ដោយកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការកសាងប្រទេស មកទល់នឹងឆ្នាំ១៩៨៩ គេឃើញមានកំណើននៃការចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សារហូតដល់ ១,៣លាននាក់ និងថ្នាក់អនុវិទ្យាល័យរហូតដល់ ០,២៥លាននាក់ ធៀបជាមួយឆ្នាំ១៩៨០ ដែលសិស្សបឋមសិក្សាមាន ០,៩លាននាក់ និងសិស្សអនុវិទ្យាល័យ ៤ ៨០០នាក់ នេះបើយោងតាមតួលេខក្រសួងអប់រំ យុវជន និងកីឡា កាលពីឆ្នាំ១៩៩៩។ នាពេលនោះមានសិស្សចំនួន ៣០ ភាគរយដែលកំព្រាឪពុក ១០ ភាគរយកំព្រាម្តាយ និងចន្លោះពី ៥ទៅ១០ ភាគរយជាក្មេងកំព្រា។

### ២.២.៧ សម័យព្រះរាជាណាចក្រកម្ពុជាទី២ (១៩៩៣ ដល់ បច្ចុប្បន្ន)

មកទល់នឹងបច្ចុប្បន្ន ប្រព័ន្ធអប់រំកម្រិតចំណេះទូទៅនៅកម្ពុជា បានអនុវត្តតាមប្រព័ន្ធ ៦-៣-៣ គឺមានរយៈពេល៦ឆ្នាំសម្រាប់បឋមសិក្សា(ថ្នាក់ទី១ ដល់ ថ្នាក់ទី៦) ៣ឆ្នាំសម្រាប់អនុវិទ្យាល័យ(ថ្នាក់ទី៧ ដល់ ថ្នាក់ទី៩) និង៣ឆ្នាំសម្រាប់វិទ្យាល័យ(ថ្នាក់ទី១០ ដល់ថ្នាក់ទី១២)។ សម្រាប់ថ្នាក់ឧត្តមសិក្សា និងនិស្សិតដែលរៀនមុខវិជ្ជាបម្រើក្នុងវិស័យរដ្ឋបាល សេវាកម្ម និងគ្រប់គ្រងត្រូវសិក្សារយៈពេល ៤ឆ្នាំ សម្រាប់ថ្នាក់បរិញ្ញាបត្រ ឬលើសពី៤ឆ្នាំ សម្រាប់មុខវិជ្ជាបច្ចេកទេសស៊ីជម្រៅមួយចំនួនដូចជា ស្ថាបត្យកម្ម វិស្វករ

វេជ្ជបណ្ឌិត ជាដើម។[14] បច្ចុប្បន្ននេះប្រព័ន្ធអប់រំស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ប៉ុន្តែក៏មានការចូលរួមចំណែកពីវិស័យឯកជនផងដែរ។ សាលាឯកជនផ្តោតលើការអប់រំថ្នាក់មត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ ហើយចំពោះការអប់រំថ្នាក់ឧត្តមសិក្សាភាគច្រើនគឺបើកដំណើរការនៅក្នុងរាជធានី ប៉ុន្តែក៏មាននៅតាមបណ្តាខេត្តមួយចំនួនផងដែរ។

យោងតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ការអប់រំសម័យបច្ចុប្បន្ននេះរួមមានៈ

**ក. ការគាំពារ និងអប់រំកុមារតូច**

រដ្ឋត្រូវគាំពារ និងអប់រំកុមារតូច ចាប់ពីកម្រិតសូន្យឆ្នាំមុនមត្តេយ្យសិក្សា ដែលជាទូទៅប្រព្រឹត្តនៅទារកដ្ឋាននៅសហគមន៍ ឬ នៅផ្ទះ។ ការអប់រំមត្តេយ្យសិក្សា ត្រូវចាប់អនុវត្តមុនបឋមសិក្សា ដើម្បីត្រៀមលក្ខណៈចូលបឋមសិក្សា ។[15]

**ខ. ការអប់រំចំណេះទូទៅរួមមាន**[16]:

- ការអប់រំបឋមសិក្សា ឬ ភូមិសិក្សាទី១ ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬ ការអប់រំកម្រិតសមមូល។

ការអប់រំបឋមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានដំបូងចាំបាច់ ដើម្បីឲ្យអ្នកសិក្សាអាចបន្តការសិក្សានៅមធ្យមសិក្សា។

- ការអប់រំមធ្យមសិក្សា ឬ ភូមិសិក្សាទី២ ចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ១២។ ការអប់រំមធ្យមសិក្សាមានពីរដំណាក់កាល ដំណាក់កាលទី១ មធ្យមសិក្សាបឋមភូមិចាប់ពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ និងដំណាក់កាលទី ២ មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទ ១០ ដល់ថ្នាក់ទី ១២។

ការអប់រំមធ្យមសិក្សា ត្រូវបណ្តុះបណ្តាលបុគ្គលិកលក្ខណៈពេញលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅឧត្តមសិក្សា ឬបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គម។

ការអប់រំកម្រិតមូលដ្ឋាន ត្រូវកំណត់ ៩ឆ្នាំ ចាប់ពីថ្នាក់ទី ១ ដល់ថ្នាក់ទី ៩ នៃការអប់រំចំណេះទូទៅក្នុងប្រព័ន្ធ ឬ ការអប់រំកម្រិតសមមូល។

[14] Strategies and Policies for Basic Education in Cambodia: Historical Perspectives Sideth S. Dy, P. 96 (In 2004)

[15] ច្បាប់ស្តីពីការអប់រំ មាត្រា១៦ ជំពូកទី៤ ទំព័រទី៥ (ឆ្នាំ២០០៧)

[16] ច្បាប់ស្តីពីការអប់រំ មាត្រា១៧ ជំពូកទី៤ ទំព័រទី៥និង៦ (ឆ្នាំ២០០៧)

**គ. ការអប់រំឧត្តមសិក្សា**[17]

ការអប់រំឧត្តមសិក្សា ឬ ភូមិសិក្សាទី ៣ ជាការអប់រំកម្រិតក្រោយមធ្យមសិក្សា នៅគ្រឹះស្ថានឧត្តមសិក្សា។

ការអប់រំឧត្តមសិក្សា ត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញ និងជំរុញការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ និងសង្គម ដើម្បីឲ្យមានសមត្ថភាពខ្ពស់ទាំងចំណេះដឹង ជំនាញ សីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាពសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ។

ក្របខណ្ឌ និង លក្ខណៈនៃកម្រិតសញ្ញាបត្រ និងវិញ្ញាបនបត្រ ត្រូវកំណត់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ។ គ្រឹះស្ថានឧត្តមសិក្សាមាន ២ ប្រភេទគឺ សាកលវិទ្យាល័យ និងវិទ្យាស្ថាន។

**ឃ. ការបណ្ដុះបណ្ដាលបុគ្គលិកអប់រំ**[18]

រដ្ឋត្រូវបណ្ដុះបណ្ដាលបុគ្គលិកអប់រំមុនពេល និង/ឬ ក្នុងពេលកំពុងបម្រើការងារ។

បុគ្គលិកអប់រំត្រូវឆ្លងកាត់ការបណ្ដុះបណ្ដាលគរុកោសល្យ ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យអប់រំ លើកលែងតែសាស្ត្រាចារ្យ និងបុគ្គលិកដែលបម្រើក្នុងស្ថាប័នថ្នាក់ឧត្តមសិក្សា។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកំណត់កម្មវិធីគោល សម្រាប់ការបណ្ដុះបណ្ដាលបុគ្គលិកអប់រំ កំណត់កាយសម្បទា និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើសបុគ្គលិកអប់រំសាធារណៈ និងឯកជន។

## ២.៣ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំ

យោងតាមព្រះរាជក្រមលេខ នស/រកម/០៧១៩/០១១ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ៖ ត្រង់ចំណុច១.១០ នៃសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ បានលើកបង្ហាញថា យុទ្ធសាស្ត្រចតុកោណ បានផ្ដោតការយកចិត្តទុកដាក់ជាថ្មីទៅលើការបង្កើនផលិតភាព និងការប្រកួតប្រជែងដើម្បីឈានទៅប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់។ ស្នូលនៃយុទ្ធសាស្ត្រចតុកោណគឺ ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ច ការពង្រឹងស្ថាប័នសាធារណៈដែលមានភាពស្អាតស្អំ ដំណើរការប្រជាធិបតេយ្យ និងនីតិរដ្ឋ។ ខ្លឹមសារចំនួន៣ដែលគាំទ្រដល់ស្នូលនៃយុទ្ធសាស្ត្រនេះគឺ គណនេយ្យភាព ប្រព័ន្ធនៃការឆ្លើយតប ការផ្សារភ្ជាប់ទៅនឹងអាណត្តិ និងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន

[17] ច្បាប់ស្ដីពីការអប់រំ មាត្រា១៨ ជំពូកទី៤ ទំព័រទី៦ (ឆ្នាំ២០០៧)

[18] ច្បាប់ស្ដីពីការអប់រំ មាត្រា២០ ជំពូកទី៤ ទំព័រទី៧ (ឆ្នាំ២០០៧)

របស់រាជរដ្ឋាភិបាលត្រូវបានគួបផ្សំជាមួយនឹងប្រសិទ្ធភាព ការពង្រឹងធនធានមនុស្ស ការសម្រួលដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការប្រើប្រាស់បច្ចេកវិទ្យាឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤បានផ្តល់ឲ្យនូវកាលានុវត្តភាពប្រសើរឡើងសម្រាប់មនុស្សគ្រប់រូប ជាពិសេសក្រុមងាយរងគ្រោះ ការកែលម្អរសេវាសាធារណៈរួមជាមួយការការពារធនធានធម្មជាតិ និងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

រូបភាព១ ៖ គំនូសបំប្រួញយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤



ប្រភព ៖ សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ទំព័រ ២៣៦-២៣៨ (ឆ្នាំ ២០១៩)

### ក. គោលនយោបាយអាទិភាពសំខាន់ៗសម្រាប់នីតិកាលទី៦[19]

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលគឺ អភិវឌ្ឍ "**ប្រពន្ធ័អប់រំប្រកបដោយ គុណភាព គុណធម៌ សមធម៌ និង បរិយាប័ន្ន**" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ក្នុងការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ការទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

ទន្ទឹមនឹងសមិទ្ធផលពីនីតិកាលរដ្ឋសភាទី៥មកកម្ពុជាក៏ជួបនូវបញ្ហាមួយចំនួនជាអាទិ៍: លទ្ធផលនៃ

[19] សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ទំព័រ ២៣៤ (ឆ្នាំ២០១៩)

ការសិក្សានៅគ្រប់កម្រិត នៅមិនទាន់បានដូចអ្វីដែលបានរំពឹងទុកនៅឡើយ រាជរដ្ឋាភិបាលចង់អោយអត្រាសិស្សដែលបោះបង់ការសិក្សាធ្លាក់ចុះ អភិបាលកិច្ចសាលារៀន និងវិសាលភាពគ្របដណ្តប់នៃបច្ចេកវិទ្យាកាន់តែប្រសើរ ការចូលរួមពីវិស័យឯកជនអោយបានទូលំទូលាយ ការអប់រំឆ្លើយតបពេញលេញទៅនឹងទីផ្សារការងារ និងការរស់នៅ គុណភាពឧត្តមសិក្សាធៀបទៅនឹងតម្រូវការ និងស្តង់ដារតំបន់ ព្រមទាំងប្រសិទ្ធភាពនៃការគ្រប់គ្រង និង អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា។ លើសពីនេះវិស័យកីឡាពង្រឹងថែមទៀត ទាំងអប់រំកាយ និងត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះនៃការប្រកួតស៊ីហ្គេមឆ្នាំ២០២៣។

ក្នុងនីតិកាលទី៦នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលនិងផ្តោតទៅលើ[20]៖

**ទី១** ការបន្តដំឡើងបៀវត្ស និងប្រាក់លើកទឹកចិត្តផ្អែកតាមសមិទ្ធកម្មជូន គ្រូបង្រៀន និងបុគ្គលិកអប់រំ ការលើកកម្ពស់សមត្ថភាពនាយក ដោយផ្សារភ្ជាប់សមិទ្ធកម្មទៅនឹងថវិការសាលារៀន ការលើកកម្ពស់គុណវឌ្ឍិគ្រូបង្រៀន សមត្ថភាពបង្រៀន និងអាជីពគ្រូបង្រៀនតាមរយៈការបណ្តុះបណ្តាល និងវិក្រឹត្យការគ្រូបង្រៀនយ៉ាងតិច កម្រិតបរិញ្ញាបត្រ ការពង្រាយគ្រូបង្រៀន សមត្ថភាពខ្ពស់ទៅតាមតំបន់ខ្វះគ្រូបង្រៀន និងបង្កើនការជួយដល់សិស្សដែលរៀនខ្សោយ ដោយលើកទឹកចិត្តតាមការជាក់ស្តែង និងការស្រាវជ្រាវ អភិវឌ្ឍវិធីសាស្ត្របង្រៀន និងរៀនតាមបែបថ្មី ការអនុវត្តការកែទម្រង់ការប្រលង ការវាយតម្លៃសិក្សាអោយបានទៀងទាត់ ការបង្កើនការវិនិយោគលើសម្ភារសិក្សា ឧបករណ៍ពិសោធន៍ និងបរិក្ខារបង្រៀន ពិសេសពង្រីកវិសាលភាពសាលាជំនាន់ថ្មី និងលើកកម្ពស់ការចូលរួមរបស់សហគមន៍ និងមាតាបិតាសិស្ស។

**ទី២** ការបន្តការកសាងបឋមសិស្សឲ្យបានដល់ភូមិ និងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំតាមការចាំបាច់ផ្អែកលើស្ថានភាពសង្គម-សេដ្ឋកិច្ច ការផ្តល់អាហារូបករណ៍ និងមធ្យោបាយទ្រទ្រង់ចាំបាច់ផ្សេងៗ ដល់សិស្សក្រីក្រសិស្សដែលស្ថិតនៅក្នុងតំបន់ជួបការលំបាក និងសិស្សមានពិការភាព ការរៀបចំយុទ្ធនាការផ្សព្វផ្សាយ ទូទាំងប្រទេសអំពីសារប្រយោជន៍នៃការសិក្សាមូលដ្ឋាន ការបង្កើនវិនិយោគដើម្បីអភិវឌ្ឍកុមារតូច និងការបង្កើតថ្នាក់មត្តេយ្យសិក្សាគ្រប់រូបភាព ព្រមទាំងជំរុញទឹកចិត្តឲ្យមានប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតាមដានសិស្ស សំដៅដល់កិច្ចអន្តរាគមន៍ឲ្យទាន់ពេលវេលាតាមគ្រប់មធ្យោបាយដើម្បីទប់ស្កាត់នូវការបោះបង់ការសិក្សារបស់សិស្សានុសិស្ស។

**ទី៣** ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលាសំដៅធានាដល់ការបង្រៀនឲ្យបានពេញលេញទៅតាមកម្មវិធីសិក្សា និងបង្កើនគុណភាពអភិបាលកិច្ចសាលារៀន ដោយរៀបចំអោយមានយន្តការចូលរួមជាប្រចាំពីអ្នកដែលមានចំណែកពាក់ព័ន្ធ និងបង្កើតអោយមានប្រអប់ទទួលព័ត៌មាន រៀបចំប្រព័ន្ធ

[20] សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ទំព័រ ២៣៥-២៣៦ (ឆ្នាំ២០១៩)

ពិនិត្យ តាមដានដំណើរការសាលារៀន ព្រមទាំងរៀបចំប្រព័ន្ធឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា។

**ទី៤** ការធ្វើបច្ចុប្បន្នភាព និងការជំរុញការអនុវត្តផែនការគោលសម្រាប់អភិវឌ្ឍការអប់រំបច្ចេកទេសសិក្សានៅមធ្យមសិក្សាទុតិយភូមិ សំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និងពង្រីកការអប់រំឲ្យមានវិសាលភាពគ្រប់ដណ្ដប់ទូទាំងប្រទេសតាមទស្សនទាន *" ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ បច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលមធ្យម និង ស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិចសម្រាប់រយៈពេលវែង "* ព្រមទាំងលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាង រដ្ឋ និងឯកជន។

**ទី៥** ការបង្កើនភាពឆ្លើយតបឲ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ និងការរស់នៅតាមទស្សនទាន *" យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត "* ដោយរៀបចំកម្មវិធីបង្កើនគំនិតសហគ្រិនភាព និងភាសាបរទេស ពង្រឹងការអប់រំផ្នែក STEM ដោយបង្កើតឲ្យមានមជ្ឈមណ្ឌលអប់រំ និងវិទ្យាសាស្ត្រ បន្តជំរុញកម្មវិធីបំណិនជីវិត ពិសេសកម្មវិធីយុវជនក្នុងភាពជាអ្នកដឹកនាំ សីលធម៌ និងសុជីវធម៌ក្នុងការរស់នៅ ការចូលរួមការងារសង្គម បរិស្ថាន និងការអភិវឌ្ឍ ព្រមទាំងបន្តបង្កើតក្រុមប្រឹក្សាកុមារ និងយុវជនអោយបានគ្រប់សាលារៀន។

**ទី៦** ការរៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាគោលគ្រប់ជ្រុងជ្រោយ រួមទាំងបញ្ចូល STEM និង វិទ្យាសាស្ត្រសង្គមគន្លឹះៗសម្រាប់ឧត្តមសិក្សាស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារតំបន់ និងអន្តរជាតិ ការពង្រឹងយន្តការទទួលស្គាល់គុណភាពឧត្តមសិក្សា ការបង្កើនចំនួនសាស្ត្រចារ្យកម្រិតបណ្ឌិតប្រកបដោយគុណភាពឧត្តមសិក្សា ការបង្កើនការវិនិយោគលើឧត្តមសិក្សា និងបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិសំដៅអភិវឌ្ឍមូលនិធិអាហារូបករណ៍ និងឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា ការជំរុញការអភិវឌ្ឍសមត្ថភាព និងធនធានសម្រាប់គាំទ្រការរៀន ការបង្រៀន និងការសិក្សាស្រាវជ្រាវ ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវ និងយន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ ព្រមទាំងការបង្កើតក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ច និងការគ្រប់គ្រងឧត្តមសិក្សា។

**ទី៧** ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣ ដោយបន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធកីឡាសំខាន់ៗ រៀបចំប្រភេទកីឡាអាទិភាព បណ្តុះបណ្តាលគ្រូបង្វឹក និងបច្ចេកទេសកីឡាកម្រិតខ្ពស់ ពង្រឹងការបណ្តុះបណ្តាល

និងការហ្វឹកហាត់កីឡាករ-កីឡាការិនីថ្នាល និង ជំរុញចលនា " ***យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត*** " និងរៀបចំវិទ្យាសាស្ត្រសុខាភិបាលកីឡាដើម្បីគាំទ្រដំណើរការប្រកួតកីឡាស៊ីហ្គេម។

**ខ. សកម្មភាព កម្មវិធី និងគម្រោងសំខាន់ៗសម្រាប់អនុវត្តគោលនយោបាយអាទិភាព**[21]

ដើម្បីអនុវត្តគោលនយោបាយជាអាទិភាពក្នុងនីតិកាលទី៦នៃរដ្ឋសភាពនេះ ***ក្រសួងអប់រំ យុវជន និងកីឡា*** បានដាក់ចេញគោលនយោបាយអប់រំរយៈពេលមធ្យមពីរ និងអាទិភាពកំណែទម្រង់នានា តាមរយៈ **ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣** ឆ្ពោះទៅរួមចំណែកក្នុងការអនុវត្តអាទិភាពរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

**គោលនយោបាយទី១៖** ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

**គោលនយោបាយទី២៖** ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ក្រសួងបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដោយផ្តោតលើសសរស្តម្ភ៥៖ (១) ការអនុវត្តសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការពិនិត្យឡើងវិញពីកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថាន (៣)ការដាក់ឲ្យអនុវត្តអធិការកិច្ច (៤)ការពង្រឹងវង្វាយតម្លៃការសិក្សា និង (៥)ការកែទម្រង់ឧត្តមសិក្សា ដូចខាងក្រោម៖

- **យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ៖** (១)កំណែទម្រង់ការគ្រប់គ្រងការសិក្សាផ្តោតលើវង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ការកែលម្អវិធីសាស្ត្របង្រៀន និងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (២)កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាលផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ (៣)កំណែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតលើការបង្កើនស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ និងកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សផ្តោតលើការបណ្តុះបណ្តាលលើវិធីសាស្ត្របង្រៀន និង (៤)កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សផ្តោតលើការបណ្តុះបណ្តាលដោយផ្តោតលើ

[21] សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ទំព័រ ២៣៦-២៣៨ (ឆ្នាំ២០១៩)

វិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។

- **យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា៖** (១)ពិនិត្យលទ្ធភាពប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល (២)ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស (៣)រៀបចំក្របខ័ណ្ឌកម្មវិធីសិក្សាឲ្យឆ្លើយតបទៅនឹងការវិវត្តន៍ឧស្សាហកម្ម (៤)ជំរុញការស្រាវជ្រាវ និងលើកទឹកចិត្តការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និង(៥)វាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា។
- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន៖** (១)ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាព និងសមធម៌ (២)លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព (៣)អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាព និងសុខដុមនីយកម្ម (៤)បង្កឱកាសឲ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានានៅក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ (៥)ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន។
- **យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា៖** (១)អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និង គតិយុត្ត (២)អភិវឌ្ឍកីឡាកម្រិតខ្ពស់ (៣)ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា (៤)អភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅគ្រប់គ្រឹះស្ថានសិក្សា និងសហគមន៍ (៥)អភិរក្ស និងអភិវឌ្ឍគ្រប់ប្រភេទ។

## ២.៤ ចក្ខុវិស័យ និងបេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា** គឺ កសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយទៅជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។[22]

**បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា៖** ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឲ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ សេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា

[22] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ទំព័រ ២៦ (ឆ្នាំ២០១៩)

និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក។[23]

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឲ្យមានមនសិការស្នេហាជាតិ មោទនភាពជាតិ សីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។[24]

**វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា** គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹង ជំនាញ វិជ្ជាជីវៈ សមត្ថភាព គុណធម៌ និងសីលធម៌ល្អ ស្របតាមស្តង់ដារមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។[25]

ដើម្បីអោយសម្រេចបាននូវចក្ខុវិស័យស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រកំណែទម្រង់ លើក្រសួងអប់រំ យុវជន និងកីឡានឹងផ្តោតលើយុទ្ធសាស្ត្រអាទិភាពដូចខាងក្រោម[26]៖

**ក. ការអប់រំកុមារតូច**

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន
- លើកកម្ពស់គុណភាពសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដារ
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច

**ខ. ការអប់រំបឋមសិក្សា**

- វិធានការបង្កើនការចូលរៀនអោយបានទៀងទាត់ និងរៀនចប់បឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាស្អាត និងមានសុវត្ថិភាពស្របតាមស្តង់ដារសាលាបឋមសិក្សា ជាពិសេសសាលារៀមិនគ្រប់កម្រិត និងសាលារៀនជួបការលំបាក

[24] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ទំព័រ ២៦ (ឆ្នាំ២០១៩)

[25] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ទំព័រ ២៦ (ឆ្នាំ២០១៩)

[26] សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ទំព័រ ២៣៨-២៤២ (ឆ្នាំ២០១៩)

- លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនដែលមានស្រាប់ និងកែលម្អការពង្រាយគ្រូ
- ពង្រឹងសមត្ថភាពគ្រូបង្រៀន និងអ្នកពាក់ព័ន្ធលើកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលសម្រាប់គ្រូបឋមសិក្សា
- កែលម្អការផ្គត់ផ្គង់ ការប្រើប្រាស់សៀវភៅសិក្សាគោល សម្ភារៀន និងបង្រៀន
- ពង្រឹងការងារអធិការកិច្ច ការពិនិត្យតាមដាន និងវាយតម្លៃពីគ្រប់កម្រិតថ្នាក់
- ពង្រឹងការអនុវត្តការគ្រប់គ្រងតាមសាលារៀន

**គ. ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស**

- វិធានការកែលម្អការចូលរៀន និងរក្សាឲ្យបានគង់វង្សនៅមធ្យមសិក្សា ជាពិសេសក្រុមជួបការលំបាក
- ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តសម្រាប់សាលាមធ្យមសិក្សា
- ពង្រឹង និងពង្រីកមុខវិជ្ជាវិទ្យាសាស្ត្រស្ទែម និងភាសាបរទេសដើម្បីឆ្លើយតបទៅនឹងក្របខ័ណ្ឌជំនាញសតវត្សទី២១
- ជំរុញការអនុវត្តក្របខ័ណ្ឌកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព
- ពង្រឹងអភិក្រមការគ្រប់គ្រងតាមសាលារៀននៅកម្រិតសាលារៀន
- ពង្រីកការអនុវត្តស្តង់ដារគំរូសាលារៀនជំនាន់ថ្មី
- អភិវឌ្ឍក្របខ័ណ្ឌធានាគុណភាពអប់រំរបស់សាលារៀននៅមធ្យមសិក្សា
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៃអធិការកិច្ចនៅតាមសាលារៀន
- ពង្រីកភាពជាដៃគូរជាមួយវិស័យឯកជន និងសហគ្រាស ដើម្បីពង្រឹងការអប់រំបច្ចេកទេស
- ពង្រឹងតម្រង់ទិសការសិក្សាឆ្ពោះទៅរកអាជីព និងពង្រីកការអប់រំបច្ចេកទេស។

**ឃ. ការអប់រំឧត្តមសិក្សា**

- បង្កើនការវិនិយោគលើកម្មវិធីអប់រំឧត្តមសិក្សាអទិភាព ដោយផ្អែកលើលទ្ធផល
- កែលម្អសមត្ថភាពនៃការបង្រៀននិងរៀន និងការស្រាវជ្រាវ តាមរយៈការបង្កើតភាពជាដៃគូឧត្តមសិក្សា
- ពង្រីកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សរបស់គ្រឹះស្ថានឧត្តមសិក្សាឆ្ពោះទៅទទួលបានស្វ័យភាពពេញលេញ
- កែលម្អប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សា។

**ង. ការអប់រំក្រៅប្រព័ន្ធ**

- អភិវឌ្ឍ និងកែលម្អរកម្មវិធីអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ
- ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងការចូលរួមគាំទ្រដល់កម្មវិធី អប់រំក្រៅប្រព័ន្ធរបស់អ្នកពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌនៃការសិក្សាពេញមួយជីវិត
- កែលម្អរប្រសិទ្ធភាព និងគុណភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់។

**ច. ការអភិវឌ្ឍយុវជន**

- ពង្រឹងជំនាញឌីជីថល និងលើកកម្ពស់ចំណេះដឹងអនុវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យាសម្រាប់យុវជនដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤
- បង្កើនការបណ្តុះទម្លាប់នៃការគិតបែបច្នៃប្រឌិត និងការបង្កើតថ្មីតាមរយៈស្មារតីសហគ្រិនភាព ការលើកកម្ពស់ការប្រកបមុខរបរដោយខ្លួនឯង និងលទ្ធភាពទទួលបានសេវាណែនាំអាជីវកម្ម ការងារ និងព័ត៌មានទីផ្សារ
- អភិវឌ្ឍយុវជនឲ្យបានពេញលេញ និងអប់រំពួកគេឲ្យចេះរស់នៅជាមួយគ្នាក្នុងសន្តិភាព និងសុខដុមនីយកម្ម ប្រកបដោយស្មារតីស្នេហាជាតិ ស្រលាញ់ប្រជាជន ជឿជាក់ និងផ្តល់តម្លៃខ្ពស់ឲ្យខ្លួនឯង មានភាពជាអ្នកដឹកនាំ និងការយល់ដឹងទូលំទូលាយអំពីសង្គម
- លើកទឹកចិត្តយុវជនឲ្យចែករំលែកការយល់ឃើញទស្សនវិស័យ និងចូលរួមក្នុងដំណើរការសម្រេចចិត្តពាក់ព័ន្ធនឹងការអភិវឌ្ឍសហគមន៍ និងសង្គម
- ប្រែក្លាយមជ្ឈមណ្ឌលយុវជនអោយក្លាយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមសហគមន៍។

**ឆ. ការអភិវឌ្ឍអប់រំកាយ និងកីឡា**

- អភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងគតិយុត្ត
- អភិវឌ្ឍកីឡាគ្រប់កម្រិតខ្ពស់
- អភិវឌ្ឍកីឡាសម្រាប់អ្នកទាំងអស់គ្នា
- អភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅគ្រប់គ្រឹះស្ថានសិក្សា និងសហគមន៍
- អភិរក្ស និងអភិវឌ្ឍកីឡាគ្រប់ប្រភេទលើកទឹកចិត្តឲ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងមហាជនចូលរួមលេងកីឡា

- បំផុសសកម្មភាពអប់រំកាយ និងកីឡានៅក្នុងសាលា
- ពង្រឹង និងលើកទឹកចិត្តដល់សហព័ន្ធកីឡា
- បន្តការជួសជុល កែលម្អរហេដ្ឋារចនាសម្ព័ន្ធកីឡា ជាពិសេសពហុកីឡាដ្ឋានជាតិ កីឡាដ្ឋានជាតិនៅតាមខេត្ត វិទ្យាស្ថានជាតិអប់រំកាយនិងកីឡា និងគ្រឹះស្ថានសិក្សា
- បន្តបណ្តុះបណ្តាលថ្នាលនិស្ស័យកីឡា និងហាត់ហ្វឹកហ្វឺន ដើម្បីត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣។

តារាង១៖ សូចនាករ និងចំនុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំយុវជន និងកីឡា

| ល.រ | សូចនាករសំខាន់ៗ ក្នុងវិស័យអប់រំ | ឯកតា | ២០១៨ ជាក់ស្តែង | ២០១៩ ប៉ាន់ស្មាន | ២០២០ ព្យាករណ៍ | ២០២១ ព្យាករណ៍ | ២០២២ ព្យាករណ៍ | ២០២៣ ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|
| | កម្មវិធីទី១៖ ការអភិវឌ្ឍការអប់រំ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ | | | | | | | |
| ១ | ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូច នៅគ្រប់រូបភាព | % | ៥៨ | ៥៩,៦ | ៦០,៨ | ៦១,៨ | ៦២,៤ | ៦៤,៥ |
| ២ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,២ | ៩៨,៣ | ៩៨,៥ |
| | ប្រុស | % | ៩៧,៦ | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,២ | ៩៨,៥ |
| | ស្រី | % | ៩៨,១ | ៩៨,៣ | ៩៨,៥ | ៩៨,៦ | ៩៨,៧ | ៩៩ |
| | ទីប្រជុំជន | % | ១០២,៨ | ១០២,១ | ១០១,៦ | ១០១,២ | ១០០,៩ | ១០០ |
| | ជនបទ | % | ៩៦,៧ | ៩៧,០ | ៩៧,៣ | ៩៧,៥ | ៩៧,៦ | ៩៨ |
| ៣ | អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ១១៣,៧ | ១១២,៣ | ១១១,២ | ១១០,៤ | ១០៩,៨ | ១០៨ |
| | ប្រុស | % | ១១៤,៦ | ១១៣,២ | ១១២,៣ | ១១១,៤ | ១១០,៤ | ១០៩ |
| | ស្រី | % | ១១២,៩ | ១១១,៤ | ១១០,៣ | ១០៩,៥ | ១០៨,៩ | ១០៧ |
| ៤ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | |
| | សរុប | % | ៨២,៧ | ៨៣,៣ | ៨៣,៧ | ៨៤,០ | ៨៤,៣ | ៨៥ |
| | ប្រុស | % | ៧៩,១ | ៨០,៣ | ៨១,២ | ៨១,៩ | ៨២,៤ | ៨៤ |
| | ស្រី | % | ៨៦,៤ | ៨៧,១ | ៨៧,៥ | ៨៧,៩ | ៨៨,២ | ៨៩ |
| ៥ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | |
| | សរុប | % | ៥៩,២ | ៦១,១ | ៦២,៥ | ៦៣,៥ | ៦៤,៣ | ៦៦,៧ |
| | ប្រុស | % | ៥៥,២ | ៥៧,៧ | ៥៩,៥ | ៦០,៩ | ៦១,៩ | ៦៥ |
| | ស្រី | % | ៦៣,៤ | ៦៥,៦ | ៦៧,២ | ៦៨,៤ | ៦៩,៣ | ៧២ |
| | ទីប្រជុំជន | % | ៦៧ | ៦៨,៨ | ៧០,១ | ៧១,០ | ៧១,៨ | ៧៤ |
| | ជនបទ | % | ៦១ | ៦៣,០ | ៦៤,៥ | ៦៥,៦ | ៦៦,៥ | ៦៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | |
| | សរុប | % | ៤៦,៥ | ៤៨,៩ | ៥០,៧ | ៥២,០ | ៥៣,០ | ៥៦ |
| | ប្រុស | % | ៤២,៣ | ៤៤,២ | ៤៥,៥ | ៤៦,៨ | ៤៧,៦ | ៥០ |
| | ស្រី | % | ៥១,១ | ៥២,៨ | ៥៤,១ | ៥៥,១ | ៥៥,៨ | ៥៨ |
| ៧ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| | សរុប | % | ២៨,៥ | ៣០,៩ | ៣២,៧ | ៣៤,០ | ៣៥,០ | ៣៨ |
| | ប្រុស | % | ២១,៩ | ២៤,៥ | ២៦,៣ | ២៧,៨ | ២៨,៨ | ៣២ |
| | ស្រី | % | ៣០,៩ | ៣៣,២ | ៣៤,៩ | ៣៦,២ | ៣៧,១ | ៤០ |
| ៨ | អត្រាអក្ខរកម្មជនពេញវ័យ (១៥ឆ្នាំឡើង) | % | ៨២,៥ | ៨៣,១ | ៨៣,៦ | ៨៣,៩ | ៨៤,២ | ៨៥ |
| ៩ | អត្រាបញ្ចប់នៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | |
| | សរុប | % | ២៣,៦ | ២៥,២ | ២៦,៤ | ២៧,៣ | ២៨,០ | ៣០ |
| | ប្រុស | % | ២១,៩ | ២៣,៤ | ២៤,៦ | ២៥,៤ | ២៦,១ | ២៨ |
| | ស្រី | % | ២៥,៣ | ២៧,២ | ២៨,៧ | ២៩,៨ | ៣០,៦ | ៣៣ |
| ១០ | យុគភាពយេនឌ័រ នៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សទុតិយភូមិ | GPI | ១,១៨ | ១,១៤ | ១,១១ | ១,០៩ | ១,០៨ | ១,០៣ |
| | កម្មវិធីទី២៖ ការអភិវឌ្ឍឧត្តមសិក្សា និងការស្រាវជ្រាវ | | | | | | | |

ប្រភព ៖ សេចក្ដីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ ឆ្នាំ២០១៩

## ២.៥ គោលនយោបាយនៃការអប់រំនៅប្រទេសកម្ពុជា

ដើម្បីអភិវឌ្ឍសមត្ថភាពយុវជនកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា នឹងបណ្ដុះស្មារតីយុវជនកម្ពុជាគ្រប់រូបឲ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិនិងប្រជាពលរដ្ឋរបស់ខ្លួន។

ក្រសួងអប់រំ យុវជននិងកីឡាបានកំណត់គោលបំណងនៃគោលនយោបាយពីរធំគឺ[27]៖

**គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។** កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត ព្រមទាំង នូវ

[27] ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ២០១៩-២០២៣ ទំព័រ ២៧

ជម្រើសផ្សេងទៀតដល់កុមារ និងយុវជនដែលពុំមានលទ្ធភាពទទួលបានសេវាអប់រំក្នុងប្រព័ន្ធ។ កុមារ យុវជនគ្រប់រូបទទួលបានលទ្ធផលសិក្សានៅគ្រប់កម្រិតប្រកបដោយគុណភាព សមធម៌ និង បរិយាបន្ន ជាពិសេស កុមារមកពីគ្រួសារជួបការលំបាក យុវជនក្រៅសាលា និងទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេស បំណិនគិត និងបំណិនអរូបវន្ត ឆ្លើយតបនឹងបរិបទសង្គមពុទ្ធិ និងវិបុលភាព និង ការអភិវឌ្ឍ សេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សាត្រូវមានការគាំទ្រ និងចូល រួមពីមាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រងជាមួយនឹងស្តង់ដារនៃផលសម្រេចការពិនិត្យតាមដាន និងរបាយការណ៍។

**គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ ថ្នាក់ ។** ការផ្តល់សេវាអប់រំអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយភាពស័ក្តិ សិទ្ធិផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា ការពិនិត្យ តាមដាន និងរបាយការណ៍ សមិទ្ធកម្ម និងយោបល់ត្រឡប់ វិធានការណ៍ប្រកបដោយគណនេយ្យភាព និងយន្តការសម្រាប់កែលម្អរ គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សា ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ត្រូវបង្កើនស្វ័យភាព និងទទួលខុសត្រូវគណនេយ្យភាពចំពោះ លទ្ធផលនៃការសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា ។

## ២.៦ ការចូលរួមរបស់វិស័យអប់រំក្នុងការអភិវឌ្ឍជាតិ[28]

ការអភិវឌ្ឍជាតិ គឺពឹងផ្អែកលើការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច សំដៅលើដំណើរការដែលមាន សុខមាលភាពសេដ្ឋកិច្ច និងគុណភាពជីវិតរបស់ប្រជាជាតិតំបន់ ឬសហគមន៍មូលដ្ឋានត្រូវបានកែលម្អរ។ ពាក្យនេះត្រូវបានគេប្រើជាញឹកញាប់នៅក្នុងសតវត្សទី ២០ និង ២១ ប៉ុន្តែគំនិតនេះមាននៅភាគខាងលិចជា ច្រើនសតវត្សមកហើយ។ "ទំនើបភាវូបនីយកម្ម" និងជាពិសេស "ឧស្សាហូបនីយកម្ម" គឺជាពាក្យផ្សេងទៀត ដែលត្រូវបានប្រើជាញឹកញាប់នៅពេលពិភាក្សាអំពីការអភិវឌ្ឍសេដ្ឋកិច្ច។ ការអប់រំលើកឡើងពីផលិតភាព និងភាពច្នៃប្រឌិតរបស់ប្រជាជន និងលើកកម្ពស់ភាពជាសហគ្រិនភាព និងបច្ចេកវិទ្យា។ លើសពីនេះទៀតវា ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាវឌ្ឍនភាពសេដ្ឋកិច្ច និងសង្គមធ្វើអោយប្រសើរឡើងនូវការចែកចាយប្រាក់ ចំណូល។ ការអភិវឌ្ឍមូលធនមនុស្សធ្វើអោយមានកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ ផលិតភាពការងារ ខ្ពស់ ការអប់រំបច្ចេកវិទ្យា ពាណិជ្ជកម្ម និងសុខភាព។

[28] Thesis master growth and development studies by Berhane, Melles (page 3-10)

**ក. ការអប់រំ និងជំនាញធ្វើអោយផលិតភាពខ្ពស់**

បទប្បញ្ញត្តិស្ដីពីការអប់រំនៅក្នុងប្រទេសដែលផ្ដល់ឱ្យតំណាងឱ្យគោលការណ៍សំខាន់មួយកត្តាកំណត់នៃសមាសភាព កំណើននៃផលិតផល ការនាំចេញរបស់ប្រទេសនោះ និងបង្កើតជាធាតុផ្សំដ៏សំខាន់នៅក្នុងសមត្ថភាពរបស់ប្រព័ន្ធក្នុងការខ្ចីបច្ចេកវិទ្យាបរទេសមានប្រសិទ្ធិភាព។ ជាក់ស្ដែងមានដូចជាសុខភាព និងអាហារូបត្ថម្ភ ហើយការអប់រំបឋម និងមធ្យមសិក្សាសុទ្ធតែលើកឡើងផលិតភាពរបស់កម្មករជនបទ និងទីក្រុង អនុវិទ្យាល័យ រួមទាំងវិជ្ជាជីវៈ សម្របសម្រួលការទទួលបានជំនាញ និងសមត្ថភាពគ្រប់គ្រង ការអប់រំឧត្តមសិក្សាគាំទ្រការអភិវឌ្ឍវិទ្យាសាស្ត្រមូលដ្ឋាន ការជ្រើសរើសសមស្របនៃការនាំចូលបច្ចេកវិទ្យា និងការសម្របខ្លួនក្នុងស្រុកការអភិវឌ្ឍបច្ចេកវិទ្យា ការអប់រំអនុវិទ្យាល័យ និងឧត្តមសិក្សាផងដែរដែលតំណាងឲ្យធាតុសំខាន់ៗក្នុងការអភិវឌ្ឍស្ថាប័នសំខាន់ៗរបស់រដ្ឋាភិបាលច្បាប់ និងប្រព័ន្ធហិរញ្ញវត្ថុក្នុងចំណោមប្រព័ន្ធទាំងអស់ គឺចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។ ភស្តុតាងជាក់ស្ដែងទាំងនៅមីក្រូ និងកម្រិតម៉ាក្រូបំភ្លឺបន្ថែមទៀតនូវទំនាក់ទំនងទាំងនេះ។ នៅកម្រិតមីក្រូការសិក្សាជាច្រើនបង្ហាញថាការកើនឡើងប្រាក់ចំណូលត្រូវបានផ្សារភ្ជាប់ជាមួយនឹងឆ្នាំបន្ថែមនៃឆ្នាំការអប់រំជាមួយនឹងអត្រានៃការត្រឡប់មកវិញមានភាពខុសប្លែកគ្នាជាមួយនឹងកម្រិតខ្ពស់នៃការអប់រំ (Behrman 1990,Psacharopoulos ឆ្នាំ ១៩៩៤) ។ ការវិលត្រឡប់ទៅបឋមសិក្សាមានទំនោរច្រើនជាងការត្រឡប់ទៅរកការអប់រំអនុវិទ្យាល័យ និងឧត្តមសិក្ស (Psacharopoulos, ១៩៩៤: ១៣២៥-៤៥)។ ការអប់រំក៏ជាការចូលរួមចំណែកដ៏សំខាន់ដល់សមត្ថភាពបច្ចេកវិទ្យា និងការផ្លាស់ប្ដូរបច្ចេកទេសនៅក្នុងឧស្សាហកម្ម។ ការវិភាគស្ថិតិនៃឧស្សាហកម្មសម្លៀកបំពាក់ និងវិស្វកម្មនៅប្រទេសស្រីលង្កាដើម្បីដកស្រង់ឧទាហរណ៍មួយបានបង្ហាញថាកម្រិតជំនាញ និងការអប់រំរបស់កម្មករ និងសហគ្រិនមានទំនាក់ទំនងជាវិជ្ជមានទៅនឹងអត្រានៃការផ្លាស់ប្ដូរបច្ចេកទេសរបស់ក្រុមហ៊ុន (Deraniyagala, 1995) ។

**ខ. ការអប់រំខ្ពស់មានឥទ្ធិពលដល់ប្រាក់ចំណូល**

វាក៏មានឥទ្ធិពលវិជ្ជមានពីការអប់រំដែលបានធ្វើឱ្យប្រសើរឡើងដល់សមភាពប្រាក់ចំណូលកាន់តែច្រើនដែលនៅក្នុងវេន ទំនងជានឹងពេញចិត្តអត្រាខ្ពស់នៃកំណើន។ នៅពេលដែលការអប់រំមានមូលដ្ឋានកាន់តែទូលំទូលាយប្រជាជនដែលមានប្រាក់ចំណូលទាបអាចស្វែងរកឱកាសសេដ្ឋកិច្ចបានប្រសើរ។ ឧទាហរណ៍ការសិក្សានៃទំនាក់ទំនងរវាងសាលារៀន ភាពមិនស្មើគ្នានៃប្រាក់ចំណូល និងភាពក្រីក្រនៅក្នុងប្រទេសចំនួន ១៨ នៃអាមេរិកឡាទីននៅទសវត្សឆ្នាំ ១៩៨០ បានរកឃើញថាមួយភាគបួននៃបំរែបំរួលប្រាក់ចំណូលរបស់កម្មករ គឺគណនេយ្យភាពដោយការប្រែប្រួលនៅក្នុងការសំរេចបានរបស់សាលា វាសន្និដ្ឋានថា

" ការអប់រំយ៉ាងច្បាស់គឺជាសៀវភៅអថេរជាមួយនឹងផលប៉ះពាល់ខ្លាំងបំផុតលើសមភាពប្រាក់ចំណូល " (Psacharopoulos, 1992) ។

**គ. ការអប់រំបង្កើតមូលធនមនុស្ស**

ក្នុងរយៈពេលហាសិបឆ្នាំចុងក្រោយនេះទ្រឹស្តីមូលធនមនុស្សត្រូវបានសង្គមជាច្រើនទទួលយកជាមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយអប់រំផែនការ និងវាយតម្លៃ។ ទ្រឹស្តីមូលធនមនុស្សមានការព្រួយបារម្ភជាមួយនឹងកំណើនសេដ្ឋកិច្ច ហើយសន្មតថាកម្លាំងពលកម្មរបស់មនុស្សអាចត្រូវបានចាត់ទុកជាទំនិញ។ ការអប់រំដែលមានភាពប្រសើរឡើងនៃកម្លាំងពលកម្មត្រូវបានគេមើលឃើញថាជាការវិនិយោគមួយដែលនឹងនាំឱ្យមានផលចំណេញផ្នែកសេដ្ឋកិច្ចទាំងបុគ្គល និងប្រហែលជាសំខាន់ជាងនេះដល់សង្គមទាំងមូល។ ដូច្នេះការបង្កើនចំណាយលើការអប់រំ និងការចូលរួមកាន់តែច្រើនឡើងនៅក្នុងវិស័យអប់រំត្រូវបានគេជឿជាក់ថានឹងនាំឱ្យមានផលិតភាពសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចប្រសើរឡើង។

**ឃ. ការអប់រំ និងពាណិជ្ជកម្ម**

ប្រទេសខ្លះបានរួមបញ្ចូលគ្នានូវភាពបើកចំហរ និងការវិនិយោគក្នុងការរៀនសូត្រដោយជោគជ័យ ការអប់រំបង្កើតជារង្វង់ប្រកបដោយគុណធម៌ ភាពបើកចំហរបង្កើតឲ្យមានតម្រូវការសំរាប់ការអប់រំ និងការរៀនសូត្រ ការអប់រំធ្វើឱ្យវិស័យនាំចេញរបស់ប្រទេសមួយកាន់តែមានការប្រកួតប្រជែង។ ការប្រមូលផ្តុំចំណេះដឹងជះឥទ្ធិពលដល់ការអនុវត្តពាណិជ្ជកម្ម និងការប្រកួតប្រជែងរបស់ប្រទេស។ ផលប៉ះពាល់នៃការបើកចំហរពាណិជ្ជកម្មលើរយៈពេលវែង ការលូតលាស់អាស្រ័យទៅលើសមត្ថភាពប្រជាជនអាចស្រូបយក និងប្រើប្រាស់ព័ត៌មានបានល្អប៉ុណ្ណាបច្ចេកវិទ្យាដែលអាចរកបានតាមរយៈពាណិជ្ជកម្ម និងការវិនិយោគបរទេស។ វាត្រូវបានគេទទួលយកជាទូទៅថា ដើម្បីសម្របខ្លួនទៅនឹងបរិយាកាសនៃការប្រកួតប្រជែងកាន់តែខ្លាំងរបស់ពិភពលោកគឺត្រូវសង្កត់ធ្ងន់ទៅលើតួនាទីរបស់ព័ត៌មានចំណេះដឹង។

ដូច្នេះការអប់រំ គឺមិនអាចខ្វះបានចំពោះការអភិវឌ្ឍជាតិ គ្មានការអភិវឌ្ឍជាតិណាដែលគ្មានការចូលរួមពីវិស័យអប់រំល្អ។ ប្រព័ន្ធអប់រំដែលមានតុល្យភាពលើកកម្ពស់មិនត្រឹមតែសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែផលិតភាព និងបង្កើតប្រាក់ចំណូលបុគ្គលម្នាក់ៗ ឥទ្ធិពលរបស់វាគឺគួរឱ្យកត់សម្គាល់នៅកម្រិតមីក្រូនៃគ្រួសារបុគ្គល។ ដូច្នេះហើយបើប្រទេសមួយដែលចង់អភិវឌ្ឍន៏នោះត្រូវតែពង្រឹងវិស័យអប់រំទៅលើគ្រូ សិស្ស និងបរិស្ថានជុំវិញ។ មួយវិញទៀត រាជរដ្ឋាភិបាលគួរតែចំណាយថវិការជាតិទៅលើការអប់រំអោយទៅតាមស្តង់ដារអន្តជាតិ។

# ជំពូកទី៣

# ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌

## ៣.១ ប្រវត្តិ និងទីតាំងរបស់សាលាបឋមសិក្សាវត្តបូព៌

សាលាបឋមសិក្សាវត្តបូព៌ស្ថិតនៅក្នុងភូមិវត្តបូព៌ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ហើយស្ថិតនៅក្នុងតំបន់ទីប្រជុំជន។ សាលាបឋមសិក្សាវត្តបូព៌បង្កើតឡើងនៅឆ្នាំ១៩៨០ ប៉ុន្តែកាលនោះពុំមែនស្ថិតនៅទីតាំងសព្វថ្ងៃនេះទេកាលដើមឡើយសាលានេះស្ថិតនៅក្នុងវត្តរាជបូព៌ ចំណែកទីតាំងដែលសាលាតាំងនៅបច្ចុប្បន្នគ្រាន់តែជាដីស្រែប៉ុណ្ណោះ។ លុះមកដល់ឆ្នាំ១៩៨៥ ដីស្រែនេះក៏ប្រែក្លាយទៅជាសាលាមធ្យមសិក្សាកម្រិតមួយ តែក្រោយមកក្នុងកំឡុងឆ្នាំ១៩៨៩-១៩៩០សាលាមធ្យមសិក្សាកម្រិតមួយត្រូវបានរំលាយដោយយកសាលាបឋមសិក្សាដែលនៅក្នុងវត្តមកដាក់ជំនួសវិញពេលនោះសាលាមានតែអាគារឈើពីរខ្នង និងអាគារថ្ម ដែលសល់ពីឆ្នាំ ១៩៥៨-១៩៥៩ មួយខ្នងប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៩៣ លោកនាយកសាលាបច្ចុប្បន្នបានចូលមកបម្រើការនៅទីនេះលោកបានឱ្យដឹងថាកាលនោះមានសិស្សត្រឹមតែ៤១២នាក់ និង គ្រូបង្រៀន១១នាក់ប៉ុណ្ណោះ ចំណែកឯស្ថានភាពនៃការរៀន និងបង្រៀនជួបការលំបាកជាច្រើនព្រោះសាលានៅតែជាដីស្រែ និងមានក្រឡុកក្រហែងក្រហូងនៅឡើយ ហើយប្រជាជនដែលនាំកូនមករៀនទៅទីនេះសុទ្ធតែជាគ្រួសារក្រីក្រ។ ដោយឡែកបច្ចុប្បន្ននេះសាលាបឋមសិក្សាវត្តបូព៌មានអាគារសិក្សាចំនួន១៥ខ្នងត្រូវជា ៦៦បន្ទប់សិស្សចំនួន ៦៣២១នាក់ និងស្រី ៣១០៤នាក់ និងគ្រូសរុបចំនួន១២៩នាក់ ស្រី ៩៩នាក់។

## ៣.២ និមិត្តសញ្ញារបស់សាលាបឋមសិក្សាវត្តបូព៌

និមិត្តសញ្ញា ជាសញ្ញាសម្គាល់ ឬអត្តសញ្ញាណតំណាងឲ្យមនុស្ស វត្ថុ ឬអង្គភាព។ ជាទូទៅគ្រប់មនុស្ស វត្ថុ ឬអង្គភាពទាំងអស់តែងតែមាននូវសញ្ញាសម្គាល់ ឬអត្តសញ្ញាណរៀងៗខ្លួន ដើម្បីងាយស្រួលក្នុងការចំណាំ និងសំគាល់។

រូបភាព ២៖ និមិត្តសញ្ញាសាលាបឋមសិក្សាវត្តបូព៌




ប្រភព៖ បទបង្ហាញស្តីពីមូលដ្ឋានគ្រឹះនៃការដឹកនាំគ្រប់គ្រងសាលារៀនឆ្នាំ២០២០

និមិត្តសញ្ញារបស់សាលាបឋមសិក្សាវត្តបូព៌មានអត្ថន័យដូចតទៅៈ

❖ ពណ៌លើផ្ទៃ

- ពណ៌ក្រហម តំណាងឲ្យ ភាពអង់អាច ក្លាហាន និងមោះមុត។
- ពណ៌ខៀវ តំណាងឲ្យ ដំណើរសុភាព រាបសារ ស្លូតបូត។

❖ ត្រីកោណ តំណាងឲ្យយុទ្ធសាស្ត្រអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌ ( ភ វ ស ) ។ ត្រីកោណមានចំនួន ៤ ដែលតាងឲ្យកត្តាចំបងៗចូលរួមក្នុងសកម្មភាពអប់រំរបស់សាលាមានដូចជា ៖

- ត្រីកោណពណ៌បៃតង តំណាងឲ្យ អក្សរ ភ មានន័យថា ភូមិ ជាកន្លែងដែលប្រមូលផ្តុំដោយគ្រួសារជាច្រើនរស់នៅ ពោលគឺការចូលរួមសហការណ៍យ៉ាងស្វិតស្វាញពីមាតាបិតា ឬអាណាព្យាបាលរបស់សិស្សក្នុងការគាំទ្រ និងបន្តជំរុញរាល់សកម្មភាពអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌ ក្នុងគោលបំណងលើកកម្ពស់ការអប់រំ ពិសេសគឺការសិក្សារបស់កូនពួកគាត់ផ្ទាល់។
- ត្រីកោណពណ៌លឿង  តំណាងឲ្យអក្សរ វ មានន័យថា វត្ត(សម្រាប់ព្រះពុទ្ធសាសនា) ឬវិហារ(សម្រាប់ គ្រិស្តសាសនា និងឥស្លាមសាសនា) ពោលគឺសំដៅលើសាសនា ដែលមានតួនាទីសំខាន់ក្នុងការអប់រំមនុស្សឲ្យប្រព្រឹត្តអំពើល្អ ជាពិសេសគឺការរស់នៅប្រកបដោយសេចក្តីសុខទាំងផ្លូវចិត្ត និងផ្លូវកាយ។
- ត្រីកោណពណ៌ខៀវ តំណាងឲ្យសាលារៀន ដែលជាទីកន្លែងសាបព្រោះចំណេះដឹងដល់សិក្សានុសិស្សទាំងឡាយ។ មួយវិញទៀតវាក៏តំណាងឲ្យលោកគ្រូអ្នកគ្រូ ជាអ្នកដែលដើរតួនាទីចំបងក្នុងការអប់រំ បង្រៀន និងផ្តល់ចំណេះដឹងដល់ក្មេងៗជំនាន់ក្រោយ។
- ត្រីកោណពណ៌ស គឺតំណាងឲ្យក្រណាត់សមួយផ្ទាំងដែលមានសភាពស្អាត គ្មានស្នាមប្រឡាក់ ប៉ុន្តែបើយើងយកក្រណាត់មួយផ្ទាំងនោះទៅជ្រលក់ជាមួយពណ៌ណាមួយ នោះវានឹងលេចចេញពណ៌នោះ និងលប់បាត់ពណ៌ស។ បើនិយាយពីន័យធៀបវិញ ក្រណាត់ស មួយផ្ទាំងនោះ តំណាងឲ្យសិស្ស ដែលនឹងត្រូវទទួលរងឥទ្ធិពលពីកត្តាទាំងបីដែលបានរៀបរាប់ខាងលើ គឺមាតាបិតា សាសនា និងគ្រូបង្រៀន។ អនាគតរបស់សិស្សានុសិស្សទាំងអស់ គឺត្រូវពឹងផ្អែកទៅលើកត្តាទាំងបីនោះជាចាំបាច់ ប្រសិនបើកត្តាទាំងនោះរួបរួមគ្នាក្នុងការអប់រំពួកគេឲ្យដើរផ្លូវល្អ នោះអនាគតរបស់ពួកគេ ក៏ដូចជាវាសនាប្រទេសជាតិទាំងមូលនឹងបានប្រសើរផងដែរ។ ផ្ទុយមកវិញប្រសិនបើកត្តាទាំងនោះមិនបានយកចិត្តទុកដាក់ក្នុងការអប់រំពួកគេទេ នោះពួកគេអាចនឹងប្រព្រឹត្តនូវអំពើដែលប្រាសចាកនូវសីលធម៌ និងច្បាប់សង្គម ហើយច្បាស់ណាស់ប្រទេស

ជាតិនឹងទទួលរងនូវភាពអន្តរាយដោយចៀសពុំរួច ព្រោះមិនមានធនធានគ្រប់គ្រាន់ក្នុងការបន្តកសាងសង្គមជាតិ។

❖ ក្លូរស្រូវ

- ក្លូរស្រូវខាងស្តាំ តំណាងឲ្យ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដែលខិតខំប្រឹងប្រែងក្នុងការជំរុញ និងលើកស្ទួយដល់វិស័យអប់រំឲ្យកាន់តែមានការរីកចំរើននៅទូទាំងព្រះរាជាណាចក្រកម្ពុជា។
- ក្លូរស្រូវខាងឆ្វេង តំណាងឲ្យ សប្បុរសជននានា ដែលតែងតែគាំទ្រ និងផ្តល់ជំនួយផ្សេងៗចំពោះការអភិវឌ្ឍសកម្មភាពអប់រំនៅសាលាបឋមសិក្សាវត្តបូព៌នេះផ្ទាល់។

## ៣.៣ ចំនួនអាគារ បន្ទប់ ថ្នាក់ គ្រូ និង សិស្ស

ដកស្រង់ចេញពីព័ត៌មានអំពីស្ថានភាពសិក្សាអប់រំក្នុងសាលាបឋមសិក្សាវត្តបូព៌នាឆ្នាំ២០១៩-២០២០៖

១/ អាគារសិក្សាមានចំនួន ១៥ខ្នង (អាគារកីឡា១ខ្នង)

២/ បន្ទប់មានចំនួន ៦៦ ក្នុងនេះបន្ទប់រៀន ៥១ បន្ទប់កុំព្យូទ័រ ១ ប្រជុំ ១ ទីចាត់ការ ១ បណ្ណាល័យ ១ មត្តេយ្យ ៧ តន្ត្រី ១ ពេទ្យ ១ គេហកិច្ច ១ ប្រពៃណី ១។

៣/ ចំនួនថ្នាក់រៀនរួមមាន:

- ថ្នាក់រៀនភាសាខ្មែរ ១០២ ថ្នាក់ មត្តេយ្យ ១៤ ថ្នាក់
- ថ្នាក់រៀនភាសាអង់គ្លេស ៥១ បារាំង ០៣ ថ្នាក់
- ថ្នាក់រៀនសិល្បៈតន្ត្រី ០២ ក្រុម
- ថ្នាក់រៀនកុំព្យូទ័រ ០១ ថ្នាក់
- ថ្នាក់គេហវិជ្ជា ០១ ថ្នាក់

៤/ សិស្ស និង គ្រូ ឆ្នាំ ២០១៩-២០២០

❖ សិស្សសរុបមាន ៦៣២១នាក់ ស្រី ៣១០៤នាក់ ក្នុងនោះ៖

- ▪ ថ្នាក់មត្តេយ្យមាន ១៤ ថ្នាក់ សិស្សសរុប ៥៦០នាក់ ស្រី ២៩៥នាក់
- ▪ ថ្នាក់ទី១មាន ២០ ថ្នាក់ សិស្សសរុប ១០៦៤នាក់ ស្រី ៥០២នាក់
- ▪ ថ្នាក់ទី២មាន ១៨ ថ្នាក់ សិស្សសរុប ៩៩៥នាក់ ស្រី ៤៨២នាក់
- ▪ ថ្នាក់ទី៣មាន ១៦ ថ្នាក់ សិស្សសរុប ៩១៦នាក់ ស្រី ៤៥៩នាក់

- ថ្នាក់ទី៤មាន ១៦ ថ្នាក់ សិស្សសរុប ៨៩១នាក់ ស្រី ៤២៣នាក់
- ថ្នាក់ទី៥មាន ១៦ ថ្នាក់ សិស្សសរុប ៩៦៤នាក់ ស្រី ៤៧០នាក់
- ថ្នាក់ទី៦មាន ១៦ ថ្នាក់ សិស្សសរុប ៩៣១នាក់ ស្រី ៤៧៣នាក់

❖ គ្រូសរុបមាន ១២៩នាក់ ស្រី ៩៩នាក់ ក្នុងនោះមានៈ

- គណៈគ្រប់គ្រង ២នាក់
- លេខាធិការ ២នាក់
- បណ្ណារក្ស ២នាក់
- គ្រូគេហកិច្ច ០នាក់
- គ្រូកីឡា ២នាក់
- ព្យួរការងារ ០នាក់
- គ្រូបង្រៀនភាសាខ្មែរ ១០២នាក់
- គ្រូសិល្បៈតន្ត្រី ១នាក់
- គ្រូបង្រៀនមត្តេយ្យ ១៤នាក់
- គ្រូកុំព្យូទ័រ ២នាក់
- គ្រូសុខភាព ២នាក់
- ត្រៀមចូលនិវត្តន៍ ០នាក់
- ឈឺ ០នាក់
- សុំឈប់ ០នាក់

## ៣.៤ កត្តារួមចំណែកធ្វើឲ្យការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌មានប្រសិទ្ធភាព

ការអប់រំនៅក្នុងសាលាទទួលបាននូវប្រសិទ្ធភាព និងគុណភាពជាលទ្ធផលបានពីការចូលរួមរបស់ចលកសំខាន់ៗក្នុងនោះរួមមាន៖

### ៣.៤.១ គោលនយោបាយរបស់សាលាបឋមសិក្សាវត្តបូព៌[29]

ដើម្បីសម្រេចបាននូវភាពជោគជ័យក្នុងការគ្រប់គ្រង ដឹកនាំបុគ្គលិក និងអប់រំដល់សិស្សានុសិស្ស សាលាបឋមសិក្សាវត្តបូព៌ក៏បានដាក់ចេញនូវគោលនយោបាយមួយដោយផ្អែកលើគោលនយោបាយរបស់

29 ប័ណ្ណព័ត៌មានអំពីស្ថានភាពសិក្សាអប់រំក្នុងសាលាបឋមសិក្សាវត្តបូព៌នាឆ្នាំ២០១៩-២០២០

រដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡាដូចខាងក្រោមនេះ៖

១. ធ្វើឲ្យកាន់តែប្រសើរឡើង ផ្នែកសុវត្ថិភាព សន្តិសុខ និង សណ្តាប់ធ្នាប់ក្នុងសាលារៀន ជាទីកក់ក្តៅរបស់មាតាបិតាសិស្ស។

២. ធ្វើឲ្យកាន់តែប្រសើរឡើង ផ្នែកសុខុមាលភាពគ្រូ សិស្ស។

៣. ធ្វើឲ្យកាន់តែប្រសើរឡើងលើ គុណភាពរៀន បង្រៀន សមាសភាគទាំង៥ មានបំណិនជីវិត និង ប្រកបដោយចតុស្តម្ភ។

៤. សម្របសម្រួលធ្វើឲ្យជីវភាពរស់នៅរបស់គ្រូបង្រៀន កាន់តែប្រសើរដោយមានការជួយគាំទ្រពីមាតាបិតា ឬអាណាព្យាបាលសិស្សពីផលក្នុងប្រយោជន៍លើចំណុចរួមគ្នាមួយ។ ឆ្លងកាត់ការធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយលោកនាយកសាលាតាមទូរស័ព្ទនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ត្រង់ចំណុចនេះលោកបានលើកឡើងថាការជួយសម្របសម្រួលដល់ជីវភាពរស់នៅរបស់គ្រូបង្រៀនមានរូបភាពពីរយ៉ាងគឺ៖

- ជួយជំរុញទឹកចិត្តគ្រូបង្រៀនឲ្យបន្តការសិក្សាយ៉ាងទាបត្រឹមបរិញ្ញាបត្រដើម្បីបង្កើនចំណេះដឹងទូទៅបន្ថែមទៀត ដែលកត្តានេះនឹងជំរុញឲ្យពួកគាត់ទទួលបាននូវការលើកទឹកចិត្តពីក្រសួងអប់រំ យុវជន និងកីឡាតាមរយៈការតម្លើងកាំប្រៀវត្ស ។
- ការផ្តល់នូវថវិកាឥណទានសម្រាប់គ្រូបង្រៀនដោយអនុញ្ញាតឲ្យពួកគាត់ធ្វើកម្ចីពីថវិកាមូលនិធិសាលាដោយគិតអត្រាការប្រាក់១%ក្នុងមួយខែនៃប្រាក់កម្ចីសរុប។ គួរឲ្យកត់សម្គាល់ផងដែរថាថវិកាមូលនិធិនេះគឺសាលាបានធ្វើកម្ចីពីមាតាបិតា ឬអាណាព្យាបាលសិស្សដោយមិនត្រូវបានគិតអត្រាការប្រាក់ឡើយ។ ចំណែកនៅរៀងរាល់ថ្ងៃព្រហស្បតិ៍ សាលាពុំបានឲ្យសិស្សធ្វើពលកម្មនោះទេពោលគឺនៅរៀនធម្មតា ប៉ុន្តែសម្រាប់ការរៀននៅថ្ងៃព្រហស្បតិ៍នេះ សាលាបានអំពាវនាវដល់មាតាបិតា ឬអាណាព្យាបាលសិស្សដោយសុំឲ្យរៃអង្គាសប្រាក់ជូនគ្រូបន្ទុកថ្នាក់ ដោយក្នុងសិស្សម្នាក់ត្រូវចំណាយ៥០០រ។ ប៉ុន្តែប្រសិនបើសិស្សណាម្នាក់ពុំមានលទ្ធភាពទេ នោះសិស្សអាចជូនដំណឹងដល់នាយកសាលា រួចនាយកសាលានឹងធ្វើលិខិតបញ្ជាក់ជាសិស្សក្រីក្រ។

### ៣.៤.១.១ ចក្ខុវិស័យរបស់សាលាបឋមសិក្សាវត្តបូព៌[30]

សាលាបឋមសិក្សាវត្តបូព៌ ធានាផ្តល់សេវាអប់រំដែលមានគុណភាព ប្រសិទ្ធភាព ប្រកបដោយសមធម៌ សម្រាប់កុមារដល់វ័យសិក្សានៅក្នុងសហគមន៍ដោយផ្តល់លទ្ធភាព និងគាំទ្រតាមជម្រើសផ្សេងៗសម្រាប់ការសិក្សាពេញមួយជីវិតដើម្បីប្រែក្លាយទៅជាសាលាកុមារមេត្រីដោយទាំងសិស្សនិងគ្រូទទួល

[30] ផែនការអភិវឌ្ឍន៍សាលាបឋមសិក្សាវត្តបូព៌ឆ្នាំ២០១៩-២០២៣ ទំព័រ ២ (ឆ្នាំ២០២០)

បាននូវៈ

១/គុណភាពខ្ពស់ (ការសិក្សាទាបបំផុតបរិញ្ញាបត្រ ជំនាញICT ចេះប្រើប្រាស់២ភាសា)

២/សុខភាពល្អ

៣/ឥរិយាបថថ្លៃថ្នូរ (សុជីវធម៌ សីលធម៌ គុណធម៌)

ដើម្បីរួមចំណែកអភិវឌ្ឍសង្គមកម្ពុជាក្លាយទៅជាសង្គមរីកចម្រើនលើគ្រប់វិស័យ។

### ៣.៤.១.២ បេសកកម្មរបស់សាលាបឋមសិក្សាវត្តបូព៌[31]

សាលាបឋមសិក្សាវត្តបូព៌ ការដឹកនាំគ្រប់គ្រង ការអប់រំសិក្សាដល់កុមារ ប្រកបដោយ តម្លាភាព សុវត្ថិភាព សមភាព គុណភាព សមត្ថភាពបានល្អប្រសើរ ដើម្បីឆ្លើយតបទៅតាមសំណូមពរ និងតម្រូវការធនធានមនុស្សជាក់ស្តែងក្នុងជីវភាពរស់នៅរបស់ប្រជាជនក្នុងសង្គមប្រចាំថ្ងៃ និងការវិវត្តន៍នៃការរីកចម្រើនធនធានមនុស្សក្នុងតំបន់ ឲ្យឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDG4) ស្របតាមយុគសម័យបច្ចេកវិទ្យាឌីជីថល។

ដើម្បីឱ្យសម្រេចនូវចក្ខុវិស័យរបស់ខ្លួន សាលាបានកំណត់គោលដៅបេសកកម្មដូចជាៈ

- បន្តកាត់បន្ថយអត្រាត្រួតថ្នាក់នៅថ្នាក់ទី១ ឱ្យនៅត្រឹមតែ0.0%
- បង្កើនអត្រាឡើងថ្នាក់នៅគ្រប់កម្រិតថ្នាក់លើសពី១០០%
- បង្កើនការប្រើប្រាស់សម្ភារៈ ធនធានមនុស្ស បរិស្ថានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព
- ពង្រឹងកិច្ចសហការ ទំនាក់ទំនងជាមួយសមាគនជាតិ និងអន្តរជាតិឱ្យកាន់តែមានភាពប្រសើរ។

### ៣.៤.១.៣ យុទ្ធសាស្ត្រអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌

ការអប់រំនៅក្នុងសាលាតែមួយមុខមិនទាន់គ្រប់គ្រាន់ទេសម្រាប់ការអភិវឌ្ឍន៍លើផ្នែកធនធានមនុស្សនេះ ដែលមានន័យថាទាមទារឲ្យមានការចូលរួមជាចាំបាច់ពីសំណាក់មាតាបិតា ឬអាណាព្យាបាលសិស្ស សាសនា និងគ្រូបង្រៀនជាកម្លាំងចលករយ៉ាងសំខាន់ដែលមានតួនាទីជាអ្នកអប់រំ។ ជាមួយគ្នានេះដែរសាលាបឋមសិក្សាវត្តបូព៌បានដាក់ចេញជាយុទ្ធសាស្ត្រនៃការអប់រំ ( ភ វ ស ) ដែលបានបង្ហាញពីកត្តា៣យ៉ាងជាចលករយ៉ាងសំខាន់ជួយជំរុញឲ្យការអប់រំនៅសាលានេះទទួលបាននូវភាពជោគជ័យយ៉ាងខ្លាំងក្នុងនោះរួមមានៈ

#### ក. មាតាបិតា ឬអាណាព្យាបាលសិស្ស

បានធ្វើការការសហការណ៍ជាមួយគ្រូបង្រៀន និងនាយកសាលាយ៉ាងជិតស្និត។ មាតាបិតា

[31] ផែនការអភិវឌ្ឍន៍សាលាបឋមសិក្សាវត្តបូព៌ឆ្នាំ២០១៩-២០២៣ ទំព័រ ២ (ឆ្នាំ២០២០)

ឬអាណាព្យាបាលសិស្ស តែងតែទទួលបានដំណឹងអំពីការសិក្សារបស់កូនគាត់ជាប្រចាំតាមរយៈគ្រូបន្ទុកថ្នាក់ និងការជួបប្រជុំជាមួយនាយកសាលាជារៀងរាល់ដើមឆ្នាំ និងចុងឆ្នាំ (សូមមើលឧបសម្ព័ន្ធទី១០)។ ការសហការនេះក្នុងគោលបំណងតាមដានការសិក្សារបស់សិស្សទាំងនៅសាលា និងនៅផ្ទះ ដើម្បីឲ្យពួកគេទទួលបានការអប់រំមួយដ៏ត្រឹមត្រូវ និងមានប្រសិទ្ធភាព។ មិនតែប៉ុណ្ណោះទេមាតាបិតា ឬអាណាព្យាបាលសិស្សភាគច្រើនបានយកចិត្តទុកដាក់បង្រៀន និងពន្យល់កូនបន្ថែមទៀត ពេលទំនេរពីការងារ ឬការប្រកបរបររកស៊ីរបស់ពួកគាត់។

**ខ. សាសនា**

នៅក្នុងប្រទេសកម្ពុជា គេពុំសូវឃើញមានច្រើននោះទេ ចំពោះសាលារៀនដែលយកព្រះពុទ្ធសាសនាទៅផ្សាភ្ជាប់ការអប់រំរបស់ខ្លួនតាមរយៈការឲ្យសិស្សបានសិក្សាជាមួយព្រះសង្ឃផ្ទាល់។ ប៉ុន្តែសាលាបឋមសិក្សាវត្តបូព៌ ក្នុងទីរួមខេត្តសៀមរាប បានដាក់បញ្ចូលការអប់រំតាមបែបព្រះពុទ្ធសាសនា ជាមួយនឹងការអប់រំចំណេះដឹងទូទៅ។ ជារៀងរាល់សប្តាហ៍នៅថ្ងៃព្រហស្បតិ៍ សាលារៀនមួយនេះ បាននិមន្តព្រះសង្ឃពីវត្តរាជបូព៌ដែលនៅជាប់នឹងសាលា មកបង្ហាត់បង្រៀនធម៌វិន័យ និងសីលធម៌ដល់កុមារតូចៗ ក្នុងសាលារៀន ដែលមានសិស្សជាច្រើនពាន់នាក់(សូមមើលឧបសម្ព័ន្ធទី១១)។ គណៈគ្រប់គ្រងសាលាបានយល់ថា ការយកព្រះពុទ្ធសាសនាមកអប់រំ ដល់កុមារតូចៗ ជាកត្តាសំខាន់បំផុត ដើម្បីធ្វើឲ្យពួកគេក្លាយជាមនុស្សសកលដែលពោរពេញដោយគុណធម៌ និងសីលធម៌។ ចំណែកព្រះសង្ឃដែលមកបណ្តុះបណ្តាលដល់កុមារ ក៏ចង់ឲ្យការអប់រំបែបនេះ មានគ្រប់នៅតាមគ្រឹះស្ថានអប់រំ មិនមែនមានតែនៅសាលាបឋមសិក្សាវត្តបូព៌ តែមួយនោះទេ។

**គ. គ្រូបង្រៀន**

គ្រូបង្រៀន ជាមាតាបិតាទី២របស់សិស្ស ព្រោះគ្រូបាន មើលថែទាំសិស្សនៅសាលា ចែករំលែកនូវចំណេះដឹងដល់សិស្ស អប់រំ ណែនាំឲ្យសិស្សគិត និងធ្វើបានត្រឹមត្រូវដើម្បីទទួលបានអនាគតដ៏ភ្លឺស្វាងនាថ្ងៃខាងមុខ។ ពួកគាត់ត្រូវបានកំណត់ឲ្យមានចំណេះដឹងសមល្មម (ទាបបំផុតត្រឹមបរិញ្ញាបត្រ ចេះយ៉ាងតិច ២ ភាសា និងចេះប្រើប្រាស់ ICT បាន)។ មានឥរិយាបថថ្លៃថ្នូរ (សុជីវធម៌ សីលធម៌ គុណធម៌ប្រសើរ) មានស្មារតីលះបង់ កម្លាំងកាយចិត្ត ថវិការ ទ្រព្យធន និងចេះចែករំលែក មានការទទួលខុសត្រូវចំពោះការងារ និងបង្កបរិយាកាសសប្បាយៗជាមួយគ្នា។

### ៣.៤.១.៤ យុទ្ធវិធីការអប់រំ(សមាសភាគអប់រំ៥)របស់សាលាបឋមសិក្សាវត្តបូព៌

ដើម្បីសម្រេចបាននូវការអប់រំដែលប្រកបដោយគុណភាព និងប្រសិទ្ធភាព សាលាបឋមសិក្សាវត្តបូព៌ក៏បានផ្តោតការអប់រំជាប្រចាំលើសមាសភាគ៥ គឺ៖

ក) ការអប់រំបញ្ញា ជាការអប់រំឲ្យសិស្សទទួលបាននូវចំណេះដឹងទូទៅ ដូចជា ភាសាខ្មែរ គណិតវិទ្យា សិក្សាសង្គម វិទ្យាសាស្ត្រ ភាសាបរទេស និង ICT ជាដើម។

ខ) ការអប់រំកាយ ផ្តោតលើការអប់រំផ្នែកសុខភាព ដូចជាការហាត់ប្រាណ និងលេងកីឡាជាដើម។ ជាការពិតណាស់កត្តាសុខភាព ជាកត្តាមួយដ៏សំខាន់ និងទាមទារឲ្យយើងយកចិត្តទុកដាក់លើសុខភាពនេះជាចាំបាច់ ព្រោះនៅពេលដែលធនធានមនុស្សមានចំណេះដឹង មានសុខភាពល្អ មានកម្លាំងមាំមួន នោះពួកគេនឹងអាចសម្រេចកិច្ចការតូចធំប្រកបដោយភាពជោគជ័យជាក់ជាមិនខាន។

គ) ការអប់រំសិល្បៈ គឺការអប់រំលើផ្នែកតន្ត្រី បំណិនសម្តែង ច្រៀង រាំ ព្រោះសិល្បៈនឹងបង្កឲ្យមានភាពរីករាយ ជាហេតុនាំឲ្យមានសុខភាពផ្លូវចិត្តល្អ ដែលអាចបណ្តុះជាគំនិតថ្មីៗដល់សិស្ស និងជួយឲ្យពួកគេមានវិន័យក្នុងខ្លួនផងដែរ ។

ឃ) ការអប់រំពលកម្ម ជាការអប់រំឲ្យពួកគេចេះពីរបៀបអនាម័យ និងមានរបៀបរៀបរយ។ តួយ៉ាងដូចជាការសម្អាតបរិស្ថានសាលា សម្អាតបង្គន់អនាម័យ និងថ្នាក់រៀនជាដើម សិស្សទាំងអស់បានទទួលការអប់រំ និងអនុវត្តជាក់ស្តែងលើផ្នែកនេះគ្រប់ៗគ្នា។

ង) ការអប់រំសោភ័ណ ជាការអប់រំឲ្យសិស្សចេះពីរបៀបនៃការរៀបចំឲ្យបានស្អាត និងមានសណ្តាប់ធ្នាប់ប្រកបដោយសោភ័ណ ជាពិសេសគឺការអប់រំលើឥរិយាបថរបស់សិស្សអោយចេះពីរបៀបរៀបចំខ្លួនឲ្យបានត្រឹមត្រូវទាំងការដេក ដើរ ឈរ និងអង្គុយជាដើម។

(សូមមើលឧបសម្ព័ន្ធទី៨)

### ៣.៤.២ ការអនុវត្តការងារជាក់ស្តែង

#### ៣.៤.២.១ ការគ្រប់គ្រងធនធានមនុស្ស

##### ក. រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាបឋមសិក្សាវត្តបូព៌

ការជោគជ័យនៅក្នុងអង្គភាពមួយ លុះត្រាតែមានការសហការណ៍យ៉ាងមុតមាំរវាងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ ព្រមទាំងបុគ្គលិកទាំងអស់នៅក្នុងអង្គភាពមួយនោះ។ តួយ៉ាងនៅ សាលាបឋមសិក្សាវត្តបូព៌នេះមានរចនាសម្ព័ន្ធដូចតទៅ៖

## តារាង២៖ រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាបឋមសិក្សាវត្តបូព៌




ប្រភព ៖ ផែនការអភិវឌ្ឍន៍សាលារៀនឆ្នាំ២០១៩-២០២៣ (ឆ្នាំ២០២០)

### ខ. តួនាទី និងភារកិច្ច[32]

តួនាទី និងភារកិច្ចរបស់បុគ្គលិកក្នុងអង្គភាពនៅសាលាបឋមសិក្សាវត្តបូព៌មានរូបភាពដូចខាងក្រោះ

❖ **នាយកសាលាទទួលបន្ទុកៈ**

- គ្រប់គ្រងទូទៅលើអង្គភាពទាំងមូល
- ការងារចាត់តាំងភារកិច្ចបុគ្គលិក គ្រូ សិស្ស និងការអនុញ្ញាតច្បាប់
- ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ
- កិច្ចការទំនាក់ទំនងសាធារណៈទាំងកម្រិតក្នុងប្រទេស និងក្រៅប្រទេស

[32] ដកស្រង់ចេញពីសៀវភៅ មគ្គុទេសក៏កំណែទម្រង់គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌ រៀបរៀងដោយសាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០២០

- ការសំណេះសំណាលជុំវិញបញ្ហានានាពាក់ព័ន្ធការងារទំនាក់ទំនងជាមួយនឹងសមាគមមាតាបិតា ឬអាណាព្យាបាលសិស្ស។

❖ **នាយករងទទួលបន្ទុកៈ**

- ត្រួតពិនិត្យ និង អនុវត្តតាមគោលការណ៍របស់នាយកសាលា
- គ្រប់គ្រងបុគ្គលិក
- អនុវត្តបទបញ្ជា និងវិន័យផ្សេងៗ។

❖ **លេខាធិការៈ** ទទួលផ្នែកការងាររដ្ឋបាលទូទៅ និង ការងារបុគ្គលិក។

❖ **ការងារគណនេយ្យ**

- គ្រប់គ្រងថវិកាអំណោយក្នុង និងក្រៅប្រទេស និងថវិកាចំណូលផ្ទាល់ពីការគ្រប់គ្រងសាលា
- បញ្ជាចំណាយតាមការចាំបាច់ ដោយមានការអនុញ្ញាតពីនាយកសាលា
- គ្រប់គ្រងបញ្ជីការគណនេយ្យ និងឯកសារផ្សេងៗដែលជាប់ទាក់ទងទៅនឹងការចំណាយ
- កត់ត្រាចំណូល និងចំណាយថវិការបស់សាលាឲ្យបានត្រឹមត្រូវ
- គ្រប់គ្រង និងបញ្ចេញសាច់ប្រាក់ចំណាយក្នុងអង្គភាព
- ចុះបញ្ជីចេញ និងចូលសាច់ប្រាក់ និងចុះហត្ថលេខាប្រគល់ទទួល
- ទទួលខុសត្រូវចំពោះមុខអង្គភាពលើការបាត់បង់សាច់ប្រាក់។

❖ **បណ្ណាល័យៈ** បណ្ណារក្សមានតួនាទីដូចជា៖

- គ្រប់គ្រងការងារបណ្ណាល័យដូចជា បញ្ជីសម្រាប់បញ្ចេញសៀវភៅ និងបញ្ជីបញ្ចូលសៀវភៅ
- ការរៀបចំបណ្ណាល័យ ផ្គត់ផ្គង់ឯកសារ ឬសម្ភារៈផ្សេងៗដែលបម្រើឲ្យការរៀន និងបង្រៀន
- តុបតែង និងការថែរទាំបណ្ណាល័យ
- ការរៀបចំកាលវិភាគសម្រាប់សិស្សតាមថ្នាក់ ចូលបណ្ណាល័យ
- គ្រប់គ្រងសកម្មភាពសិក្សា និង ការស្រាវជ្រាវរបស់សិស្សក្នុងបណ្ណាល័យ។

❖ **ផ្នែកកីឡាៈ**

- រៀបចំកម្មវិធី ឬមេរៀនស្តីពីកីឡា
- រៀបចំផែនការ ឬកាលវិភាគសិស្សម៉ោងកីឡា សម្រាប់ថ្នាក់នីមួយៗ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរៀន និងបង្រៀនប្រចាំខែ ជូនគណៈគ្រប់គ្រងសាលា។

❖ **ផ្នែកសុខភាព:**

- ធានាបន្ទប់រៀនឲ្យមានផាសុកភាព
- បែងចែកកម្មវិធីសម្រាប់សិស្សចូលផែកសុខភាពតាមថ្នាក់
- ជំរុញសកម្មភាពទប់ស្កាត់នឹងជំងឺអេដស៍ ជួញដូរកុមារ និងគ្រឿងញៀន
- បំប៉នអំពីវិធីសាស្ត្រសង្គ្រោះបន្ទាន់ និងវិធីថែរក្សាសុខភាព វិធីព្យាបាលកម្រិតមូលដ្ឋាន
- តាមដានការប្រែប្រួលសុខភាពរបស់កុមារ និងធ្វើរបាយការណ៍ជូននាយកសាលា។

❖ **បរិស្ថាន:**

- គ្រប់គ្រងលើសណ្តាប់ធ្នាប់ទូទៅ ដូចជាប្រជុំរៀបចំផែនការ និងអនាម័យបរិស្ថាន បែងចែក ភារកិច្ចតាមគ្រូប្រចាំថ្នាក់ អនុវត្តភារកិច្ច វាយតម្លៃលើភារកិច្ច អនុវត្តការងារ រោងជាង និង សំណូមពរផ្សេងៗ។

❖ **គេហៈកិច្ច:** គ្រប់គ្រងលើសម្ភារសម្រាប់ការងារអនុវត្តជាក់ស្តែងដូចជា វិជ្ជាធ្វើម្ហូប ការដេរប៉ាក់។

❖ **ផ្នែកព័ត៌មានវិទ្យា:**

- គ្រប់គ្រងលើដំណើរការនៃការរៀន និងបង្រៀនផ្នែកកុំព្យូទ័រ
- បំប៉នអំពីវិធីសាស្ត្រដល់គ្រូជាប្រចាំ
- តាមដានការប្រែប្រួលរបស់សិស្ស គ្រូ និងធ្វើរបាយការណ៍ជូនគណៈគ្រប់គ្រងសាលា។

❖ **ការងារបច្ចេកទេស**

ប្រជុំបែងចែកកម្មវិធីសិក្សាប្រចាំខែ និងជួយសមាជិកក្រុមអនុវត្តផែនការ និងវិធីសាស្ត្របរិស្ថានផលិតសម្ភារៈឧបទេស សម្រាប់បរិស្ថានរៀបចំថ្នាក់ និទស្សន៍រកវិធីសាស្ត្រឲ្យសិស្សចេះស្វ័យសិក្សា ដោះស្រាយរាល់ចម្ងល់ដែលក្រុមបច្ចេកទេសសួរ និងផ្សព្វផ្សាយសារាចរណ៍ណែនាំ ផ្សេងៗ របស់ក្រសួងអប់រំ យុវជន និងកីឡា ។ ការប្រជុំបច្ចេកទេស គឺធ្វើឡើងជារៀងរាល់ថ្ងៃព្រហស្បតិ៍ដោយមានរបៀបវារៈ និងខ្លឹមសារនៃការប្រជុំច្បាស់។ ករណីចាំបាច់ នាយកសាលាត្រូវកោះប្រជុំជាសមញ្ញបាន។ ចំពោះការពង្រឹងលើការងារបច្ចេកទេស នាយករង មានតួនាទីទទួលខុសត្រូវលើការងារមួយចំនួនទៀតដូចជាៈ ប្រជុំគ្រូរៀបចំកម្មវិធីសិក្សាចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ និងធ្វើកិច្ចតែងការសម្រាប់បង្រៀន ។ រៀបចំផែនការចុះពង្រឹងការបង្រៀន និងរៀនផ្នែកភាសាខ្មែរ គណិតវិទ្យាចាប់ពីថ្នាក់ទី១ ដល់ទី៦ ក្នុងមួយខែចំនួនពីរថ្នាក់។ ប្រធានក្រុមបច្ចេកទេសចុះអធិការកិច្ចជួយគ្រូមួយខែពីរនាក់ ចំនួនពីរថ្នាក់ ពីរថ្នាក់ទី១ដល់ទី៦។ ពង្រឹងគ្រូធ្វើថ្នាក់និទស្សន៍គ្រប់កម្រិតថ្នាក់ក្នុងមួយខែម្តងនូវរៀងរាល់ថ្ងៃព្រហស្បតិ៍ នៅសប្តាហ៍ទី៤ រៀង រាល់ ខែនីមួយៗ។

❖ **ការបង្កើតក្រុមប្រឹក្សាកុមារ**

ការបង្កើតក្រុមប្រឹក្សាកុមារនេះត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងរយៈពេលមួយឆ្នាំម្តង(ធ្វើឡើងនៅពេលចុងឆ្នាំ)(សូមមើលឧបសម្ព័ន្ធទី១)។ ពួកគេមានភារកិច្ចក្នុងការទទួលខុសត្រូវចំពោះការរៀបចំសណ្តាប់ធ្នាប់ ដឹកនាំ គ្រប់គ្រង តម្រង់ទិសការងារក្រុមប្រឹក្សាកុមារ និងសិស្សកាយរិទ្ធិ ដូចជាការសម្រួលចរាចរណ៍នៅច្រកចូលសាលា ដោយមានសំលៀកបំពាក់សំគាល់បានជាសន្តិសុខ សណ្តាប់ធ្នាប់ (សូមមើលឧបសម្ព័ន្ធទី២)។

**៣.៤.២.២ ការអភិវឌ្ឍធនធានមនុស្ស**

ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យ និងបេសកកម្មរបស់សាលា គណៈគ្រប់គ្រងសាលាបឋមសិក្សាវត្តបូព៌ បានយកចិត្តទុកដាក់ក្នុងការពង្រឹង និងពង្រីកចំណេះដឹងរបស់បុគ្គលិកអប់រំខ្លួនជាចំបង តាមរយៈ

- ការផ្តល់នូវការបណ្តុះបណ្តាលផ្នែកបច្ចេកវិទ្យា (ICT) ព្រោះការទទួលបាននូវចំណេះដឹងផ្នែកនេះពិតជាមានសារសំខាន់យ៉ាងខ្លាំងក្នុងការសម្រួលដល់ការស្រាវជ្រាវចំណេះដឹងថ្មីៗ បច្ចេកទេសបង្រៀនថ្មីៗ សម្រាប់យកមកបង្ហាញ និងបង្រៀនដល់សិស្ស ដើម្បីឲ្យសិស្សទទួលបានចំណេះដឹងថ្មីៗបន្ថែមទៀត និងយល់កាន់តែស៊ីជម្រៅទៅលើមេរៀននីមួយៗ។
- មិនតែប៉ុណ្ណោះទេគ្រូបង្រៀននៅទីនោះក៏មានការសាមគ្គី និងសហការណ៍គ្នាបានយ៉ាងល្អ ចំពោះការចែករំលែកនូវចំណេះថ្មីៗជាមួយគ្នាទៅវិញទៅមក ដើម្បីជាប្រយោជន៍ដល់ការអប់រំទាំងមូល ដូចពាក្យស្លោកមួយបានលើកឡើងថា " ការអប់រំដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ " ។
- ទន្ទឹមនឹងនេះលោកគ្រូ អ្នកគ្រូក៏ត្រូវបានលើកទឹកចិត្តឲ្យមានចំណេះដឹងផ្នែកភាសាយ៉ាងតិច២ភាសា គឺមានភាសាជាតិជាគោល និងភាសាបរទេសមានដូចជា ភាសាអង់គ្លេស និងភាសាបារាំង។
- សាលាបឋមសិក្សាវត្តបូព៌មានទិសដៅអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនឲ្យមានចំណេះដឹងទាបបំផុតក៏ត្រឹមកម្រិតបរិញ្ញាបត្រដែរ។ ជាក់ស្តែងបើយោងតាមបញ្ជីរាយនាមបុគ្គលិកអប់រំតាមក្របខណ្ឌអប់រំឆ្នាំ ២០១៧-២០១៨ របស់សាលាបឋមសិក្សាវត្តបូព៌ មានគ្រូបង្រៀនដែលបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ចំនួន ៧៣នាក់ និងបានបញ្ចប់ថ្នាក់អនុបណ្ឌិតមានចំនួន ១១នាក់រួចហើយដែរ (សូមមើលឧបសម្ព័ន្ធទី២៦)។

**៣.៤.២.៣ ការអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាលា**

**ក. ឯកសណ្ឋាន**

ការរៀបចំឯកសណ្ឋានរបស់គ្រូ និងសិស្សនៅសាលាបឋមសិក្សាវត្តបូព៌ពិតជាមានលក្ខណៈសមសួន មានរបៀបរៀបរយ មានវិន័យត្រឹមត្រូវ និងប្រកបដោយភាពថ្លៃថ្នូរ។

❖ **សម្រាប់បុគ្គលិក**

ឯកសណ្ឋានរបស់គ្រូបង្រៀនមានបំពាក់នូវនិមិត្តសញ្ញារបស់សាលានៅផ្នែកខាងឆ្វេង និងឈ្មោះរបស់គ្រូនៅផ្នែកខាងស្តាំ ។ ចំពោះឯកសណ្ឋាននេះទៀតសោតត្រូវបានបែងចែកជា ៤ ឈុតសំខាន់ៗគឺ មានឯកសណ្ឋានសម្រាប់ចូលរួមក្នុងកម្មវិធីផ្សេងៗ សម្រាប់ទទួលភ្ញៀវជាតិ និងអន្តរជាតិ សម្រាប់បង្រៀនជាប្រចាំ និងឯកសណ្ឋានកីឡា (សូមមើលឧបសម្ព័ន្ធទី៣)។

❖ **សម្រាប់សិស្ស**

ឯកសណ្ឋានរបស់សិស្សនៅសាលាបឋមសិក្សាវត្តបូព៌ មានអាវស មានបំពាក់នូវឈ្មោះសាលានៅផ្នែកខាងស្តាំ និងនិមិត្តសញ្ញាសាលានៅផ្នែកខាងឆ្វេង ស្លៀកខោ ឬសំពត់ ពណ៌ទឹកប៊ិច ស្បែកជើងប៉ាត់តាពណ៌ស និងមានសម្លៀកបំពាក់មួយឈុតទៀតសម្រាប់ហាត់កីឡា (សូមមើលឧបសម្ព័ន្ធទី៤)។ គួរឲ្យកត់សម្គាល់ផងដែរថា នៅលើករអាវរបស់សិស្សានុសិស្សមានភ្ជាប់ជាមួយនូវឡេវអាវ ដែលមានពណ៌ផ្សេងៗគ្នាទៅតាមកម្រិតថ្នាក់នីមួយៗ ហើយពណ៌ឡេវអាវទាំងនេះត្រូវបានរៀបចំទៅតាមពណ៌នៃថ្ងៃ ពីថ្ងៃអាទិត្យ ដល់ថ្ងៃច័ន្ទ និងកម្រិតថ្នាក់ ពីថ្នាក់មត្តេយ្យ ដល់ថ្នាក់ទី៦ តាមលំដាប់រៀងគ្នាដូចខាងក្រោម៖

- ថ្នាក់មត្តេយ្យ ប្រើប្រាស់ពណ៌ក្រហម
- ថ្នាក់ទី១ ប្រើប្រាស់ពណ៌លឿងទុំ
- ថ្នាក់ទី២ ប្រើប្រាស់ពណ៌ស្វាយ
- ថ្នាក់ទី៣ ប្រើប្រាស់ពណ៌ស៊ីលៀប
- ថ្នាក់ទី៤ ប្រើប្រាស់ពណ៌បៃតង
- ថ្នាក់ទី៥ ប្រើប្រាស់ពណ៌ខៀវ
- និងថ្នាក់ទី៦ ប្រើប្រាស់ពណ៌ព្រឿងទុំ។

**ខ. វិន័យ**

❖ **សម្រាប់បុគ្គលិក**

គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌ត្រូវបានគេកត់សម្គាល់ឃើញថាមានឥរិយាបទសមរម្យ មានអធ្យាស្រ័យល្អ មានភាពរស់រាយរាក់ទាក់ មានភាពម៉ឺងម៉ាត់ចំពោះការងារ និងមានការគោរពបទបញ្ជាផ្ទៃក្នុងរបស់សាលាបានយ៉ាងខ្ជាប់ខ្ជួន។ ជារៀងរាល់ថ្ងៃ ពួកគាត់តែងតែមកដល់សាលាមុនម៉ោង ៧ សម្រាប់វេនព្រឹក និង ម៉ោង ១ រសៀលសម្រាប់វេនល្ងាចដើម្បី ធ្វើការស្កេនមេដៃ ស្រង់វត្តមាន មុននឹងចូលបំពេញតួនាទីរៀងៗខ្លួន (សូមមើលឧបសម្ព័ន្ធទី៥)។ មួយវិញទៀតមុនម៉ោងចូលរៀនមួយម៉ោងគេតែងសង្កេតឃើញថាមាន

គ្រូយាមជាប្រចាំពីរនាក់នៅក្លោងទ្វារសាលា ដើម្បីត្រួតពិនិត្យ តាមដាន និងសម្រួលដល់សកម្មភាពចូលរៀនរបស់សិស្ស។ ទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ថា ក្រៅពីការបង្រៀន គ្រូបង្រៀននៅទីនេះក៏បានចូលរួមយ៉ាងសកម្មក្នុងការសម្រួលដល់សកម្មភាពនៃការអប់រំទាំងមូល។

❖ **សម្រាប់សិស្ស**

វិស័យមួយអាចទទួលបានជោគជ័យ លុះត្រាតែមនុស្សនៅក្នុងវិស័យនោះមានគុណភាពផ្នែកចំណេះដឹងព្រមជាមួយនឹងការគោរពវិន័យបានត្រឹមត្រូវ។ តាមគោលការណ៍របស់សាលាបឋមសិក្សាវត្តបូព៌បានអប់រំឲ្យសិស្សបានយល់ និងចេះពីវិន័យ៥យ៉ាងគឺ

ក) ស្អាត គឺអប់រំឲ្យសិស្សចេះពីរបៀបអនាម័យ និងរៀបចំខ្លួនឲ្យបានសមរម្យ។

ខ) របៀប គឺរបៀបនៃការដេក ដើរ ឈរអង្គុយឲ្យបានត្រឹមត្រូវ។

គ) សុភាព គឺអប់រំសិស្សឲ្យក្លាយជាមនុស្សសុភាពរាបសារ ចេះឱនលំទោន ចេះគោរពចាស់ទុំ និងនិយាយស្ដីដោយពាក្យសមរម្យ។

ឃ) ទៀងពេល គឺអប់រំឲ្យស្គាល់ពីតម្លៃនៃពេលវេលា ឲ្យគោរពពេលវេលា។

ង) ការធ្វើសមាធិ ដើម្បីទទួលបានសេចក្ដីសុខផ្លូវចិត្ត និងពិចារណាឡើងវិញពីកម្រិតនៃការអនុវត្តឥរិយាបថទាំង៤ខាងលើ។ ប្រសិនបើការអនុវត្តបានល្អហើយគឺត្រូវធ្វើឲ្យកាន់តែល្អ ប៉ុន្តែបើពុំទាន់បានល្អត្រូវរកចំណុចខ្វះចន្លោះ រួចកែតម្រូវឲ្យមានភាពប្រសើរ។

**ចំពោះការគោរពទង់ជាតិ**៖កូនសិស្សមកមុនម៉ោង ឈរមានវិន័យសណ្ដាប់ធ្នាប់ល្អ មានភាពក្លាហានអំណត់ព្យាយាម មានឯកសណ្ឋានគ្រប់គ្នា។ សិស្សមានវិន័យល្អពេលគោរពទង់ជាតិ ឈរត្រង់ជួរភ្លឹង តាំងពីសិស្សថ្នាក់មត្តេយ្យឡើងទៅ ក្នុងពេលគោរពទង់ជាតិ មានសិស្សរាយការណ៍ពត៌មានពេលព្រឹក បន្ទាប់មកនាយកមានមតិណែនាំសមាធិដោយមានពោលពាក្យតម្កួញ ភ្លេងកំដរ ចុងបញ្ចប់ស្ដាប់ចម្រៀងការដឹងគុណគ្រូ (សូមមើលឧបសម្ព័ន្ធទី៦)។

### គ. ការសុំអនុញ្ញាតច្បាប់ឈប់សំរាក

❖ **សម្រាប់បុគ្គលិក**

ចំពោះការសុំអនុញ្ញាតច្បាប់ឈប់សំរាករបស់គ្រូបង្រៀននៅទីនេះ គឺពួកគាត់អាចឈប់សំរាកបាននៅពេលណាដែលគាត់ត្រូវការ ប៉ុន្តែទាមទារឲ្យមានការសហការណ៍ជាមួយមិត្តរួមការងាររបស់ពួកគាត់ដើម្បីមកបង្រៀនសិស្សជំនួស ដោយមិនបង្កឲ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សនោះទេ។ ទោះបីជាមិនមានការរឹតបណ្ដឹងទៅលើច្បាប់ឈប់សំរាករបស់បុគ្គលិក ប៉ុន្តែគេសង្កេតឃើញថាគ្រូបង្រៀននៅទីនេះ មិនងាយនឹងសុំ

អនុញ្ញាតច្បាប់ឈប់សំរាកឡើយ លុះកណាពួកគាត់មានភារកិច្ចបន្ទាន់ដែលត្រូវឈប់ជាចាំបាច់ដោយខានពុំបាន។

❖ សម្រាប់សិស្ស

ចំណែកការសុំអនុញ្ញាតច្បាប់ឈប់សំរាករបស់សិស្សវិញ គឺគណៈគ្រប់គ្រងសាលាបានធ្វើការរឹតបន្តឹងយ៉ាងខ្លាំង ព្រោះពួកគាត់បានយកចិត្តទុកដាក់ជាខ្លាំងទៅលើការសិក្សារបស់សិស្ស និងតម្រូវឲ្យសិស្សមករៀនឲ្យបានទៀងទាត់ ជៀសវាងការខកខានរៀននូវមេរៀនណាមួយ ដែលអាចនឹងបណ្តាលឲ្យមានបញ្ហារៀនយឺតកើតមានចំពោះសិស្សផ្ទាល់។ ការអនុញ្ញាតឲ្យសិស្សឈប់សំរាកបាន ដរាបណាពួកគេមានធុររវល់ជាចាំបាច់ និងមានជំងឺ។ ករណីមានធុររវល់ ត្រូវបានអនុញ្ញាតឲ្យច្បាប់ឈប់សំរាកចំនួន៨ថ្ងៃក្នុងមួយឆ្នាំ (ច្បាប់នេះត្រូវបូកបន្ត)។ រីឯករណីមានជំងឺវិញ អាចឈប់សំរាករហូតដល់ជាសះស្បើយអាចមករៀនវិញបាន ប៉ុន្តែទាមទារឲ្យមានលិខិតពេទ្យបញ្ជាក់អំពីស្ថានភាពជំងឺ ភ្ជាប់មកជាមួយនៅពេលដែលសិស្សអាចត្រឡប់ចូលរៀនវិញបាន។ ជាមួយគ្នានេះដែរការសុំអនុញ្ញាតច្បាប់ឈប់សំរាករបស់សិស្ស តម្រូវឲ្យមាតាបិតា ឬអាណាព្យាបាលសិស្សជាអ្នកផ្តល់ដំណឹងតាមរយៈការតេទូរស័ព្ទមកកាន់គ្រូបន្ទុកថ្នាក់ផ្ទាល់ (មុនម៉ោងសិក្សា) ឬលោកនាយកសាលា (ក្នុងម៉ោងសិក្សា)។

### ៣.៤.២.៤ ការរៀបចំបរិស្ថានក្នុងបរិវេណសាលា

ការរៀបចំទីធ្លាសាលាបឋមសិក្សាវត្តបូព៌ ប្រកបដោយសណ្តាប់ធ្នាប់ មានរបៀបរៀបរយល្អប្រពៃ និងមានអនាម័យ។ ជាក់ស្តែងពេលដែលចូលទៅដល់ក្នុងទីធ្លាសាលា យើងសង្កេតឃើញថាមានដើមឈើធំៗជាច្រើនដុះស្កឹមស្កៃ សម្រាប់ផ្តល់ជាម្លប់ត្រជាក់ដល់លោកគ្រូ អ្នកគ្រូ ក៏ដូចជាសិស្សានុសិស្ស។ មួយវិញទៀតនៅក្នុងទីធ្លាសាលាក៏មានការរៀបចំជាពាក្យស្លោក និងសុភាសិតប្រកបដោយអត្ថន័យអប់រំដល់ជនានុជនទាំងឡាយសម្រាប់យកមកអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ និងមានការរៀបចំកន្លែងសម្រាប់សិស្សអង្គុយសម្រាកពេលចេញលេង ឬសម្រាប់អានសៀវភៅ មានបង្គន់អនាម័យស្អាត និងកន្លែងលាងសម្អាតដៃជាច្រើនគួរឲ្យកត់សម្គាល់។

ការគ្រប់គ្រងសំរាមនៅទីនេះគឺបានល្អប្រសើរ ដូចមានពាក្យមួយឃ្លាដែលប្រជាជននៅក្នុងតំបន់នោះតែងតែលើកឡើងអំពីសាលានេះគឺ "គ្មានធុងសំរាម ប៉ុន្តែក៏គ្មានសំរាម"។ ការគ្រប់គ្រងសំរាមបានល្អ គឺមកពីមានការចូលរួមសំខាន់ៗដូចជា៖

- គ្រូ និងសិស្សមានទំនួលខុសត្រូវចំពោះការរក្សាទុកដាក់សំរាមរៀងៗខ្លួន ហើយជារៀងរាល់ថ្ងៃសិស្សតែងតែធ្វើការបោសសំអាតទីធ្លាសាលា។

- បើនិយាយអំពីអាជីវករដែលលក់ដូរនៅក្នុងសាលា គឺពួកគាត់បានគោរពទៅតាមគោលការណ៍ដែលសាលាបានដាក់ឲ្យយ៉ាងខ្ជាប់ខ្ជួន ពោលគឺ អាហារទាំងអស់ត្រូវមានអនាម័យ តូបលក់ត្រូវមានរបៀបរៀបរយល្អ និងមានទំហំស្តង់ដា ការលក់ដូរមានការឯកភាពគ្នាទៅលើតម្លៃ តូបលក់ដូរត្រូវបានសាងសង់ដោយសាលា គ្មានចំណីអាហារប្រភេទស្ករគ្រាប់ អាជីវករមិនមែនជាបុគ្គលិកសាលារៀន អាជីវករត្រូវបង់ ១៨០,០០០រៀលក្នុងមួយខែ (សម្រាប់តូបលក់ និងសំរាម) មានទីតាំងសម្រាប់សិស្សញ៉ាំអាហារក្រៅពីតូបលក់ មិនអនុញ្ញាតឲ្យគ្រូលក់នំក្នុងសាលារៀន អ្នកលក់ជាប្រជាជនទាំងអស់ លក់ក្នុងតម្លៃសមរម្យសិស្សអាចញ៉ាំបាន តម្រូវឲ្យមានធុងសំរាមតាមតូបលក់ដូរ និងមានការគ្រប់គ្រងសំរាមដោយអាជីវករ ដែលមានការញែកសម្រាមជាពីរប្រភេទគឺ(បានការ និងមិនបានការ) ថ្លៃសំរាម សាលាជាអ្នកដោះស្រាយ (សូមមើលឧបសម្ព័ន្ធទី៧)។

#### ៣.៤.២.៥ សកម្មភាពនៃការបង្រៀន និងរៀន

##### ក. សកម្មភាពនៃការបង្រៀន និងរៀនប្រចាំថ្ងៃ

ចំពោះការបង្រៀនក្នុងថ្នាក់វិញ គឺលោកគ្រូអ្នកគ្រូបានយកចិត្តទុកដាក់ជាខ្លាំងក្នុងការបង្រៀនសិស្សដោយព្យាយាមពន្យល់ លើកឧទាហរណ៍ផ្សេងៗ ព្រមទាំងមានឧបករណ៍បច្ចេកទេសជាជំនួយដល់ការបង្រៀនដើម្បីឲ្យសិស្សកាន់តែងាយស្រួលយល់ ជាពិសេសសម្រាប់សិស្សចាប់ពីថ្នាក់ទី៣ឡើងទៅក៏មានការបង្រៀនតាមបែបទំនើបកម្មដោយប្រើប្រាស់ Slide សម្រាប់ពន្យល់ និងបង្ហាញដល់សិស្សទៀតផង។ បន្ថែមពីលើនេះទៅទៀតគ្រូបង្រៀនបានបង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល ពោលគឺមានការចូលរួមពីសិស្សយ៉ាងសកម្ម ដូចជា ការផ្តល់ឱកាសឲ្យសិស្សសួរ និងឆ្លើយសំណួរ ក៏ដូចជាលើកទឹកចិត្តឲ្យសិស្សហ៊ានបញ្ចេញមតិ និងរៀនដោះស្រាយនូវបញ្ហាដោយខ្លួនឯង ដោយមានការសម្របសម្រួលពីសំណាក់គ្រូបន្ទុកថ្នាក់ផ្ទាល់។ ក្រៅពីនេះនៅតាមថ្នាក់រៀននីមួយៗក៏មានបង្កើតនូវ Facebook group chat សម្រាប់ការធ្វើទំនាក់ទំនងជាមួយមាតាបិតាសិស្សដែលបង្កភាពងាយស្រួលក្នុងការជំរុញការសិក្សារបស់សិស្សផងដែរ។

ចំពោះសកម្មភាពក្នុងថ្នាក់វិញ កុមារចេះទុកដាក់ស្បែកជើងនៅលើធ្នើរ និងអង្គុយមានរបៀបរៀបរយតាមកន្លែងដែលបានកំណត់ យកចិត្តទុកដាក់ក្នុងការសិក្សា និងចូលរួមសកម្មភាពក្នុងថ្នាក់ ដូចជាសួរ និងឆ្លើយសំណួរយ៉ាងសកម្ម។ មួយវិញទៀតកុមារត្រូវបានបង្រៀនពីចំណេះដឹងទូទៅ ចំណេះដឹងផ្នែកបច្ចេកវិទ្យា (ICT) ចំណេះដឹងផ្នែកភាសាបរទេស អប់រំកាយ សិល្បៈតន្ត្រី របៀបអនាម័យ រក្សាទុកដាក់សំរាមដោយខ្លួនឯង និងបានយល់ដឹងពីប្រភេទសំរាមដែលត្រូវបោះចោល និងកែច្នៃឡើងវិញបានយ៉ាងត្រឹមត្រូវ។ សិស្សចេះគួរសមរាក់ទាក់ចំពោះភ្ញៀវ និងទទួលភ្ញៀវដោយទឹកមុខញញឹម។ ព្រមទាំងមានការបង្ហាត់សិស្សឱ្យចេះធ្វើ

សមាធិមួយថ្ងៃពីរដង មុនម៉ោងរៀន និងមុនចេញទៅផ្ទះ១៥នាទី។ មិនតែប៉ុណ្ណោះសិស្សត្រូវបានបង្ហាត់ឲ្យចេះពីរបៀបក្នុងការចូលរួមកម្មវិធីផ្សេងៗ ដូចជាការដង្ហែរក្បួនពេលបើកបវេសនកាលថ្មី ពិធីបុណ្យជាតិពិសាខបូជា មាឃបូជាជាដើម។ សកម្មភាពទាំងនេះជាការបង្រៀនកុមារឲ្យយល់ពីទំនៀមទម្លាប់របស់ខ្មែរ យល់ដឹងអំពីសាសនារបស់ជាតិ ក៏ដូចជាការបង្ហាត់ឲ្យពួកគេចេះស្រឡាញ់ និងថែរក្សានិមិត្តសញ្ញារបស់ជាតិយើងផងដែរ។

## ខ. សកម្មភាពនៃការរៀន និងបង្រៀននាសម័យកូវីដ១៩

ខណៈពេលដែលពិភពលោកទាំងមូលកំពុងតែប្រឈមមុខជាមួយជំងឺឆ្លងដ៏កាចសាហាវ គឺកូវីដ១៩ បានធ្វើឲ្យមានការកកស្ទះលើគ្រប់វិស័យ ក្នុងនោះក៏មានវិស័យអប់រំមួយផងដែរ ដែលសិស្ស និស្សិតគ្រប់កម្រិតថ្នាក់ត្រូវបានផ្អាក និងមិនអនុញ្ញាតឲ្យទៅសិក្សានៅសាលាដូចសព្វដង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏មិនអាចបញ្ឈប់ការរៀន និងបង្រៀនបានដែរ ព្រោះប្រមុខរាជរដ្ឋាភិបាល ពិសេសក្រសួងអប់រំ យុវជន និងកីឡាបានព្យាយាមស្វះស្វែងរកដំណោះស្រាយដើម្បីឲ្យការរៀន និងបង្រៀននៅតែអាចដំណើរការបាន។ ចំណែកគណៈគ្រប់គ្រងសាលា និងបុគ្គលិកទាំងអស់របស់សាលាបឋមសិក្សាវត្តបូព៌ក៏បានព្យាយាមរកគ្រប់មធ្យោបាយដើម្បីបានចែករំលែកចំណេះដឹងដល់សិស្សរបស់ខ្លួន ដោយផ្អែកជាចំបងទៅលើគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា។ ការរៀន និងបង្រៀននៅសម័យកូវីដ១៩របស់សាលាបឋមសិក្សាវត្តបូព៌មានរូបភាពដូចខាងក្រោម៖

- រូបភាពទី១ ៖ គ្រូ និងសិស្ស បានបង្រៀន និងរៀនពីចំងាយតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។
- រូបភាពទី២ ៖ គណៈគ្រប់គ្រងសាលាបានរៀបចំឲ្យគ្រូ និងសិស្ស បង្រៀន និងរៀនពីចំងាយតាមការផ្សាយផ្ទាល់ (Live) តាមកម្មវិធី Zoom Facebook private និងFacebook group chat។ របៀបនៃការបង្រៀន និងរៀន គឺក្រុមគ្រូបង្រៀនបានធ្វើការផ្សាយផ្ទាល់ និងមានការថតទុកជាឯកសារសម្រាប់ឲ្យសិស្សដែលមិនបានចូលរួមមើលការផ្សាយផ្ទាល់សម្រាប់មើលឡើងវិញផងដែរ។ ការប្រើប្រាស់កម្មវិធីទាំងនេះក៏មានការចូលរួមសហការណ៍ពីក្រុមហ៊ុន Koompi ដោយបានធ្វើការតម្លើងកម្មវិធី និងបង្ហាត់បង្ហាញដល់លោកគ្រូ អ្នកគ្រូ ព្រមទាំងមាតាបិតារបស់សិស្សអំពីការប្រើប្រាស់កម្មវិធីទាំងនោះផងដែរ។

❖ ការគ្រប់គ្រងលើគ្រូបង្រៀន

ជារៀងរាល់ថ្ងៃគ្រប់បុគ្គលិកទាំងអស់ត្រូវទៅសាលារៀននៅពេលព្រឹករយៈពេលមួយម៉ោងកន្លះចាប់ពីម៉ោង ៨ ដល់ ៩:៣០ ដើម្បីធ្វើការបង្រៀនតាមរយៈការផ្សាយផ្ទាល់។

❖ ការគ្រប់គ្រងសិស្ស

គ្រូបង្រៀនតែងតែទុកពេល១៥នាទីដើម្បីស្រង់វត្តមានសិស្ស មុននឹងធ្វើការបង្រៀន។ ការសិក្សារបស់សិស្សគឺត្រូវមានការសម្របសម្រួលពីមាតាបិតាសិស្ស និងមានទំនាក់ទំនងជាមួយគ្រូបន្ទុកថ្នាក់ជាចាំបាច់។ ជាក់ស្តែងដូចដែលជម្រាបជូនខាងលើគឺថ្នាក់រៀននីមួយៗត្រូវបានបង្កើតឲ្យមាន Facebook group chat ដើម្បីឲ្យសិស្សសួរអំពីមេរៀនដែលពួកគេយល់ពុំទាន់ច្បាស់ និងសម្រាប់ធ្វើកិច្ចការផ្ទះឲ្យគ្រូបន្ទុកថ្នាក់ត្រួតពិនិត្យវិញ។

(សូមមើលឧបសម្ព័ន្ធទី៩)

### ៣.៤.៣ ការទំនាក់ទំនងជាមួយសមាគមជាតិ និងអន្តរជាតិ

ការទំនាក់ទំនង គឺមិនអាចកាត់ផ្តាច់ពីការអភិវឌ្ឍបានឡើយ ជាពិសេសការទំនាក់ទំនងជាមួយសហគមន៍ គឺជាកត្តាគន្លឹះ និងចំបងដែលអាចទាក់ទាញ មជ្ឈដ្ឋានខាងក្រៅមកចូលរួមអភិវឌ្ឍន៍ទាំងធនធានមនុស្ស ថវិកា សម្ភារបរិក្ខារ ផ្សេងៗផងដែរ។ ជាញឹកញាប់សាលាបឋមសិក្សាវត្តបូព៌ត្រូវបានភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិជាច្រើនមកធ្វើទស្សនៈកិច្ចសិក្សា សិស្សនិស្សិតជាតិ និងអន្តរជាតិចុះកម្មសិក្សាសម្រាប់ទទួលយកបទពិសោធន៍គ្រប់គ្រង និងអប់រំនៅទីនោះផងដែរ។ កត្តាទាំងនេះបានជំរុញឲ្យសាលាកាន់តែមានកេរ្តិ៍ឈ្មោះល្បីសុះសាយតាមរយៈការផ្សព្វផ្សាយបន្ថែមរបស់កម្មសិក្សាវីទាំងនោះ និងបានបង្ហាញពីភាពទាក់ទាញចំពោះកំណែទម្រង់ដ៏ល្អមួយនេះ (សូមមើលឧបសម្ព័ន្ធទី១២)។

## ៣.៥ ស្នាដៃដែលសម្រេចបាន

ដោយសារតែការដាក់ចេញនូវគោលនយោបាយមួយដែលសមស្របទៅនឹងស្ថានភាពតំបន់ដោយផ្អែកលើផែនការរបស់ក្រសួងអប់រំ រួមជាមួយនឹងការដាក់ចេញនូវយុទ្ធសាស្ត្រផ្សេងៗសម្រាប់សម្រេចនូវគោលនយោបាយ ពិសេសគឺបានអនុវត្តទៅតាមផែនការដែលបានរៀបចំនោះទើបធ្វើឲ្យសាលាមួយនេះរមែងទទួលបាននូវការលើកសរសើរពីសំណាក់ថ្នាក់ដឹកនាំដែលមានដូចខាងក្រោម៖

### ៣.៥.១ ស្នាដៃរបស់នាយកសាលា

តាមរយៈការខិតខំប្រឹងប្រែងយ៉ាងស្វិតស្វាញក្នុងការដឹកនាំ និងគ្រប់គ្រងបានធ្វើឲ្យលោកនាយក

សាលាទទួលបាននូវសមិទ្ធផលដូចខាងក្រោម៖

- ឆ្នាំ ២០១៧ ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសមេដាយការងារថ្នាក់មាស
- ឆ្នាំ ២០១៧ ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសមេដាយការងារបារាំងថ្នាក់មាស
- ឆ្នាំ ២០១៦ ប្រកាសនីយប័ត្រ គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ
- ឆ្នាំ ២០១៦ ប័ណ្ណសរសើររដ្ឋមន្ត្រីក្រសួងបរិស្ថានជូននាយកសាលាគំរូ ដែលមានស្នាដៃល្អក្នុងការបញ្ជ្រាបចំណេះដឹងបរិស្ថាន
- ឆ្នាំ ២០១៥ ប្រកាសនីយប័ត្រ ពានរង្វាន់សម្តេចតេជោសែន នាយកល្អចំណាត់ថ្នាក់លេខ១
- ឆ្នាំ ២០១៥ ពានរង្វាន់ WAT BO PRIMARY SCHOOL, SIAM REAP CAMBODIA ASEAN ECO-SCHOOLS AWARD 2015 Primary School Category
- ឆ្នាំ ២០១៥ លិខិតសរសើរប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- ឆ្នាំ ២០១៣ ប្រកាសនីយប័ត្រគ្រឿងឥស្សរិយយសមេដាយការងារថ្នាក់មាស។

**៣.៥.២ ស្នាដៃអង្គភាព**

ចំពោះស្នាដៃដែលអង្គភាពសម្រេចបានមានដូចខាងក្រោម៖

- ២០១៧ វិញ្ញាបនបត្រទទួលស្គាល់ (ការអនុវត្តស្តង់ដារសាលាស្អាត) រដ្ឋមន្ត្រីក្រសួងទេសចរណ៍
- ឆ្នាំ ២០១៦ ប្រកាសនីយប័ត្រកិត្តិយសកម្មវិធីមហោស្រពតន្ត្រី និងចម្រៀងកុមារ ២០១៦ ដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- ២០១៦ ប័ណ្ណសរសើរដោយរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- ២០១៤ ប័ណ្ណសរសើរ (សុខភាពអនាម័យ) ក្រសួងអប់រំ យុវជន និងកីឡា/សុខាភិបាល
- ២០១១ ទង់ជ័យលាភីថ្នាក់លេខ១ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឆ្នាំ ២០០៩ ប័ណ្ណសរសើរ (ចំណាត់ថ្នាក់លេខ១) រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឆ្នាំ ២០០៦ ទង់ជ័យលាភីថ្នាក់លេខ២ ដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- ឆ្នាំ ២០០២ ប័ណ្ណសរសើរ (ចំណាត់ថ្នាក់លេខ១) រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា។

(សូមមើលឧបសម្ព័ន្ធទី១៣)

## ៣.៦ លទ្ធផលសិក្សារបស់សិស្សពីឆ្នាំ២០១៥ ដល់ ២០១៩

លទ្ធផលសិក្សារបស់សិស្សពីឆ្នាំ២០១៥ ដល់ ២០១៩ មានដូចខាងក្រោម៖

តារាង ៣៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៥ ~ ២០១៦

| | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| អត្រាឡើងថ្នាក់ | 89.32% | 95.70% | 97.32% | 98.50% | 98.90% | 100.00% |
| អត្រាត្រួតថ្នាក់ | 10.68% | 4.30% | 2.68% | 1.50% | 1.10% | 0.00% |
| អត្រាបោះបង់កាសិក្សា | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |
| អត្រាផ្ទេរចេញ | 3.04% | 2.01% | 1.26% | 0.74% | 1.53% | 1.42% |

ក្រាហ្វិច ១៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៥ ~ ២០១៦




តារាង ៤៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៦ ~ ២០១៧

| | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| អត្រាឡើងថ្នាក់ | 83.00% | 95.40% | 96.83% | 98.13% | 98.83% | 100.00% |
| អត្រាត្រួតថ្នាក់ | 17.00% | 4.60% | 3.17% | 1.87% | 1.17% | 0.00% |
| អត្រាបោះបង់ការសិក្សា | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |
| អត្រាផ្ទេរចេញ | 1.00% | 0.90% | 0.64% | 0.13% | 0.00% | 0.00% |

## ក្រាហ្វិច ២៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៦ ~ ២០១៧




## តារាង ៥៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៧ ~ ២០១៨

| | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| អត្រាឡើងថ្នាក់ | 84.42% | 95.03% | 97.61% | 97.90% | 97.72% | 100.00% |
| អត្រាត្រួតថ្នាក់ | 15.58% | 4.97% | 2.39% | 2.10% | 2.28% | 0.00% |
| អត្រាបោះបង់ការសិក្សា | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |
| អត្រាផ្ទេរចេញ | 0.27% | 0.94% | 0.00% | 0.66% | 0.00% | 0.00% |

## ក្រាហ្វិច ៣៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា ២០១៧ ~ ២០១៨



តារាង ៦៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា២០១៨ ~ ២០១៩

| | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ | ថ្នាក់ទី៤ | ថ្នាក់ទី៥ | ថ្នាក់ទី៦ |
|---|---|---|---|---|---|---|
| អត្រាឡើងថ្នាក់ | 84.42% | 95.03% | 97.61% | 97.90% | 97.72% | 100.00% |
| អត្រាត្រួតថ្នាក់ | 15.58% | 4.97% | 2.39% | 2.10% | 2.28% | 0.00% |
| អត្រាបោះបង់ការសិក្សា | 0.00% | 0.00% | 0.00% | 0.00% | 0.00% | 0.00% |
| អត្រាផ្ទេរចេញ | 0.27% | 0.94% | 0.00% | 0.66% | 0.00% | 0.00% |

ក្រាហ្វិច ៤៖ លទ្ធផលសិក្សាប្រចាំឆ្នាំសិក្សា២០១៨ ~ ២០១៩




ប្រភព៖ លទ្ធផលសិក្សារបស់សិស្សពីឆ្នាំ២០១៥ ដល់ ២០១៩ បានដកស្រង់ចេញពីប័ណ្ណព័ត៌មានអំពីស្ថានភាពសិក្សាអប់រំនៅសាលាបឋមសិក្សាវត្តបូព៌(ឆ្នាំ២០១៥ ដល់ ២០១៩)

តាមក្រាហ្វបានបង្ហាញថាការបញ្ចប់ការសិក្សារបស់សិស្សមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ពីឆ្នាំ ២០១៥ ដល់២០១៩។ ប៉ុន្តែគួរឲ្យកត់សម្គាល់ចំពោះអត្រាបោះបង់ការសិក្សា គឺ0,00% និងអត្រាឆ្លងភូមិសិក្សាបានដោយជោគជ័យគឺ ១០០%។

## ៣.៧ លទ្ធផលស្រាវជ្រាវ

ឆ្លងកាត់តាមរយៈការស្រាវជ្រាវចំពោះការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌រួចមក យើងសង្កេតឃើញថា ទាំងគណៈគ្រប់គ្រងសាលា និងបុគ្គលិកអប់រំនៅក្នុងអង្គភាពបានខិតខំបំពេញតួនាទីរបស់ខ្លួនជាខ្លាំងដោយការពេញចិត្ត និងពុំខ្លាចនឿយហត់ឡើយ ក្នុងគោលបំណងលើកស្ទួយវិស័យអប់រំនៅក្នុងប្រទេស

កម្ពុជាឲ្យកាន់តែមានភាពប្រសើរឡើងតាមរយៈការផ្តល់នូវសេវាអប់រំមួយដែលមានគុណភាព និងប្រសិទ្ធភាព។ ជាលទ្ធផលយើងក៏បានស្វែងយល់ពីចំណុចខ្លាំង ចំណុចខ្វះចន្លោះ របស់សាលាដូចខាងក្រោម៖

### ៣.៧.១ ចំណុចខ្លាំង

ដោយសារសាមគ្គីភាពរវាងគណៈគ្រប់គ្រងសាលា និងបុគ្គលិកអប់រំនៅក្នុងអង្គភាព ព្រមទាំងមាការសហការណ៍ពីមជ្ឈដ្ឋានជុំវិញ ដើម្បីឆ្ពោះទៅរកទិសដៅរួមមួយ ដែលញាំងឲ្យសាលាបឋមសិក្សាវត្តបូព៌សម្រេចបាននូវគោលដៅរបស់ខ្លួនជាបន្តបន្ទាប់ និងមានចំណុចខ្លាំងជាច្រើនដូចជា៖

តារាងទី៧៖ អត្រាឡើងថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩ (សូមមើលព័ត៌មានលម្អិតក្នុងឧបសម្ព័ន្ធទី២៧)

| ឆ្នាំសិក្សា | មធ្យមភាគនៃអត្រាឡើងថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ | |
|---|---|---|
| | មធ្យម | គម្លាតស្តង់ដា |
| 2015 - 2016 | 96.62% | 0.039 |
| 2016 - 2017 | 95.37% | 0.063 |
| 2017 - 2018 | 95.45% | 0.056 |
| 2018 - 2019 | 95.66% | 0.056 |
| មធ្យមភាគនៃអត្រាឡើងថ្នាក់រយៈពេល៤ឆ្នាំចាប់ពីឆ្នាំ២០១៥ ដល់២០១៩សម្រាប់ថ្នាក់ទី១ ដល់ទី៦ | 95.77% | 0.053 |

- បើយោងតាមតារាង មធ្យមភាគនៃអត្រាឡើងថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ ក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩ ជាមធ្យមគឺ ៩៥.៧៧% និងមានមធ្យមនៃគម្លាតស្តង់ដា ០.០៥៣ ដែលបង្ហាញពីភាពលំអៀងតិចតួច និងមានលទ្ធផលនៃការសិក្សាល្អដែលគួរឲ្យចាប់អារម្មណ៍ ។
- អត្រាឆ្លងភូមិសិក្សារបស់សិស្សក្នុងអត្រា ១០០% ជារៀងរាល់ឆ្នាំក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩ (សូមមើលព័ត៌មានលម្អិតក្នុងឧបសម្ព័ន្ធទី២៧)។
- អត្រាបោះបង់ការសិក្សារបស់សិស្សក្នុងអត្រា 0.00% ជារៀងរាល់ឆ្នាំក្នុងចន្លោះឆ្នាំ ២០១៥ ដល់ ២០១៩(សូមមើលព័ត៌មានលម្អិតក្នុងឧបសម្ព័ន្ធទី២៧)។

ក្រៅពីការទទួលបាននូវលទ្ធផលល្អប្រសើរនៃការសិក្សាផ្នែកចំណេះដឹងទូទៅ សិស្សក៏ទទួលនូវបំណិនផ្នែកជំនាញទន់ដូចជា៖

- ការចេះគោរពនូវវិន័យបានយ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយរបៀបរៀបរយ។
- ការសម្របសម្រួលការវិយាបថទៅតាមកាលៈទេសៈបានល្អ ដូចជារាល់ពេលចូលរួមក្នុងកម្មវិធី ដង្ហែក្បួនសម្រាប់ពិធីបុណ្យមាឃបូជា ពិសាខបូជា ទទួលស្វាគមន៍គណៈប្រតិភូជាតិ និងអន្តរជាតិជាដើម។
- ការចូលរួមក្នុងការងារសង្គមដូចជា ការចេះរក្សាទុកដាក់សំរាមដោយខ្លួនឯងបានយ៉ាងត្រឹមត្រូវ ការសម្រួលចរាចរណ៍នៅខាងមុខក្លោងទ្វារសាលា ការដកហូតនំចំណីដែលខូចគុណភាពពីអាជីវករក្នុងសាលា។

### ៣.៧.២ ចំណុចខ្វះចន្លោះ

បើទោះបីជាគណៈគ្រប់គ្រងសាលា និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ប្រឹងប្រែងក្នុងការបំពេញកាតព្វកិច្ចយ៉ាងណាក៏ដោយ គឺតែងមានចំណុចខ្វះចន្លោះដែលពុំទាន់អាចសម្រេចបាន។ ចំណុចទាំងនោះរួមមាន៖

តារាង៨៖ អត្រាត្រួតថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩ (សូមមើលព័ត៌មានលម្អិតក្នុងឧបសម្ព័ន្ធទី២៧)

| ឆ្នាំសិក្សា | មធ្យមភាគនៃអត្រាត្រួតថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ | |
|---|---|---|
| | មធ្យម | គម្លាតស្តង់ដា |
| 2015 - 2016 | 3.38% | 0.039 |
| 2016 - 2017 | 4.64% | 0.063 |
| 2017 - 2018 | 4.55% | 0.056 |
| 2018 - 2019 | 4.18% | 0.052 |
| មធ្យមភាគនៃអត្រាត្រួតថ្នាក់រយៈពេល៤ឆ្នាំចាប់ពីឆ្នាំ២០១៥ ដល់ ២០១៩សម្រាប់ថ្នាក់ទី១ ដល់ទី៦ | 4.19% | 0.052 |

- បើយោងតាមតារាង មធ្យមភាគនៃអត្រាត្រួតថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ ក្នុងចន្លោះឆ្នាំ ២០១៥

ដល់២០១៩ ជាមធ្យមគឺ ៤.១៩% និងមានមធ្យមនៃគម្លាតស្តង់ដា 0.0៥២ ដែលបង្ហាញពីភាពលំអៀងតិចតួច។

តារាង៩៖ អត្រាត្រួតថ្នាក់របស់សិស្សគិតជាមធ្យមប្រចាំឆ្នាំសិក្សានីមួយៗពីឆ្នាំ ២០១៥ ដល់២០១៩ (សូមមើលព័ត៌មានលម្អិតក្នុងឧបសម្ព័ន្ធទី២៧)

| ឆ្នាំសិក្សា | មធ្យមភាគនៃអត្រាផ្ទេរចេញចាប់ពីថ្នាក់ទី១ ដល់ទី៦ | |
|---|---|---|
| | មធ្យម | គម្លាតស្តង់ដា |
| 2015 - 2016 | 1.67% | 0.008 |
| 2016 - 2017 | 0.45% | 0.005 |
| 2017 - 2018 | 0.31% | 0.004 |
| 2018 - 2019 | 0.71% | 0.012 |
| មធ្យមភាគនៃអត្រាផ្ទេរចេញថ្នាក់រយៈពេល៤ឆ្នាំចាប់ពីឆ្នាំ២០១៥ ដល់២០១៩សម្រាប់ថ្នាក់ទី១ ដល់ទី៦ | 0.78% | 0.007 |

- បើយោងតាមតារាង មធ្យមភាគនៃអត្រាអត្រាផ្ទេរចេញចាប់ពីថ្នាក់ទី១ ដល់ទី៦ ក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩ ជាមធ្យមគឺ 0.៧៨% និងមានមធ្យមនៃគម្លាតស្តង់ដា 0.00៧ ដែលបង្ហាញពីភាពលំអៀងតិចតួច។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវពីសាលាបឋមសិក្សាវត្តបូព៌រួចមក យើងសង្កេតឃើញថា សាលាបឋមសិក្សាវត្តបូព៌មានចំណុចល្អជាច្រើន ដែលអាចឲ្យយើងសន្និដ្ឋានបានថា :

- គណៈគ្រប់គ្រងសាលាបានយកចិត្តទុកដាក់ចំពោះការគ្រប់គ្រងសាលាដោយបានរៀបចំជាផែនការយុទ្ធសាស្ត្ររបស់សាលាផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងក្រសួងអប់រំ យុវជន និងកីឡា និងអនុវត្តបានយ៉ាងខ្ជាប់ខ្ជួន ដើម្បីឈានឆ្ពោះទៅរកការរីកចំរើនជានិរន្តរភាពរបស់សាលា។ ជាក់ស្តែងដូចជា៖
    - សាលាបានធ្វើការពង្រឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយកត្តាខាងក្រៅដូចជា ការជួបប្រជុំជាមួយមាតាបិតា អាណាព្យបាលសិស្ស អាជ្ញាធរពាក់ព័ន្ធដើម្បីផ្សព្វផ្សាយពីផែនការសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ក្នុងនោះដែរគេឃើញថា៩១,៨% (សូមមើលឧបសម្ព័ន្ធទី១៧) នៃសំណាកគំរូដែលបានមកពីការសម្ភាសន៍មហាជន៩៧នាក់ (សូមមើលឧបសម្ព័ន្ធទី១៥) បានឆ្លើយថាមាតាបិតាសិស្សតែងតែចូលរួមជាមួយសកម្មភាពរបស់សាលាដើម្បីតាមដាន និងជំរុញការសិក្សារបស់សិស្ស។
    - ក្នុងករណីកូវីដ១៩សាលាបានដាក់ចេញនូវគោលការណ៍ដែលបន្ថែមលើគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ដោយតម្រូវឲ្យសិក្សាតាមកម្មវិធី Zoom Facebook private និងFacebook group chat ហើយសម្រាប់ការប្រើប្រាស់កម្មវិធីទាំងនេះក៏មានការចូលរួមសហការពីក្រុមហ៊ុន Koompi ដោយបានធ្វើការតម្លើងកម្មវិធី និងបង្ហាត់បង្ហាញដល់លោកគ្រូអ្នកគ្រូ ព្រមទាំងមាតាបិតារបស់សិស្សអំពីការប្រើប្រាស់កម្មវិធីទាំងនោះផងដែរ។
    - សាលាបានផ្តល់នូវការអប់រំឲ្យសិស្សយល់ដឹងពីសន្តិសុខ និងសុវត្ថិភាពផ្ទាល់ខ្លួនបានល្អជាក់ស្តែង គេសង្កេតឃើញថាជារៀងរាល់ថ្ងៃតែងតែមានក្រុមប្រឹក្សាកុមារសម្រួលចរាចរណ៍នៅខាងមុខក្លោងទ្វារសាលានៅរាល់ពេលមុន និងក្រោយពេលចេញពីរៀន។ ម្យ៉ាងទៀតសាលាក៏បានរៀបចំកន្លែងសម្រាប់សិស្សអង្គុយរងចាំមាតាបិតា ឬអាណាព្យាបាលមកទទួលពេលម៉ោងចេញពីសាលា ដើម្បីធានាសុវត្ថិភាពរបស់សិស្សផងដែរ ។
- ការគ្រប់គ្រងប្រកបដោយភាពម៉ឺងម៉ាត់ និងមានវិន័យស្មើរគ្រប់ផ្នែក ទាំងការគ្រប់គ្រងការងារបុគ្គលិកវិន័យ សណ្តាប់ធ្នាប់ អនាម័យ បរិស្ថាន ការបង្រៀន និងការរៀន ដែលជាគំរូមួយដ៏ប្រសើរសម្រាប់

មនុស្សជាតិ ពិសេសគឺកុមារដែលបានឃើញ និងចូលរួមយ៉ាងសកម្មក្នុងបរិបទនៃការគ្រប់គ្រងដ៏ល្អមួយនេះ។ តួយ៉ាងមានមតិមហាជន៨៥,៦០% (សូមមើលឧបសម្ព័ន្ធទី១៨) ដែលយល់ថាការរៀបចំទីធ្លាសាលាប្រកបដោយសណ្តាប់ធ្នាប់។

- សាលាបានយកចិត្តទុកដាក់ក្នុងការអប់រំ បណ្តុះបណ្តាលដល់កុមារនូវចំណេះដឹងទូទៅប្រកបដោយគុណភាព មានបំណិនជីវិត តាមរយៈការសិក្សាពីការថែរក្សាសុខភាព អនាម័យ ការអប់រំឲ្យមានឥរិយាបថថ្លៃថ្នូរ ពោលគឺសុជីវធម៌ សីលធម៌ និងគុណធម៌ ការចូលរួមចំណែកក្នុងការងារសង្គម និងសកម្មភាពផ្សេងៗទៀត ដែលនឹងដឹកនាំឲ្យពួកគេក្លាយជាធនធានមនុស្សដ៏ចាំបាច់សម្រាប់តម្រូវការសង្គមឲ្យស្របទៅនឹងយុគសម័យនៃការរីកចំរើនផ្នែកបច្ចេកវិទ្យា។ តួយ៉ាងមាន ៨២,៥០% (សូមមើលឧបសម្ព័ន្ធទី២៤) នៃមតិមហាជនបានយល់ឃើញថាសិស្សនៅទីនេះពិតជាបានយកចិត្តទុកដាក់ក្នុងការសិក្សា និង ៧១,១០% (សូមមើលឧបសម្ព័ន្ធ២៣) បានសង្កេតឃើញថាសិស្សមានអត្តចរិតល្អ និងឥរិយាបថសមរម្យ។
- ជាលទ្ធផលការសិក្សារបស់សិស្សទទួលបាននូវលទ្ធផលល្អដែលៈ
  - មធ្យមភាគនៃអត្រាឡើងថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ទី៦ ក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩ ជាមធ្យមគឺ ៩៥.៧៧% និងមានមធ្យមនៃគម្លាតស្តង់ដា ០.០៥៣។
  - អត្រាឆ្លងភូមិសិក្សារបស់សិស្សក្នុងអត្រា ១០០% ជារៀងរាល់ឆ្នាំក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩។
  - អត្រាបោះបង់ការសិក្សារបស់សិស្សក្នុងអត្រា ០.០០% ជារៀងរាល់ឆ្នាំក្នុងចន្លោះឆ្នាំ ២០១៥ ដល់២០១៩។

ទាំងអស់នេះនឹងជួយដល់ការអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌កាន់តែមានភាពប្រសើរឡើង ពិសេសសង្គមជាតិនឹងទទួលបាននូវធនធានមនុស្ស ប្រកបដោយសក្តានុពល ដែលជាទីពំនាក់ពុំអាចខ្វះបានសម្រាប់គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល។

អាស្រ័យដូចដែលបានរៀបរាប់ខាងលើនេះមក បានបង្ហាញឲ្យឃើញថាសាលាបឋមសិក្សាវត្តបូព៌បានយកចិត្តទុកដាក់ក្នុងការអប់រំដល់មនុស្សជំនាន់ក្រោយយ៉ាងសកម្ម ដើម្បីឲ្យពួកគាត់ទទួលបាននូវការអប់រំមួយដែលត្រឹមត្រូវ និងមានគុណភាព ព្រមទាំងបញ្ចប់ការសិក្សាដោយជោគជ័យ និងបន្តឈានឆ្ពោះទៅរកអាជីពក្នុងក្តីស្រម៉ៃរបស់ពួកគាត់ផងដែរ។

## ២. អនុសាសន៍

បច្ចុប្បន្នការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌គឺមានភាពល្អប្រសើរទាំងផ្នែករដ្ឋបាលគ្រប់គ្រង និងការបង្រៀន និងរៀន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយសាលាបឋមសិក្សាវត្តបូព៌នៅមានចំណុចខ្វះខាតមួយចំនួននៅឡើយដែលយើងសូមផ្តល់ជាអនុសាសន៍ដល់សាលាបឋមសិក្សាវត្តបូព៌ និងសូមសំណូមពរឲ្យគណៈគ្រប់គ្រងសាលាធ្វើការស្រាវជ្រាវបន្ថែមទៀតដើម្បីឲ្យឃើញកាន់តែច្បាស់ពីបញ្ហាស្នូល រួចចាត់វិធានការណ៍ដោះស្រាយឲ្យបានសមស្របទៅនឹងឥរិយាបថរបស់ប្រជាជនដែលរស់នៅតំបន់នោះ ហើយចំណុចគួរកែលំអរឡើងវិញមានដូចខាងក្រោម៖

- សាលាបឋមសិក្សាវត្តបូព៌គួរតែពង្រឹងលើវិន័យបន្ថែមទៀតលើការគ្រប់គ្រងសិស្ស ព្រោះកន្លងមកធ្លាប់មានការបង្កជម្លោះរវាងសិស្ស និងសិស្សមួយចំនួនតូច ជាពិសេសចំពោះសិស្សថ្នាក់ទី៦។
- លោកគ្រូ អ្នកគ្រូ គួរតែចូលរួមបន្ថែមទៀតជាមួយក្រុមប្រឹក្សាកុមារលើការសម្រួលចរាចរណ៍នៅតាមដងផ្លូវរាល់ពេលសិស្សចូល និងចេញពីរៀន។
- សាលាគួរតែពង្រឹងលើការសម្អាតបន្ទប់ទឹក បង្គន់អនាម័យបន្ថែមទៀត ដើម្បីឲ្យត្រូវតាមស្តង់ដានៃការប្រើប្រាស់របស់សិស្ស។ ជាក់ស្តែងបើតាមទិន្នន័យដែលបានមកពីការសម្ភាសន៍មហាជនមានមតិ ៤៧,៤០%(សូមមើលឧបសម្ព័ន្ធទី១៩) ក៏បានសំណូមពរឲ្យមានការកែលំអរផងដែរ។

# ឯកសារយោង

## ➢ ប្រភេទសៀវភៅ


១. Antoneitta Campus (1987), “marginal economics”, The New Palgrave: A Dictionary of Economics, v.3, p. 323

២. ដកស្រង់ពី International Encyclopedia of Education-Education and Economic Growth (2010) vol.2 ទំព័រ ២៤៥

៣. ដកស្រង់ពីសៀវភៅ ប្រវត្តិនៃការអប់រំ បឋម និងមធ្យមសិក្សានៅកម្ពុជា និពន្ធដោយបណ្ឌិតប្រវត្តិវិទ្យា ស៊ន សំណាង និងអតីតអធិការបឋមសិក្សា លោក យ៉ង់ ធី ឆ្នាំ១៩៩៨

៤. Strategies and Policies for Basic Education in Cambodia: Historical Perspectives Sideth S. Dy (In 2004)

៥. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ. យ. អ. ជ.) ២០១៩-២០២៣ (ឆ្នាំ២០១៩)

៦. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (ឆ្នាំ២០១៩)

៧. ផែនការអភិវឌ្ឍន៍សាលាបឋមសិក្សាវត្តបូព៌ឆ្នាំ២០១៩-២០២៣ (ឆ្នាំ២០២០)

៨. Thesis master growth and development studies by Berhane, Melles (page 3-10)

៩. ច្បាប់ស្តីពីការអប់រំ (ឆ្នាំ២០០៧)

១០. មគ្គុទេសក៏កំណែទម្រង់គុណានុភាពនៃសាលាបឋមសិក្សាវត្តបូព៌ ដែលរៀបរៀងដោយសាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០២០


## ➢ ប្រភេទគេហទំព័រ


១១. https://www.pinterest.com/pin/408138784979923837/ ( ទស្សនៈរបស់ prof. H. Mahmud Yunus)

១២. https://www.mext.go.jp/en/

១៣. http://www.en.moe.go.th/enMoe2017/

១៤. https://www.moe.gov.sg/

## ឧបសម្ព័ន្ធទី ១៖ ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាកុមារប្រចាំសាលា


















## ឧបសម្ព័ន្ធទី២៖ សកម្មភាពក្រុមប្រឹក្សាបំពេញភារកិច្ច







## ឧបសម្ព័ន្ធទី៣៖ ឯកសណ្ឋានរបស់គ្រូបង្រៀន












ឧបសម្ព័ន្ធទី៤៖ ឯកសណ្ឋានរបស់សិស្ស





ឧបសម្ព័ន្ធទី៥៖ សកម្មភាពស្កេនមេដៃដើម្បីស្រង់វត្តមានរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌





ឧបសម្ព័ន្ធទី៦៖ ការធ្វើសមាធិពេលគោរពទង់ជាតិ




ឧបសម្ព័ន្ធទី៧៖ អាហារដ្ឋានក្នុងសាលាបឋមសិក្សាវត្តបូព៌






ឧបសម្ព័ន្ធទី៨៖ សកម្មភាពនៃការសិក្សាក្នុងសាលាបឋមសិក្សាវត្តបូព៌











ឧបសម្ព័ន្ធទី៩៖ សកម្មភាពនៃការរៀន និងបង្រៀនក្នុងសម័យកូវីដ១៩របស់សាលាបឋមសិក្សាវត្តបូព៌








ឧបសម្ព័ន្ធទី១០៖ អាណាព្យាបាលរបស់សិស្សចូលរួមក្នុងសកម្មភាពសាលា



ឧបសម្ព័ន្ធទី១១៖ សកម្មភាពដែលព្រះសង្ឃអប់រំដល់សិស្សានុសិស្ស



ឧបសម្ព័ន្ធទី១២៖ សកម្មភាពដែលភ្ញៀវជាតិ និងអន្តរជាតិមកធ្វើទស្សនកិច្ចនៅសាលាបឋមសិក្សាវត្តបូព៌







ឧបសម្ព័ន្ធទី១៣៖ ប័ណ្ណសរសើរ និងពានរង្វាន់ផ្សេងដែលសាលាបឋមសិក្សាវត្តបូព៌ទទួលបាន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡា
ខេត្តសៀមរាប

លិខិតសរសើរ

ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា ខេត្តសៀមរាប

សូមអបអរសាទរ និងសម្តែងនូវការកោតសរសើរដ៏ជ្រាលជ្រៅជូន **កញ្ញា. គុច បណ្ណូល** គ្រូបង្រៀនថ្នាក់ទី ៣(ក) នៅ **សាលាបឋមសិក្សាវត្តបូព៌** ដែលទទួលបាននូវស្នាដៃជាជ័យលាភីពានរង្វាន់ **សម្តេចតេជោ សែន** ក្នុងចំណាត់ថ្នាក់ជាគ្រូបង្រៀនល្អ ក្នុងក្របខណ្ឌទូទាំងប្រទេស ឆ្នាំសិក្សា ២០១៣-២០១៤ ។

ធ្វើនៅសៀមរាប.ថ្ងៃទី...ខែមេសា ឆ្នាំ២០១៥
ប្រធានមន្ទីរអប់រំ យុវជន និងកីឡា

អ៊ិង ពិរិទ្ធិ


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ប័ណ្ណសរសើរ


ពានរង្វាន់
សម្តេចតេជោ សែន
១




ASEAN
ECO-SCHOOLS AWARD
2015
Primary Schools Category



## ឧបសម្ព័ន្ធទី១៤៖ កម្រងសំណួរ

ជំរាបសួរ! យើងខ្ញុំឈ្មោះ ជុំ ពេជ្រនីតា និង អ៊ុន វឌ្ឍនា ជានិស្សិតមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី ៤។ គោលបំណងនៃការបង្កើតកម្រងសំណួរនេះ គឺដើម្បីសាកសួរពត៌មានមួយចំនួនដែលទាក់ទងទៅនឹងសកម្មភាពនៃការបង្រៀន និងរៀននៅក្នុងសាលាបឋមសិក្សាវត្តបូព៌ រួចយកមកសរសេរជារបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទមួយដែលនិយាយពី "ប្រសិទ្ធភាពនៃការអប់រំនៅសាលាបឋមសិក្សាវត្តបូព៌"។

### I. អំពីព័ត៌មានផ្ទាល់ខ្លួន

1. ភេទ៖ *

   a. ប្រុស

   b. ស្រី

2. មុខងារ៖ *

   a. គ្រូបង្រៀន

   b. អាណាព្យាបាលសិស្ស

   c. ប្រជាជន

   d. សិស្ស

### II. គោលការណ៍ និងវិន័យរបស់សាលា

3. តើសាលាមានការសហការណ៍គ្នាជាមួយមាតាបិតា/អាណាព្យាបាលសិស្សសម្រាប់តាមដានការសិក្សារបស់សិស្សដែរឺទេ? *

   a. មានការសហការណ៍

   b. មិនសូវមានការសហការណ៍

### III. សណ្តាប់ធ្នាប់ និងអនាម័យ

4. តើអ្នកយល់យ៉ាងណាដែរចំពោះការរៀបចំសណ្តាប់ធ្នាប់ក្នុងទីធ្លាសាលាបឋមសិក្សាវត្តបូព៌? (សណ្តាប់ធ្នាប់សាលាសំដៅលើ៖ បរិស្ថានស្អាត ការរៀបចំសាលាមានសោភ័ណភាព មានពាក្យស្លោក និងសុភាសិតសម្រាប់អប់រំដល់ជនានុជនទាំងឡាយ សួនកំសាន្តសម្រាប់កុមារ...) *

   a. មានការរៀបចំបានល្អ ប្រកបដោយផាសុខភាព និងមានអនាម័យ

   b. ការរៀបចំបានល្អបង្គួរ

   c. ទាំងការរៀបចំ និងអនាម័យពុំទាន់បានល្អនៅឡើយ

5. តើបង្គន់អនាម័យនៅក្នុងសាលាបឋមសិក្សាវត្តបូព៌មានលក្ខណៈដូចម្តេច? *

   a. មានសភាពស្អាត និងមានអនាម័យ

   b. មានសភាពល្អបង្គួរ

   c. មានសភាពមិនសូវស្អាត និងមិនមានអនាម័យ

6. តើនៅក្នុងសាលាបឋមសិក្សាវត្តបូព៌មានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ដែរឬទេ? *

   a. មានទឹកស្អាតសម្រាប់ប្រើប្រាស់គ្រប់គ្រាន់
   b. មានទឹកស្អាតសម្រាប់ប្រើប្រាស់ ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយទេ
   c. មិនមានទឹកស្អាតសម្រាប់ប្រើប្រាស់ទេ

**IV. បុគ្គលិកលក្ខណៈរបស់គ្រូបង្រៀន និងសិស្សនៅសាលាបឋមសិក្សាវត្តបូព៌**

7. តើគ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌មានអត្តចរិតដូចម្តេច? *

   a. មានអត្តចរិតល្អ សម្រាប់ជាគំរូដល់ក្មេងៗ
   b. មានអត្តចរិតល្អបង្គួរ
   c. មានអត្តចរិតមិនសូវល្អ

8. បើតាមការយល់ឃើញរបស់លោកអ្នក តើកម្រិតនៃការយកចិត្តទុកដាក់ក្នុងការបង្រៀនរបស់គ្រូបង្រៀន នៅសាលាបឋមសិក្សាវត្តបូព៌មានលក្ខណៈយ៉ាងដូចម្តេចដែរ? *

   a. បានយកចិត្តទុកដាក់ក្នុងកម្រិតខ្ពស់
   b. បានយកចិត្តទុកដាក់ក្នុងកម្រិតក្នុងកម្រិតបង្គួរ
   c. បានយកចិត្តទុកដាក់ក្នុងកម្រិតមធ្យម
   d. បានយកចិត្តទុកដាក់ក្នុងកម្រិតទាប

9. តើសិស្សនៅសាលាបឋមសិក្សាវត្តបូព៌មានអត្តចរិតបែបណា? *

   a. មានអត្តចរិតល្អ
   b. មានអត្តចរិតល្អបង្គួរ
   c. មានអត្តចរិតមិនសូវល្អ

10. តើសិស្សនៅសាលាបឋមសិក្សាវត្តបូព៌បានយកចិត្តទុកដាក់ក្នុងការសិក្សាដែរឬទេ? *

   a. បានយកចិត្តទុកដាក់រៀនសូត្រជាខ្លាំងទាំងក្នុង និងក្រៅសាលា
   b. បានយកចិត្តទុកដាក់រៀនសូត្រក្នុងកម្រិតបង្គួរទាំងក្នុង និងក្រៅសាលា
   c. មិនសូវមានការយកចិត្តទុកដាក់រៀនសូត្រទេទាំងក្នុង និងក្រៅសាលា

11. តើអ្នកយល់យ៉ាងណាដែរចំពោះកំណែទម្រង់ថ្មីរបស់សាលាបឋមសិក្សាវត្តបូព៌? *

   a. មានភាពល្អប្រសើរជាងមុនទាំងការគោរពគោលការណ៍ វិន័យរបស់សាលា និងគុណភាពល្អ
   b. មានភាពល្អប្រសើរចំពោះការគោរពគោលការណ៍ និងវិន័យរបស់សាលា ប៉ុន្តែគុណភាពអប់រំពុំទាន់បានល្អនៅឡើយទេ
   c. ពុំទាន់មានភាពល្អនៅឡើយទេទាំងការគោរពគោលការណ៍របស់សាលា និងគុណភាពអប់រំ

ឧបសម្ព័ន្ធទី១៥៖ ចំនួនមហាជនគិតទៅតាមភេទ




ឧបសម្ព័ន្ធទី១៦៖ ចំនួនមហាជនគិតទៅតាមមុខងារ




ឧបសម្ព័ន្ធទី១៧៖ ការយល់ឃើញចំពោះកម្រិតនៃការសហការណ៍គ្នារវាងគ្រូ និងមាតាបិតាឬអាណាព្យាបាលសិស្សក្នុងការតាមដានការសិក្សារបស់សិស្ស



ឧបសម្ព័ន្ធទី១៨៖ ការរៀបចំសណ្ដាប់ធ្នាប់ក្នុងទីធ្លាសាលាបឋមសិក្សាវត្តបូព៌ (សំដៅលើការរៀបចំផ្នែកបរិស្ថានស្អាត ការរៀបចំសាលាឲ្យមានសោភ័ណភាព មានពាក្យស្លោក និងសុភាសិតសម្រាប់អប់រំដល់ជនានុជនទាំងឡាយ មានសួនកំសាន្តសម្រាប់កុមារ




ឧបសម្ព័ន្ធទី១៩៖ សភាពលក្ខណៈបង្គន់អនាម័យនៅក្នុងសាលាបឋមសិក្សាវត្តបូព៌



ឧបសម្ព័ន្ធទី២០៖ ទឹកស្អាតសម្រាប់ប្រើប្រាស់នៅក្នុងសាលា




ឧបសម្ព័ន្ធទី២១៖ បុគ្គលិកលក្ខណៈរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌



ឧបសម្ព័ន្ធទី២២៖ កម្រិតនៃការយកចិត្តទុកដាក់ក្នុងការបង្រៀនរបស់គ្រូបង្រៀននៅសាលាបឋមសិក្សាវត្តបូព៌




ឧបសម្ព័ន្ធទី២៣៖ បុគ្គលិកលក្ខណៈរបស់សិស្សនៅសាលាបឋមសិក្សាវត្តបូព៌



## ឧបសម្ព័ន្ធទី២៤៖ កម្រិតនៃការយកចិត្តទុកដាក់ក្នុងការសិក្សារបស់សិស្សនៅសាលាបឋមសិក្សាវត្តបូព៌




## ឧបសម្ព័ន្ធទី២៥៖ ការយល់ឃើញចំពោះកំណែទម្រង់ថ្មីរបស់សាលាបឋមសិក្សាវត្តបូព៌



ឧបសម្ព័ន្ធទី២៧៖ លទ្ធផលនៃការសិក្សារបស់សិស្សចន្លោះឆ្នាំ ២០១៥ ដល់ ២០១៩

| ឆ្នាំសិក្សា | ថ្នាក់ទី | អត្រាឡើងថ្នាក់ | អត្រាត្រួតថ្នាក់ | អត្រាបោះបង់ការសិក្សា | អត្រាផ្ទេរចេញ |
|---|---|---|---|---|---|
| **២០១៥ ~ ២០១៦** | ១ | ៨៩,៣២ % | ១០,៦៨% | ០,០០% | ៣,០៤% |
| | ២ | ៩៥,៧០% | ៤,៣០% | ០,០០% | ២,០១% |
| | ៣ | ៩៧,៣២% | ២,៦៨% | ០,០០% | ១,២៦% |
| | ៤ | ៩៨,៥០% | ១,៥០% | ០,០០% | ០,៧៤% |
| | ៥ | ៩៨,៩០% | ១,១០% | ០,០០% | ១,៥៣% |
| | ៦ | ១ | ០,០០% | ០,០០% | ១,៤២% |
| **២០១៦ ~ ២០១៧** | ១ | ៨៣,០០% | ១៧,០០% | ០,០០% | ១,០០% |
| | ២ | ៩៥,៤០% | ៤,៦០% | ០,០០% | ០,៩% |
| | ៣ | ៩៦,៨៣% | ៣,១៧% | ០,០០% | ០,៦៤% |
| | ៤ | ៩៨,១៣% | ១,៨៧% | ០,០០% | ០,១៣% |
| | ៥ | ៩៨,៨៣% | ១,១៧% | ០,០០% | ០,០០% |
| | ៦ | ១ | ០,០០% | ០,០០% | ០,០០% |
| **២០១៧ ~ ២០១៨** | ១ | ៨៤,៤២% | ១៥,៥៨% | ០,០០% | ០,២៧% |
| | ២ | ៩៥,០៣% | ៤,៩៧% | ០,០០% | ០,៩៤% |
| | ៣ | ៩៧,៦១% | ២,៣៩% | ០,០០% | ០,០០% |
| | ៤ | ៩៧,៩០% | ២,១០% | ០,០០% | ០,៦៦% |
| | ៥ | ៩៧,៧២% | ២,២៨% | ០,០០% | ០,០០% |
| | ៦ | ១ | ០,០០% | ០,០០% | ០,០០% |
| **២០១៨ ~ ២០១៩** | ១ | ៨៥,៩៥% | ១៤,០៥% | ០,០០% | ២,៩៥% |
| | ២ | ៩៥,០០% | ៥,០០% | ០,០០% | ០,០០% |
| | ៣ | ៩៦,០០% | ៤,០០% | ០,០០% | ០,២៩% |
| | ៤ | ៩៩,០០% | ១,០០% | ០,០០% | ០,០០% |
| | ៥ | ៩៩,០០% | ១,០០% | ០,០០% | ១,០០% |
| | ៦ | ១ | ០,០០% | ០,០០% | ០,០០% |

ឧបសម្ព័ន្ធទី២៨៖ សំណើសុំអនុញ្ញាតចុះកម្មសិក្សា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
លេខ..៤៦៤...ស.ភ.ន.វ.ស

ថ្ងៃ អង្គារ ៧ កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២០

ជម្រាបជូន
លោកនាយកសាលាបឋមសិក្សាវត្តបូព៌

កម្មវត្ថុ ៖ សំណើសុំអនុញ្ញាតឲ្យនិស្សិតចំនួនពីររូបចុះកម្មសិក្សា។

យោង ៖ សំណើរបស់សាមីនិស្សិតចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក នាយក ជ្រាបថា៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចបាន និងកំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍។ អំឡុងពេលសិក្សាឆ្នាំបញ្ចប់ និស្សិតយើងខ្ញុំចំនួនពីររូបដូចមានបញ្ជីរាយនាមជូនភ្ជាប់មកជាមួយនេះ ត្រូវចុះកម្មសិក្សា និងស្វែងយល់ពីការងារមួយចំនួនដែលទាក់ទងនឹងប្រធានបទស្តីពី "ប្រសិទ្ធភាពនៃការអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌" នៅសាលាបឋមសិក្សាវត្តបូព៌ ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២០ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ ដើម្បីទទួលបានមកវិញនូវបទពិសោធន៍ការងារជាក់ស្តែង និងដើម្បីសរសេររបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សារបស់ខ្លួន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក នាយក មេត្តាពិនិត្យលទ្ធភាពអនុញ្ញាតឲ្យនិស្សិតយើងខ្ញុំបានចុះកម្មសិក្សាតាមការគួរ។

សូម លោក នាយក ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

ជ. សាកលវិទ្យាធិការ
សាកលវិទ្យាធិការរង

យិត_សុវុច

ពីង ពិមឆេន

សាម_ឡាន

Monivong Blvd, Sangkat Tonle Bassac, Khan Chamkamon, Phnom Penh, Cambodia.
P.O. Box 842, Tel: (855) 23 214 703, Fax: (855)23 214 953, E-mail: rector@rule.edu.kh,website: www.rule.edu.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**បញ្ជីរាយនាម**
**និស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ក្រុម D4C1**
**ឆ្នាំសិក្សា ២០១៩-២០២០**
**ដែលត្រូវចុះកម្មសិក្សានៅ សាលាបឋមសិក្សាវត្តបូព៌**

| ល.រ | គោត្តនាម-នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | លេខទូរស័ព្ទ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ជុំ ពេជ្រនីតា | ស្រី | ២០/កញ្ញា/១៩៩៨ | ០១០ ៣៤៥ ៣៦៥ | |
| ២ | អ៊ិន វឌ្ឍនា | ស្រី | ០៣/កក្កដា/១៩៩៨ | ០៩២ ៤៥៧ ៨៨៧ | |

ថ្ងៃសៅរ៍ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០
**ប្រធានការិយាល័យស្រាវជ្រាវ**

ញ៉ឹក_វុទ្ធី

ឃើញ & ឯកភាព
នាយកសាលា

ពីង គិមឆេន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំអនុញ្ញាតចុះកម្មសិក្សា

យើងខ្ញុំឈ្មោះ ជុំ ពេជ្រនីតា និង អ៊ិន វឌ្ឍនា ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ ជំនាន់ទី៤ ក្រុមD4C1 ឆ្នាំសិក្សា២០១៩-២០២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពជូន**
**ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

កម្មវត្ថុ ៖ សំណើសុំអនុញ្ញាតចុះកម្មសិក្សា។

តាមកម្មវត្ថុខាងលើ ខ្ញុំយើងមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា៖ បន្ទាប់ពីបានធ្វើការសិក្សាផ្នែកទ្រឹស្តី យើងខ្ញុំត្រូវសរសេររបាយការណ៍កម្មសិក្សា និងការពារបញ្ចប់ការសិក្សាដែលទាក់ទងនឹងប្រធានបទស្តីពី "ប្រសិទ្ធភាពនៃការអប់រំរបស់សាលាបឋមសិក្សាវត្តបូព៌" ដោយត្រូវចុះកម្មសិក្សានៅសាលាបឋមសិក្សាវត្តបូព៌ ចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២០ ដល់ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាអនុញ្ញាតឲ្យយើងខ្ញុំបានចុះកម្មសិក្សាដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃសៅរ៍ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២០០
ហត្ថលេខា

ជុំ ពេជ្រនីតា　　អ៊ិន វឌ្ឍនា